ព្រះរាជាណាចក្រកម្ពុជា

— ជាតិ សាសនា ព្រះមហាក្សត្រ —

ក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា

## របាយការណ៍

# ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារ ក្នុងរាជធានី-ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា



# បុព្វកថា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ.) រៀបចំផ្សព្វផ្សាយរបាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងបានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានី-ខេត្តចំនួន៥ ដែលរួមមានជាអាទិ៍ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកណ្តាល និងខេត្តព្រះសីហនុ នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ ខែកុម្ភៈ ឆ្នាំ២០១៥ ហើយបានបោះពុម្ពផ្សាយរបាយការណ៍បឋមនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦។ ដោយមានការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងអង្គការយូនីសេហ្វ ក្រសួង ស.អ.យ. បានបន្តធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារដែលនៅសេសសល់ចំនួន២០ខេត្តទៀត ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០១៥។

គោលបំណងនៃការកំណត់ទីតាំងកន្លែងថែទាំកុមារទាំងអស់ គឺដើម្បីកំណត់អត្តសញ្ញាណកន្លែងថែទាំកុមារដោយរាប់បញ្ចូលកន្លែងថែទាំកុមារដែលមិនទាន់បានចុះបញ្ជីជាមួយក្រសួង ស.អ.យ. និងធ្វើការប្រមូលព័ត៌មានមូលដ្ឋានអំពីប្រភេទកន្លែងថែទាំជំនួស និងចំនួនកុមារដែលកំពុងរស់នៅក្នុងទីកន្លែងទាំងនោះ។ ផ្អែកលើរបាយការណ៍ដ៏មានសារៈសំខាន់នេះ ក្រសួងបានដាក់ចេញនូវ "ផែនការសមាហរណកម្មកុមារចំនួន៣០ ភាគរយពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៨ ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារ" ។ ក្រសួង ស.អ.យ. នឹងដាក់បញ្ចូលទៅក្នុងផែនការអធិការកិច្ចប្រចាំឆ្នាំចំពោះកន្លែងថែទាំកុមារទាំងអស់ដែលត្រូវបានរកឃើញ ហើយកន្លែងថែទាំកុមារទាំងអស់ត្រូវដាក់ពាក្យស្នើសុំទទួលស្គាល់ពីក្រសួង ស.អ.យ. ដោយផ្អែកតាមការកំណត់នៅក្នុងអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។

ការសិក្សានេះបានរកឃើញកន្លែងថែទាំកុមារចំនួន ៦៣៩ កន្លែង កំពុងប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកុមារ និងយុវជនវ័យក្មេងសរុបចំនួន ៣៥.៣៧៤ នាក់ (ស្រី៤៥%) ក្នុងនោះ ២៦.១៨៧នាក់មានអាយុក្រោម១៨ឆ្នាំ (កុមារី៤៨%) និងយុវជនវ័យក្មេងចំនួន ៩.១៨៧នាក់ ដោយផ្អែកតាមស្វ័យរាយការណ៍ពីបុគ្គលិកកន្លែងថែទាំកុមារ។ ក្នុងចំណោម ៦៣៩កន្លែង មានមណ្ឌលថែទាំកុមារចំនួន ៤០៦មណ្ឌលដែលមានកុមារចំនួន១៦.៥៧៩នាក់ (កុមារីចំនួន៤៧%) ផ្ទះស្នាក់នៅបណ្តោះអាសន្ននិងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្នចំនួន២៥កន្លែង ផ្ទះស្នាក់នៅជាក្រុម ចំនួន៧១កន្លែង វត្តអារាម រឺអគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ ចំនួន៦៥កន្លែង និង អន្តេវាសិកដ្ឋាន ចំនួន៧២កន្លែង។

របាយការណ៍នេះបានធ្វើការវិភាគបន្ថែមទៅលើទិន្នន័យ ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានីខេត្តចំនួន៥កន្លងមក និងបានផ្តល់អនុសាសន៍ ដើម្បីពង្រឹងប្រព័ន្ធថែទាំជំនួសចំពោះកុមារ។ ផ្អែកលើគំហើញនេះ ក្រសួងនឹងពង្រឹងការអនុវត្តគោលនយោបាយ និងក្របខណ្ឌច្បាប់នានានិងសកម្មភាពផ្សេងៗដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលនានា ដើម្បីអនុវត្តអនុសាសន៍ដែលបានមកពីលទ្ធផលនៃការសិក្សាដោយឈរលើគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ និងការចូលរួមសម្រេចចិត្តរបស់កុមាររាល់បញ្ហាដែលទាក់ទងនឹងកុមារ។
ក្រសួង ស.អ.យ. សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ

នានា អង្គការយូនីសេហ្វ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ព្រមទាំងគ្រប់អង្គការដែលជាសមាជិកកម្មវិធី "ភាពជាដៃគូសម្រាប់កិច្ចការពារកុមារ" ដែលបានផ្តល់កិច្ចគាំទ្របច្ចេកទេសដល់ការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ។ ក្រសួងសូមថ្លែងអំណរគុណជាពិសេស ចំពោះទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិកដែលបានផ្តល់ការគាំទ្រដល់ដំណើរការកំណត់ទីតាំងកន្លែងថែទាំកុមារ ដែលនឹងជួយធ្វើអោយប្រសើរឡើងនូវប្រព័ន្ធថែទាំកុមារនៅកម្ពុជា។

ក្រសួងសូមកោតសរសើរចំពោះនាយកដ្ឋានសុខុមាលភាពកុមារ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌទាំងអស់។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសូមស្វាគមន៍ចំពោះមតិយោបល់ស្ថាបនាពីគ្រប់ដៃគូពាក់ព័ន្ធនានា ដើម្បីប្រើប្រាស់ទិន្នន័យនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៧

រដ្ឋមន្ត្រី

វង សូត

រចនាដោយ ៖
©Nova (Cambodia) Co., Ltd/2017

ត្រូវសុំការអនុញ្ញាតជាមុន ចំពោះការផលិតឡើងវិញនូវផ្នែកណាមួយនៃឯកសារនេះ។

សូមទាក់ទង:
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: +៨៥៥ ២៣ ២១៤ ០៣៩
អ៊ីមែល: mosvy.cwd@gmail.com
គេហទំព័រ: mosvy.gov.kh

រាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ២០១៧

# មាតិកា


បុព្វកថា ០២

និយមន័យ ០៦

សង្ខេប ០៨

១ សេចក្តីផ្តើម ១៤

២ សាវតា ១៤

៣ វិធីសាស្ត្រ ១៨

៤ គំហើញ និងការពិភាក្សា ២១

៤.១ គំហើញទូទៅអំពីចំនួន និងប្រភេទកន្លែងថែទាំកុមារ ២១

៤.២. គំហើញអំពីមណ្ឌលថែទាំកុមារ ២៤

៤.៣ គំហើញអំពីកុមារដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ ៣២

៤.៤ គំហើញអំពីកន្លែងថែទាំកុមារប្រភេទដទៃទៀត និងកុមារដែលកំពុងរស់នៅកន្លែងទាំងនោះ ៣៨

៤.៥ យុវជនវ័យក្មេងដែលកំពុងរស់នៅក្នុងកន្លែងថែទាំប្រភេទផ្សេងៗគ្នា ៤២

៥ អត្ថន័យចំពោះគោលនយោបាយ ៤៣

៦ សេចក្តីសន្និដ្ឋាន ៤៧

# និយមន័យ



## ការថែទាំតាមមណ្ឌល

ការថែទាំដែលផ្តល់ជូនជាក្រុមនៅតាមកន្លែងទាំងឡាយណាដែលមិនមែនជាគ្រួសារដូចជាកន្លែងសុវត្ថិភាពសម្រាប់ការថែទាំនៅពេលមានគ្រោះអាសន្ន មណ្ឌលសំចត ក្នុងស្ថានភាពគ្រោះអាសន្ន និងរាល់កន្លែងថែទាំរយៈពេលខ្លី និងរយៈពេលវែងដទៃទៀត រួមមានផ្ទះស្នាក់នៅជាក្រុម (គោលការណ៍ណែនាំអង្គការសហប្រជាជាតិស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០១០)។



## កន្លែងថែទាំកុមារ

មណ្ឌលដែលពុំមានទម្រង់ជាការថែទាំតាមគ្រួសារ និងដំណើរការដោយបុគ្គលិកទទួលបានបៀវត្សរ៍ ដែលកុមាររស់នៅ និងទទួលបានសេវា ព្រមទាំងទទួលទានដំណេកនៅពេលយប់។ និយមន័យនេះរាប់បញ្ចូលរាល់ទីកន្លែងទាំងអស់ដែលត្រូវបានកំណត់នៅក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ
ស្តីពីការថែទាំជំនួសចំពោះកុមារ។ ប៉ុន្តែសម្រាប់គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ មានតែកន្លែងថែទាំប្រភេទខាងក្រោមប៉ុណ្ណោះ ដែលត្រូវបានយកមកពិចារណា ៖ មណ្ឌលថែទាំកុមារ ឬ ("មណ្ឌលកុមារ កំព្រា") ផ្ទះស្នាក់នៅបណ្តោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន ផ្ទះស្នាក់នៅជាក្រុម ការថែទាំតាមវត្តអារាម និងអគារសាសនាដទៃទៀត ព្រមទាំងអន្តេវាសិកដ្ឋាន (សូមមើលរូបភាពទី១)។ កន្លែងថែទាំកុមារទាំងនេះត្រូវបានប្រើប្រាស់ជាទូទៅក្នុងប្រទេសកម្ពុជា។

ក្នុងចំណោមកន្លែងថែទាំកុមារទាំង៥ប្រភេទ របាយការណ៍នេះផ្តោតលើមណ្ឌលថែទាំកុមារដូចបានកំណត់នៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ(ឆ្នាំ២០០៦)។ បើទោះបីជា កន្លែងថែទាំកុមារទាំងអស់គប្បីទទួលបានការត្រួតពិនិត្យក៏ដោយ ប៉ុន្តែដោយសារតែវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះនៅមានកម្រិត ដូច្នេះ គេបានផ្តោតអាទិភាពលើមណ្ឌលថែទាំកុមារ។ ព័ត៌មានលម្អិតអំពីកន្លែងថែទាំកុមារដទៃទៀត ត្រូវបានរំពឹងថានឹងមាននៅពេលអនាគតតាមរយៈដំណើរការ មួយចំនួន ដូចជាការជូនដំណឹង និងការផ្តល់ការអនុញ្ញាតដែលតម្រូវឱ្យកន្លែងថែទាំកុមារទាំងនោះធ្វើការស្នើសុំដើម្បីប្រតិបត្តិការបន្ត។

### មណ្ឌលថែទាំកុមារ

កន្លែងថែទាំកុមារមួយប្រភេទដែលផ្តល់សេវាជូនដល់កុមារគ្រប់ប្រភេទដែលត្រូវបានបោះបង់ចោល ឬ មិនអាចរស់នៅជាមួយគ្រួសារបង្កើត ឬ សាច់ញាតិនៅក្នុងសហគមន៍បាន និងដែលមានលក្ខខណ្ឌ ស្របទៅនឹងនិយមន័យបទដ្ឋានរបស់មណ្ឌលថែទាំកុមារ ដូចមានចែងនៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ។ ជាទូទៅ កន្លែងថែទាំកុមារទាំងនេះផ្តល់ការថែទាំក្នុងបរិយាកាសមួយដែលមិនមែនជាគ្រួសារ និងមានការរៀបចំរចនាសម្ព័ន្ធសម្រាប់កុមារជាច្រើននាក់។



## កុមារ

កុមារ គឺជាបុគ្គលទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ លើកលែងតែភាពពេញវ័យឆាប់ឈានមកដល់ (អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា១)។ នៅកម្ពុជា ចំណុចនេះមានន័យថា បុគ្គលទាំងឡាយណាដែលមានអាយុចន្លោះពី ០-១៧ឆ្នាំ ត្រូវបានចាត់ទុកថាជាកុមារ។



## យុវជន/មនុស្សវ័យក្មេង

អង្គការនានាអាចកំណត់និយមន័យក្រុមនេះខុសគ្នា។ សម្រាប់គោលបំណង នៃរបាយការណ៍នេះ យុវជន/មនុស្សវ័យក្មេង គឺជាបុគ្គលទាំងឡាយណាដែលមានអាយុចន្លោះពី១៨ទៅ២៨ឆ្នាំ។

### រូបភាពទី១ ៖ ប្រភេទកន្លែងថែទាំកុមារ

#### ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន

ទម្រង់មួយនៃការថែទាំតាមមណ្ឌលដែលមានកំណត់រយៈពេលស្នាក់នៅសម្រាប់កុមារ នៅក្នុងដំណើរការធ្វើផែនការអចិន្ត្រៃយ៍គ្រួសារ ឬ កុមារដែលគ្រួសារកំពុងជួបប្រទះវិបត្តិធ្ងន់ធ្ងរ និងទាមទារឱ្យកូនរបស់ពួកគេស្នាក់នៅបណ្តោះអាសន្ន ដើម្បីឱ្យបរិយាកាសគ្រួសារមានស្ថិរភាពឡើងវិញ។ បើទោះបីជាផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្នអាចធ្វើការបែងចែកបន្ថែមទៀតក៏ដោយ ប៉ុន្តែរបាយការណ៍នេះ ប្រើប្រាស់ពាក្យទាំងពីរនេះរួមគ្នាតែមួយ។

#### ផ្ទះស្នាក់នៅជាក្រុម

ការថែទាំដែលផ្តល់ជូនកុមារក្នុងចំនួនកំណត់ណាមួយនៅក្នុងបរិយាកាសមួយដែលដូចគ្នាទៅនឹងគ្រួសារ ក្រោមការត្រួតពិនិត្យពីអ្នកថែទាំមួយក្រុមតូច ដែលមិនមែនជាសាច់ញាតិរបស់កុមារ។ ជាទូទៅយ៉ាងហោចណាស់ មានអ្នកថែទាំ១នាក់ដែលបានទទួលការបណ្តុះបណ្តាល និងបម្រើការងារផ្តល់ការថែទាំដែលមិនពាក់ព័ន្ធនឹងវេជ្ជសាស្ត្រ និង គ្រប់គ្រងកុមាររយៈពេល២៤ម៉ោង នៅក្នុងបរិយាកាសមួយដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។

#### វត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់ការថែទាំ

ការថែទាំដែលផ្តល់ជូនកុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងស្ថាប័នសាសនា ដែលជួយដោះស្រាយសេចក្តីត្រូវការជាមូលដ្ឋានរបស់កុមារនៅក្នុងវត្ត និងកន្លែងសាសនាដទៃទៀត។

#### អន្តេវាសិកដ្ឋាន

ការរៀបចំលំនៅដ្ឋានសម្រាប់កុមារស្នាក់នៅរយៈពេលសិក្សាមួយវគ្គ ឬ ច្រើនវគ្គដើម្បីទទួលការអប់រំនៅឆ្ងាយពីផ្ទះ។ អន្តេវាសិកដ្ឋានត្រូវបានបញ្ចូលទៅក្នុងការកំណត់ទីតាំងកន្លែងថែទាំកុមារ ដោយសារតែមានក្តីបារម្ភថា សាលារៀនមួយចំនួនជាការពិតអាចជាមណ្ឌលថែទាំកុមារ។

# សង្ខេប

នៅចន្លោះឆ្នាំ២០០៥ ដល់ឆ្នាំ២០១១ មានការកើនឡើងចំនួនកុមារដែលរស់នៅក្នុងមណ្ឌលដោយសារមានការខ្វះខាតយន្តការ និងការគ្រប់គ្រងដែលនាំឲ្យក្រសួង ស.អ.យ និងបុគ្គលិកការពារកុមារមានការព្រួយបារម្ភជាខ្លាំងចំពោះសុវត្ថិភាពកុមារ។ កន្លងមកតាមការស្រាវជ្រាវបានបញ្ជាក់ថាកម្ពុជាមានទំលាប់ទុកដាក់កុមារកំព្រា និងកុមារងាយរងគ្រោះនៅតាមសហគមន៍ ឬតាមគ្រួសារសាច់ញាតិ។ ចំនួនមណ្ឌលថែទាំកុមារដែលបានចុះបញ្ជីជាផ្លូវការជាមួយក្រសួង ស.អ.យ. បានកើនឡើងពី ១៥៤មណ្ឌលដែលមានកុមារចំនួន ៦.២៥៤នាក់ ក្នុងឆ្នាំ២០០៥ រហូតដល់ ២៥៤មណ្ឌលដែលមានកុមារចំនួន ១១.១៧១នាក់ ក្នុងឆ្នាំ២០១៥។ ការស្រាវជ្រាវ និងភស្តុតាងកម្រិតសកលជាច្រើនបានបង្ហាញឱ្យដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃការថែទាំតាមមណ្ឌលថែទាំកុមារទៅលើការអភិវឌ្ឍផ្នែកសង្គម ផ្លូវកាយ សតិបញ្ញា និង ផ្លូវចិត្តរបស់កុមារបើធៀបទៅនឹងការថែទាំតាមគ្រួសារ[១]។

នៅពេលជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងកំណើននៃចំនួនកុមាររស់នៅក្នុងមណ្ឌល ក្រសួងបាននឹងកំពុងធ្វើការដកពិសោធន៍កម្មវិធី និងគោលនយោបាយផ្សេងៗជាច្រើន ដើម្បីគ្រប់គ្រងការថែទាំតាមមណ្ឌល និងវិស័យថែទាំកុមារនានា សំដៅការការពារកុមារឱ្យបានកាន់តែប្រសើរឡើង។ កំណែទម្រង់រចនាសម្ព័ន្ធមួយដ៏សំខាន់ គឺជាការផ្តួចផ្តើម និងការធ្វើអធិការកិច្ចទៀងទាត់ជាបន្តបន្ទាប់ទៅលើមណ្ឌលថែទាំកុមាររាប់រយកន្លែងដែលស្ថិតនៅទូទាំងប្រទេស។ បើទោះបីជាការធ្វើអធិការកិច្ចទាំងនេះ បានផ្តល់នូវព័ត៌មានដ៏មានតម្លៃអំពីសុខុមាលភាពរបស់កុមារដែលរស់នៅក្នុងមណ្ឌលក៏ដោយ ប៉ុន្តែព័ត៌មានទាំងនោះមិនទាន់គ្រប់ជ្រុងជ្រោយតាមតម្រូវការនៅឡើយ ដោយសារការធ្វើអធិការកិច្ចទៅលើតែមណ្ឌលទាំងឡាយណាដែលបានទទួលស្គាល់ជាផ្លូវការឬមានអនុស្សរណៈជាមួយក្រសួង។

ក្រសួងដឹងថានៅមានកន្លែងថែទាំកុមារជាច្រើនទៀតដែលស្ថិតក្រោមការត្រួតពិនិត្យដោយក្រសួង និងស្ថាប័នដទៃទៀត។ ដូច្នេះ នៅឆ្នាំ២០១៤ ក្រសួង ស.អ.យ. និងអង្គការយូនីសេហ្វ បានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ ប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់អត្តសញ្ញាណកន្លែងថែទាំទាំងនោះ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារទាំងអស់នៅក្នុងប្រទេសបានក្លាយជាអាទិភាពមួយរបស់ក្រសួង ស.អ.យ. ហើយបានចាប់ផ្តើមអនុវត្តផែនការប្រកបដោយមហិច្ឆិតាដើម្បីត្រួតពិនិត្យទៅលើការកើនឡើងនៃមណ្ឌលថែទាំកុមារ និងធ្វើសមាហរណកម្មកុមារដែលរស់នៅក្នុងមណ្ឌលទៅតាមគ្រួសារ និងសហគមន៍វិញ។ គោលនយោបាយនេះ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ ២០១៥។ អនុក្រឹត្យនេះបានបញ្ជាក់ផងដែរថា ក្រសួង ស.អ.យ. គឺជាស្ថាប័នតែមួយគត់ដែលមាននីតិសម្បទាទទួលបន្ទុកក្នុងការគ្រប់គ្រងមណ្ឌលទាំងអស់ដែលផ្តល់ការថែទាំកុមារ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារ មានគោលបំណងប្រមូលទិន្នន័យបឋមដើម្បីបង្កលក្ខណៈឱ្យក្រសួងអាចផ្តល់ការគ្រប់គ្រងលើវិស័យការថែទាំកុមារប្រកបដោយប្រសិទ្ធភាព។ គំហើញនេះ និងត្រូវបានប្រើប្រាស់ដើម្បី អនុវត្តកម្មវិធីសមាហរណកម្មកុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ដើម្បីសម្រេចឱ្យបាននូវគោលដៅផែនការសមាហរណកម្មកុមារចំនួន៣០ភាគរយពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨។ ក្រសួងបានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារជាពីរដំណាក់កាល ៖ លើកទី១ គឺជាការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានីខេត្តអាទិភាពទាំង៥ ដែលបានធ្វើឡើងកាលពីខែវិច្ឆិកា ឆ្នាំ២០១៤ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៥ និងលើកទី២ បានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារនៅខេត្តទាំង២០ដែលពុំទាន់បានធ្វើ ចាប់ពីខែតុលា រហូតដល់ខែធ្នូ ឆ្នាំ២០១៥។ របាយការណ៍បឋមអំពីរាជធានីខេត្តទាំង៥ ត្រូវបានផ្សព្វផ្សាយនៅខែមីនា ឆ្នាំ២០១៦ចំណែក របាយការណ៍នេះ បានធ្វើការបូកសរុប និងវិភាគទិន្នន័យទាំង ២៥ រាជធានីខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ទិន្នន័យដែលបានពីការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ បានជួយក្រសួងក្នុងការប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់រៀបចំគោលនយោបាយ កម្មវិធី និងសេចក្តីសម្រេចនានា និងជាភស្តុតាងដើម្បីធ្វើការប៉ាន់ប្រមាណលម្អិតអំពីស្ថានភាពរបស់មណ្ឌលថែទាំកុមារ និងការរស់នៅរបស់កុមារនៅកន្លែងថែទាំទាំងនោះ។ សកម្មភាពនេះ គឺជាជំហានមួយដ៏សំខាន់ដើម្បីគាំទ្រដំណើរការសមាហរណកម្មកុមារទៅរស់នៅជាមួយគ្រួសារ និងសហគមន៍វិញផងដែរ។

របាយការណ៍នេះផ្តល់នូវទិន្នន័យសំខាន់ៗ អំពីចំនួនកន្លែងថែទាំកុមារ នៅក្នុងរាជធានី ខេត្ត ទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតការយកចិត្តទុក

[១]សន្និសិទឡាដែន ស្តីពីការអភិវឌ្ឍន៍ និងការថែទាំកុមារដែលពុំមានឪពុកម្តាយអចិន្ត្រៃ ការអភិវឌ្ឍន៍ និងការថែទាំនៃវិជ្ជាស្ថានអប់រំកុមារ ការអភិវឌ្ឍន៍នៃទស្សនៈកុមារលើកទី៨ លេខ ២ នៃឆ្នាំ២០១២ ទំព័រ១៧៤-១៨០។ កម្មវិធីការពាររបស់ ប៊ូឆារេស ទាក់ទងនិងការថែទាំកុមារកំព្រា កុមារបោះបង់ចោល កុមារត្រូវបានគេធ្វើទោស: http:www.crin.org/docs/PPT%20Group.pdf ១៥ តុលា ២០០៩ myers, john E.B, Child p.77; Browne, Kevin. វិជ្ជាស្ថាលគ្រប់គ្រងហានិភ័យយុវជន ការសែតស្តីពីការធ្វើឲ្យប្រសើរឡើងនៃបណ្តាញការងារ Save the Children ឆ្នាំ២០០៩ ការសង្ខេបទាក់ទងនិងការស្រាវជ្រាវ របស់លោក John Williamson, John and Aaron Greenberg, Family, not orphanages និងការសែតស្តីពីការធ្វើឲ្យប្រសើរឡើងនៃបណ្តាញការងារ Save the Children ឆ្នាំ២០១០។

ដាក់ទៅលើមណ្ឌលថែទាំកុមារ (“មណ្ឌលកុមារកំព្រា”) ដែលស្របទៅបទដ្ឋានថែទាំជំនួសចំពោះកុមារ។ ទិន្នន័យត្រូវបានប្រមូលដោយមន្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ របស់ក្រសួង ដែលចុះពិនិត្យដោយផ្ទាល់ទៅតាមកន្លែងថែទាំកុមារដែលត្រូវបានកំណត់រកឃើញ ក្រោយពេលពិគ្រោះយោបល់ជាមួយមេភូមិ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់។ ទិន្នន័យអំពីចំនួនកុមារអាចខុសពីចំនួនកុមារនៅកន្លែងថែទាំកុមារជាក់ស្តែង ដោយសារអ្នកប្រមូលទិន្នន័យមិនបានចុះពិនិត្យរាប់ចំនួនកុមារដោយផ្ទាល់ទេគឺ អាស្រ័យលើស្វ័យរាយការណ៍របស់បុគ្គលិកនៃកន្លែងថែទាំកុមារ។

## សង្ខេបអំពីគំហើញសំខាន់ៗ

នៅកម្ពុជាមានកន្លែងថែទាំកុមារសរុបចំនួន ៦៣៩ ដែលកំពុងធ្វើប្រតិបត្តិការ ហើយត្រូវបានបែងចែកជា៥ ប្រភេទ៖

| | | | | |
|---|---|---|---|---|
| ៤០៦ | ២៥ | ៧១ | ៦៥ | ៧២ |
| មណ្ឌលថែទាំកុមារ | ផ្ទះស្នាក់នៅបណ្តោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន | ផ្ទះស្នាក់នៅជាក្រុម | វត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ | អន្តេវាសិកដ្ឋាន |

យោងតាមទិន្នន័យអធិការកិច្ចឆ្នាំ២០១៥ បានបង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន២៥៤ មណ្ឌល ដោយឡែកការកំណត់ទីតាំងមណ្ឌលថែទាំកុមារបានរកឃើញមណ្ឌលថែទាំកុមារចំនួន៤០៦មណ្ឌល លទ្ធផលនេះបានបង្ហាញពីភាពខុសប្លែកគ្នាប្រមាណ ៣៨%។ បន្ថែមពីលើនេះមណ្ឌលថែទាំកុមារចំនួន២១% ពុំមានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងទេ ហើយ១២% ទៀតក៏មិនបានចុះបញ្ជីជាមួយស្ថាប័នណាមួយរបស់រដ្ឋាភិបាលដែរ។ ចំណុចនេះបង្ហាញអោយឃើញអំពីចន្លោះប្រហោងគួរឱ្យកត់សម្គាល់ ក្នុងការធ្វើនិយតកម្មទៅលើមណ្ឌលថែទាំកុមារមួយចំនួនធំដែលនាំមកនៅការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខុមាលភាពរបស់កុមារដែលរស់នៅក្នុងមណ្ឌលទាំងនោះ។ បន្ថែមពីការបារម្ភនេះ នៅមានភាពខុសប្លែកគ្នាជាច្រើននៅក្នុងខេត្តទាំង៩ ដោយសារកន្លែងថែទាំកុមារភាគច្រើនមិនមានការអនុញ្ញាត ហើយមានចំនួនកុមារច្រើនជាងគេ។

បើទោះបីជាមានការកើនឡើងនៃចំនួនមណ្ឌលថែទាំកុមារនៅកម្ពុជាក៏ដោយ តែរបាយកន្លែងថែទាំកុមារមិនស្មើគ្នាទេពីខេត្តមួយទៅខេត្តមួយ ហើយក៏មិនមែនគ្រប់ខេត្តទាំងអស់មានកំណើនកន្លែងថែទាំនោះដែរ។ ខេត្តមួយចំនួនបានកត់ត្រា ថាមានការកើនឡើងតែបន្តិចបន្តួចប៉ុណ្ណោះ។ បើប្រៀបធៀបទៅនឹងលទ្ធផលនានានៃរបាយការណ៍អធិការកិច្ចឆ្នាំ ២០១៥ បានឱ្យដឹងថាមិនមានមណ្ឌលដែលមិនបានរកឃើញពីមុនមកត្រូវបានកត់ត្រាទុកក្នុងខេត្តទាំង៩នោះទេ ទិន្នន័យនេះក៏បានបង្ហាញឱ្យដឹងផងដែរថា ខេត្តជាច្រើនមានចំនួនមណ្ឌលតិចគួរឱ្យកត់សម្គាល់។ ប៉ុន្តែការកំណត់ទីតាំងមណ្ឌលបានបញ្ជាក់ថា មណ្ឌលថែទាំកុមារមានចំនួនច្រើនជាងកន្លែងថែទាំកុមារប្រភេទដទៃទៀត។ មានតែខេត្តចំនួន ១ ប៉ុណ្ណោះដែលបានកត់ត្រាថាគ្មានមណ្ឌលថែទាំកុមារ។ ដោយឡែកមានខេត្តចំនួន១៩ បានកត់ត្រាថាគ្មានមណ្ឌលសំចត ១១ខេត្តបានកត់ត្រាថាគ្មានផ្ទះស្នាក់នៅជាក្រុម និង ១០ខេត្តបានកត់ត្រាថាគ្មានអន្តេវាសិកដ្ឋាន ឬវត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារឡើយ។

របាយមណ្ឌលថែទាំកុមារនៅកម្ពុជាមានចំនួនមណ្ឌលខុសគ្នា។ មណ្ឌលភាគច្រើនប្រមូលផ្តុំនៅក្នុងរាជធានីខេត្តចំនួន៩ ដែលស្មើរនឹង ៨៣% មានមណ្ឌល១១៧កន្លែងនៅរាជធានីភ្នំពេញ បន្ទាប់មកគឺ ខេត្តសៀមរាប ៨០កន្លែង ខេត្តបាត់ដំបង ៣៥កន្លែង ខេត្ត កំពង់ធំ ២៣កន្លែង ខេត្តកណ្តាល ២០កន្លែង ខេត្តកំពត ១៧កន្លែង ខេត្តកំពង់ឆ្នាំង ១៦កន្លែង ខេត្តព្រះសីហនុ ១៥កន្លែង និងខេត្តកំពង់ស្ពឺ ១៥កន្លែង[៣]។

[២] មណ្ឌលថែទាំកុមារ សំដៅដល់មណ្ឌលទាំងឡាយណាដែលមានលក្ខខណ្ឌស្របទៅនឹងនិយមន័យបទដ្ឋាន (ជាទូទៅត្រូវបានសំដៅដល់ មណ្ឌលកុមារកំព្រា ហើយមណ្ឌលគឺជាចំនុចដែលត្រូវយកចិត្តទុកដាក់ចម្បងនៃរបាយការណ៍នេះ។ កន្លែងថែទាំកុមារដែលនៅសេសសល់ដទៃទៀត នឹងត្រូវបាន សំដៅហៅថា កន្លែងថែទាំកុមារប្រភេទ “ដទៃទៀត”។

# សង្ខេប

រាជធានីភ្នំពេញ និងខេត្តសៀមរាប មានមណ្ឌលចំនួន ៤៩% នៃចំនួនមណ្ឌលសរុបទូទាំងប្រទេស។ មណ្ឌលថែទាំកុមារមានចំនួនចន្លោះពី១ ទៅ ៩ កន្លែង ក្នុងខេត្តដែលនៅសេសសល់ចំនួន១៥ទៀត។ ពុំមានការកត់ត្រាអំពីមណ្ឌលថែទាំកុមារនៅក្នុងខេត្តត្បូងឃ្មុំឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេសនោះគឺចំនួនផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្នមានចំនួនតិចជាងគេបំផុតក្នុងចំណោកន្លែងថែទាំកុមារសរុបគឺមានចំនួនត្រឹមតែ៤% និងត្រូវបានរកឃើញតែនៅក្នុងខេត្តចំនួន៦ប៉ុណ្ណោះ។ទន្ទឹមនឹងនេះដែរកុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលថែទាំកុមារក៏មានការប្រមូលផ្តុំនៅក្នុងរាជធានីខេត្តទាំង៩ ដែលមានចំនួនមណ្ឌលច្រើនជាងគេបំផុតផងដែរ។ ក្នុងចំណោមកុមារសរុបមានកុមារចំនួន ៨៧% ឬ កុមារចំនួន ១៤.៣៦៧នាក់ នៅក្នុងរាជធានីខេត្តទាំង៩នេះ។ ដោយឡែក រាជធានី-ខេត្តអាទិភាពទាំង៥[៤] ត្រូវបានរកឃើញថាមានចំនួនកុមារច្រើនជាងគេបំផុតរហូតដល់ ១១.៧៨៨នាក់ ឬ ៧១% នៃចំនួនកុមារសរុប បើទោះបីជារាជធានីខេត្តទាំង៥នេះពុំមានចំនួនមណ្ឌលច្រើនជាងគេបំផុតក៏ដោយ។ គ្រាន់តែរាជធានីភ្នំពេញ និងខេត្តសៀមរាបមានកុមារចំនួន ៥១% ឬ ៨.៣៨៩នាក់ ក្នុង ចំណោមកុមារសរុប។ បន្ថែមពីនេះទៀត មណ្ឌលភាគច្រើន (៩២%) ដែលមិនត្រូវបានធ្វើអធិការកិច្ចគឺស្ថិតនៅក្នុងរាជធានីខេត្តចំនួន៨ នៃរាជធានីខេត្តទាំង៩ ដែលមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារច្រើន លើកលែងតែខេត្តកំពង់ស្ពឺ។

មណ្ឌលថែទាំកុមារភាគច្រើន (៧២%) ផ្តល់ការថែទាំរយៈពេលវែងលើសពី៦ខែ បើទោះបីជាមានការយល់ដឹងយ៉ាងច្បាស់អំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងការរក្សាកុមារនៅក្នុងមណ្ឌលរយៈពេលវែងក៏ដោយ ហើយគោលការណ៍ណែនាំរបស់ក្រសួង និងគោលការណ៍ណែនាំអន្តរជាតិបានថ្លែងថាការថែទាំតាមមណ្ឌលគប្បីជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ ហើយការថែទាំតាមគ្រួសារ និងសហគមន៍ទើបជាជម្រើសប្រសើរបំផុតសម្រាប់ការថែទាំជំនួស។

ជាមធ្យម មានបុគ្គលិកផ្លូវការ ឬ បុគ្គលិកជាប់កិច្ចសន្យា ១រូប ដែលបម្រើការងារដោយទទួលបានបៀវត្សរ៍ មើលថែកុមារចំនួន៣នាក់ដែលរស់នៅក្រោមការថែទាំជំនួស។

កុមារភាគច្រើន (៦៣%) ដែលទទួលការថែទាំជំនួសរស់នៅក្នុងមណ្ឌលថែទាំកុមារ ឬ"មណ្ឌលកុមារកំព្រា"។ កុមារសរុបចំនួន ១៦.៥៧៩នាក់ (៤៧%ជាកុមារី) ត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន ៤០៦កន្លែង។ យោងតាមតួលេខចំនួនប្រជាជនឆ្នាំ២០១៥ នេះមានន័យថា មានកុមារស្ទើរតែ១នាក់ក្នុងចំណោមកុមារ៣៥០នាក់កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ[៥]។

មានកុមារចំនួន ៩,៦០៨នាក់ បន្ថែមទៀត (៤៩% ជាកុមារី) ត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមារដទៃទៀតចំនួន ២៣៣កន្លែង ក្នុងចំណោមកន្លែងថែទាំកុមារសរុប។ កុមារសរុបដែលរស់នៅក្នុងកន្លែងថែទាំកុមារទាំង ៦៣៩កន្លែង មានចំនួន ២៦.១៨៧នាក់ (៤៨%ជាកុមារី)។ បន្ថែមពីនេះទៀត មានយុវជនវ័យក្មេងចំនួន ៩.១៨៧ នាក់ដែលមានអាយុចន្លោះពី ១៨ ទៅ ២៤ឆ្នាំ (៣៦%ជាស្ត្រី) ត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមារទាំង ៦៣៩កន្លែង ដែលក្នុងនោះ ភាគច្រើន (៧៩%) រស់នៅក្នុងមណ្ឌលថែទាំកុមារ។ ចំនួនកុមារ និងយុវជនវ័យក្មេងសរុប ៣៥.៣៧៤នាក់ (៤៥%ជាស្ត្រី) ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងកន្លែងថែទាំទាំង ៦៣៩ ។

មានកុមារា(៥៣%) កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ និង (៥២%) កំពុងរស់នៅក្នុងអន្តេវាសិកដ្ឋាន។ កុមារប្រមាណ៥០% ដែលរស់នៅតាមវត្តអារាម និងអគារសាសនាដទៃទៀត គឺជាកុមារី។ មានកុមារី (៥៥%) កំពុងរស់នៅតាមមណ្ឌលស្នាក់នៅ
បណ្តោះអាសន្ន និង (៥២%) កំពុងរស់នៅក្នុងអន្តេវាសិកដ្ឋាន។

ព័ត៌មានបន្ថែមត្រូវបានប្រមូលផ្តុំនៅក្នុងការប្រមូលទិន្នន័យលើកទី២ ពីខេត្តចំនួន២០ទៀត។ សកម្មភាពនេះបានបង្ហាញឱ្យដឹងថា មណ្ឌលថែទាំកុមារ ៧៧% ក្នុងចំណោមមណ្ឌលចំនួន ១២៦ ក្នុងខេត្តចំនួន ២០ ដែលគ្រប់គ្រងដំណើរការដោយជនជាតិខ្មែរ។ កុមារភាគច្រើនដែល រស់នៅក្នុង
មណ្ឌលទាំងនេះ ក៏ត្រូវបានរាយការណ៍ឱ្យដឹងផងដែរថាស្ថិតក្នុងវ័យសិក្សាក្នុងនោះ ៦៧% មានអាយុចន្លោះពី ១១ ទៅ ១៧ឆ្នាំ និង ៣២% មានអាយុចន្លោះពី ៤ ទៅ ១០ឆ្នាំ។ កុមារដែលមានអាយុ ចន្លោះពី ០ ទៅ ៣ឆ្នាំ មានចំនួន ៨០នាក់ ដែលស្មើនឹង ២% នៃចំនួនកុមារសរុបដែលរស់នៅក្រោមការថែទាំក្នុងមណ្ឌល។ ក្នុងចំណោមខេត្តទាំង២០ មានខេត្តចំនួន៣ តាកែវ កំពង់ស្ពឺ និង កំពត ដែលមានកុមារ ៥៦% ដែលមាន

[៣] ចាប់ពីត្រង់ចំនុចនេះតទៅ ការសំដៅហៅថារាជធានី-ខេត្តទាំង៩ គឺសំដៅចំពោះរាជធានី-ខេត្តទាំងនេះ។

[៤]រាជធានី-ខេត្តអាទិភាពទាំង៥ រួមមាន ខេត្តបាត់ដំបង ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តសៀមរាប ដែលកំពុងត្រូវបានកំណត់ គោលដៅសម្រាប់សេវាដកកុមារចេញពីមណ្ឌល និងសេវាសមាហរណកម្មរបស់ក្រសួង ស.អ.យ. និងអង្គការយូនីសេហ្វ ដោយមានកិច្ចសហការជាមួយដៃគូរបស់កម្មវិធី 3PC និង មានកិច្ចគាំទ្រហិរញ្ញវត្ថុពីមូលនិធិសម្រាប់កុមារដែលត្រូវបានជម្លៀស និងកុមារកំព្រា របស់ USAID។

[៥] យោងតាមការព្យាករណ៍ចំនួនប្រជាជនឆ្នាំ២០១៥ ចំនួនកុមារសរុបអាយុក្រោម១៨ឆ្នាំត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៥.៨៥០.០០០នាក់
(UNDESA, 2015)។

វ័យក្មេងជាងគេបំផុត។
កុមារគ្រប់រូប ដែលមានអាយុចន្លោះពី ០ ទៅ ៣ឆ្នាំ ត្រូវបានរកឃើញថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមាររយៈពេលវែង។

នៅក្នុងខេត្តទាំង២០នេះ មានមណ្ឌលថែទាំកុមារតាមកន្លែងសាសនា ៥៩% នៃមណ្ឌលថែទាំកុមារដែលមិនមែនជាលក្ខណៈសាសនា។ មណ្ឌលថែទាំកុមារតាមកន្លែងសាសនា ភាគច្រើនគឺជាកន្លែងសាសនាគ្រិស្ត (៨៩%) និងបន្ទាប់មកគឺកន្លែងសាសនាព្រះពុទ្ធ (១១%)។ បន្ថែមពីនេះទៀត មានវត្តអារាមចំនួន៦៥ និងអគារសាសនាដទៃទៀត ដែលការកំណត់ទីតាំង មិនបានធ្វើការបែងចែកប្រភេទការថែទាំកុមារ តែអាចកំណត់បានថាភាគច្រើនគឺ កន្លែងសាសនា។

# សង្ខេបអំពីអត្ថន័យ គោលនយោបាយសំខាន់ៗ

### ឆ្លើយតបទៅនឹងកំណើននៃចំនួនកន្លែងថែទាំកុមារ ដោយរាប់បញ្ចូលទាំងមណ្ឌលថែទាំកុមារ តាមរយៈការដកកុមារចេញពីមណ្ឌល ការធ្វើសមាហរណកម្ម និងការគ្រប់គ្រងករណីសមស្របទៅលើកុមារគ្រប់រូប៖

គំហើញបង្ហាញឱ្យដឹងថា ក្រសួង ស.អ.យ. ត្រូវពង្រីកវិសាលភាពនៃការងាររបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងចំនួនមណ្ឌលថែទាំកុមារដែលបានកើនឡើងនៅក្នុងប្រទេស។ កន្លែងផ្តល់ការថែទាំប្រភេទជាច្រើនពុំមានលក្ខខណ្ឌស្របទៅនឹងនិយមន័យរបស់មណ្ឌលថែទាំកុមារ ប៉ុន្តែបានផ្តល់ការថែទាំជូនកុមារ នេះបង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការជាបន្ទាន់ក្នុងការទុកដាក់កន្លែងទាំងនោះឲ្យស្ថិតនៅក្រោមការយកចិត្ត ទុកដាក់បែបជាកម្មវិធី និងគោលនយោបាយឱ្យបានកាន់តែប្រសើរជាងនេះ ដោយពិចារណាទៅលើសេវាថែទាំជំនួសតាមគ្រួសារដែលមានចំនួនតិចតួចនៅឡើយនៅកម្ពុជា សេវាបែបនេះក៏នឹងត្រូវពង្រីក ផងដែរឲ្យស្របគ្នាទៅនឹងកំណើនចំនួនកុមារដែលនឹងត្រូវដកចេញពីមណ្ឌល និងធ្វើសមាហរណកម្មទៅជាការថែទាំតាមគ្រួសារវិញ។

### សេចក្តីត្រូវការឱ្យជ្រើសរើសប្រើប្រាស់យុទ្ធសាស្ត្រទ្វេវិធាន ដើម្បីឆ្លើយតបទៅនឹង របាយមិនស្មើភាពគ្នានៃកន្លែងថែទាំកុមារក្នុងប្រទេសកម្ពុជា៖

បើទោះបីជាមានការកើនឡើងជារួមនៃចំនួនមណ្ឌលថែទាំកុមារនៅកម្ពុជាក៏ដោយ ប៉ុន្តែរបាយនៃកន្លែងទាំងនេះពុំមានភាពស្មើគ្នាឡើយ។ គំហើញបានបង្ហាញឱ្យដឹងអំពីសេចក្តីត្រូវការក្នុងការជ្រើសរើសប្រើប្រាស់យុទ្ធសាស្ត្រទ្វេវិធានមួយដើម្បីកាត់បន្ថយ នៅក្នុងបណ្តារាជធានីខេត្តដែលមានចំនួនមណ្ឌលថែទាំកុមារច្រើន និងទប់កុំឱ្យមានការកើនឡើង(ចំពោះកន្លែងដែលកំណត់រកឃើញថាមានចំនួនមណ្ឌលតិច ហើយកុំអនុញ្ញាតិអោយបើកមណ្ឌលថ្មី)។

### ពិនិត្យឡើងវិញទៅលើរាជធានី-ខេត្តអាទិភាពទាំង៥ ៖

ក្នុងចំណោមរាជធានី-ខេត្តទាំង៩ ដែលបានរកឃើញមណ្ឌលថែទាំកុមារចំនួន៨៣% មានតែរាជធានី-ខេត្តចំនួន៥ប៉ុណ្ណោះ ដែលជាអាទិភាពរបស់ក្រសួង ស.អ.យ. ហើយក្រសួងបានប្តេជ្ញាចិត្តធ្វើសមាហរណកម្មកុមារចំនួន៣០% ប្រកបដោយសុវត្ថិភាពពីមណ្ឌលថែទាំកុមារ។ រាជធានីខេត្តទាំងនេះរួមមាន ភ្នំពេញ សៀមរាប បាត់ដំបង ព្រះសីហនុ និងកណ្តាល។
ការកំណត់ទីតាំង កន្លែងថែទាំកុមារ បានបញ្ជាក់ឱ្យដឹងថាការផ្តោតយកចិត្តទុកដាក់របស់កម្មវិធីទៅលើតំបន់ភូមិសាស្ត្រទាំងនោះនាពេលបច្ចុប្បន្នគឺជាការត្រឹមត្រូវ និងនៅតែមានភាពពាក់ព័ន្ធ អាស្រ័យដោយរាជធានី-ខេត្តទាំងនេះ មានចំនួនមណ្ឌលថែទាំកុមារច្រើន។ បន្ថែមពីនេះទៀត រាជធានីខេត្តអាទិភាពទាំង៥ ក៏មានកុមាររស់នៅក្នុងមណ្ឌលច្រើនជាងគេ
ផងដែរនិង មានកន្លែងថែទាំភាគច្រើនដែលពុំមានលិខិតអនុញ្ញាត។ បើទោះជាដូច្នេះក្តី ខេត្តចំនួន៤ទៀត កំពង់ឆ្នាំង កំពត កំពង់ធំ កំពង់ស្ពឺក៏បានបង្ហាញឱ្យឃើញអំពីការប្រមូលផ្តុំមណ្ឌលថែទាំកុមារក្នុងកម្រិតមួយដ៏ខ្ពស់ និងគប្បីត្រូវបានចាត់ទុកជាអាទិភាពផងដែរ។ ដូច្នេះ រាជធានី-ខេត្តខាងក្រោម គប្បីទទួលបានអាទិភាពខ្ពស់ ដោយផ្អែកលើគំហើញនៃការកំណត់ទីតាំងកន្លែងថែទាំកុមារ

ពណ៌ខៀវតំណាងអោយរាជធានីខេត្តបច្ចុប្បន្ន ហើយពណ៌ប្រផេះជាខេត្តដែលត្រូវបានស្នើសុំអោយមានការយកចិត្តទុកដាក់បន្ថែម ៖



# សង្ខេប

បន្ថែមពីរាជធានីខេត្តទាំង៩នេះខេត្តដែលមានអាទិភាពដែលគួរផ្តោតជាពិសេសគឺ ៖ ខេត្តតាកែវមានកុមារពិការច្រើនគួរឱ្យកត់សម្គាល់ កុមារផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ និង កុមារដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមដោយឡែក ខេត្តបន្ទាយមានជ័យមានអគារសាសនាច្រើនជាងគេ និងមានកុមាររស់នៅ ក្នុងអគារសាសនានោះ និងមណ្ឌលសំចតច្រើនដែលមានកុមារកំពុងរស់នៅក្នុងនោះ។

## ការកំណត់អាទិភាពទៅលើការថែទាំរយៈពេលខ្លី និងបណ្តោះអាសន្ន៖

ការស្រាវជ្រាវ ដែលបានដកស្រង់ខាងលើបញ្ជាក់ថាមណ្ឌលថែទាំរយៈពេលវែងជាច្រើនមិនត្រូវបានប្រើប្រាស់ជាជម្រើសបណ្តោះអាសន្ន ឬ ជាជម្រើសចុងក្រោយទេ ព្រោះមានមណ្ឌលខ្លះមានជាប់ទាក់ទងនឹងការរក្សាកុមារនៅក្នុងមណ្ឌលរយៈពេលវែង។ បើទោះបីជាមានកន្លែងថែទាំកុមាររយៈពេលវែងមានចំនួនលើសពីតម្រូវការក៏ដោយ ប៉ុន្តែនៅខ្វះខាតកន្លែងថែទាំដែលមានឯកទេសផ្តល់ការថែទាំរយៈពេលខ្លី។ ក្រសួង ស.អ.យ. និងកម្ពស់ការថែទាំរយៈពេលខ្លីក្នុងករណីដែលអាចធ្វើទៅបាន។ ការផ្លាស់ប្តូរកន្លែងផ្តល់ការថែទាំរយៈពេលវែង ទៅជាកន្លែងផ្តល់ការថែទាំរយៈពេលខ្លីគប្បីយកមកពិចារណាជាជម្រើសមួយ។

## ការឃ្លាំមើល និងការត្រួតពិនិត្យរបស់រដ្ឋាភិបាល៖

មណ្ឌលថែទាំកុមារចំនួន ២១% ពុំមានអនុស្សរណៈនៃការយោគយល់ជាមួយស្ថាប័នរបស់រដ្ឋាភិបាល និង ១២% ពុំបានចុះបញ្ជីជាមួយស្ថាប័នទីភ្នាក់ងាររដ្ឋាភិបាលណាមួយឡើយ។ មណ្ឌលជាច្រើនប្រមូលផ្តុំគ្នានៅក្នុងរាជធានីខេត្តទាំង៩។ ការកំណត់ទីតាំងកន្លែងថែទាំកុមារបានបង្ហាញថាកង្វះការឃ្លាំមើលប្រកបដោយប្រសិទ្ធភាពនៅ ក្នុងខេត្តមួយចំនួនបានបង្ហាញអំពីសេចក្តីត្រូវការឱ្យមាន ធនធានបន្ថែមសម្រាប់ការងារត្រួតពិនិត្យនិងនិយតកម្ម។ អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ គឺជាជំហានមួយដ៏ត្រឹមត្រូវនៅក្នុងទិសដៅនេះ ដែលទាមទារឱ្យមានការបន្តសម្របសម្រួល និងសហប្រតិបត្តិការ រវាងបណ្តាក្រសួងនានា ដើម្បីឱ្យមានការឆ្លើយតបប្រកបដោយភាពសុខដុមចំពោះកុមារដែលស្ថិតនៅក្នុងកន្លែងថែទាំប្រភេទផ្សេងៗគ្នាផងដែរ។

## ការធ្វើសមាហរណកម្មកុមារអាយុចន្លោះពី០ ទៅ ៣ឆ្នាំ៖

នៅក្នុងខេត្តទាំង២០ ដែលមានទិន្នន័យ កុមារអាយុចន្លោះពី ០ ទៅ ៣ឆ្នាំត្រឹមតែ ២% នៃចំនួនកុមារសរុប ក្នុងមណ្ឌលថែទាំកុមារទាំងអស់។
បើទោះជាដូច្នេះក្តី ការស្រាវជ្រាវបង្ហាញឱ្យឃើញថាការរស់នៅក្នុងមណ្ឌល បង្កហានិភ័យកាន់តែខ្លាំងចំពោះកុមារអាយុក្រោម ៣ឆ្នាំ បើធៀបទៅនឹងកុមារដែលមានវ័យច្រើនជាងនេះ[៦]។ ការព្រួយបារម្ភបន្ថែមទៀត គឺថាកុមារគ្រប់រូបនៅក្នុងក្រុមអាយុនេះត្រូវបានរកឃើញថាកំពុងរស់នៅក្នុងកន្លែង ថែទាំរយៈពេលវែង។ចំនុចនេះបានឱ្យដឹងថា ដោយសារតែមិនសូវមានកុមារអាយុចន្លោះពី ០ ទៅ ៣ឆ្នាំ នៅក្នុងមណ្ឌល និង ដោយសារតែកុមារទាំងនោះប្រមូលផ្តុំតែនៅក្នុងបណ្តារាជធានីខេត្តមួយចំនួន ដូច្នេះមានសារៈសំខាន់ក្នុងការកំណត់អាទិភាពទៅលើការធ្វើសមាហរណកម្មពួកគេជាពិសេស អាស្រ័យដោយផលប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរ នៃការថែទាំបែបនេះទៅលើការអភិវឌ្ឍរបស់ពួកគេនៅពេលអនាគត។

# តើទិន្នន័យនឹងត្រូវបានគេប្រើប្រាស់ដោយរបៀបណា?

## ការគ្រប់គ្រងករណី និងអធិការកិច្ច៖

ការកំណត់ទីតាំងកន្លែងថែទាំកុមារផ្តល់នូវទិន្នន័យបឋមមួយដ៏រឹងមាំអំពីមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា ហើយនឹងត្រូវបានយកមកប្រើប្រាស់ សម្រាប់ការគ្រប់គ្រងករណី ដូច្នេះវិធីសាស្ត្រដែលត្រូវបានជ្រើសរើសគឺត្រូវកំណត់រករាល់មណ្ឌលទាំងអស់ និងទីតាំងជាក់លាក់របស់មណ្ឌលទាំងនោះ ដើម្បីបង្កលក្ខណៈឱ្យអាចធ្វើការតាមដានបាន ជាពិសេសមណ្ឌលថែទាំកុមារដែលទើបត្រូវបានកំណត់រកឃើញនាពេលថ្មីៗនឹងត្រូវបានបញ្ចូលទៅក្នុងបញ្ជីអធិការកិច្ចជាទៀងទាត់ប្រចាំឆ្នាំរបស់ក្រសួង ស.អ.យ. នៅពេលអនាគត។

## ការត្រួតពិនិត្យកែសម្រួលគោលនយោបាយ និងកម្មវិធី៖

គំហើញនឹងត្រូវបានយកមកប្រើប្រាស់ ដើម្បីពិនិត្យកែសម្រួលឡើងវិញទៅលើគោលនយោបាយ និងការរៀបចំកម្មវិធីនាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាលទាក់ទងនឹងការធ្វើសមាហរណកម្មកុមារពីមណ្ឌល និង ជាពិសេស សំដៅផ្តោះទៅលើការសម្រេចឱ្យបាននូវគោលដៅធ្វើសមាហ

[៦] Browne Kevin, ហានិភ័យដែលធ្វើឲ្យមានការឈឺចាប់ដល់យុវជនវ័យក្មេងរស់នៅក្នុងមណ្ឌលថែទាំកុមារ និងការសែតស្តីពីការធ្វើឲ្យប្រសើរឡើងនៃបណ្តាញការងារ Save the Children ឆ្នាំ២០០៩ Gudbrandsson, Bragi ស្តីពីសិទ្ធកុមារដែលមានហានិភ័យ និងការរស់នៅក្នុងមណ្ឌលថែទាំ ការរៀបចំនៃសន្និសិទរបស់រដ្ឋមន្ត្រី អ៊ឺរ៉ុប ទទួលមន្ទុកការថែទាំសុខមាលភាពគ្រួសារ នៅ លីប៊ុន ១៦-១៧ ឧសភា ២០០៦

[៧] កម្មវិធីសមាហរណកម្ម៣០% (២០១៦-២០១៨) សំដៅចំពោះកិច្ចសហការរួមគ្នាជាក់លាក់ រវាងក្រសួង ស.អ.យ. និងអង្គការយូនីសេហ្វ ដើម្បីធ្វើសមាហរណកម្មកុមារចំនួន៣០% ពីមណ្ឌលក្នុងរាជធានី-ខេត្តអាទិភាពទាំង៥ (បាត់ដំបង កណ្តាល ភ្នំពេញ ព្រះសីហនុ និង សៀមរាប)។ គោលដៅ ៣០%នេះ ត្រូវបានគណនាផ្អែកលើរបាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ ហើយរដ្ឋាភិបាលនឹងធ្វើការតាមដានករណី និង មណ្ឌលនីមួយៗនៅក្នុងរាជធានីខេត្តទាំងនេះ ដើម្បីវាស់ស្ទង់ទៅលើការប្រែប្រួល។

វណកម្មកុមារចំនួន៣០%ពីមណ្ឌលទៅគ្រួសារនិងសហគមន៍[៧]។
បើនិយាយឱ្យទូលាយទិន្នន័យនេះនឹងត្រូវបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណប្រសិទ្ធភាព នៃការអនុវត្ត អនុក្រឹត្យស្តីពីការ គ្រប់គ្រងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា។

### ទិន្នន័យបឋម និងការវាស់ស្ទង់និន្នាការជាបន្តបន្ទាប់ ៖

ក្រសួង ស.អ.យ. នឹងប្រើប្រាស់គំហើញទិន្នន័យបឋមនេះដើម្បីវាស់ស្ទង់និន្នាការជាបន្តបន្ទាប់ សំដៅឆ្ពោះទៅរកអាទិភាពជារួមនៃការលើកកម្ពស់ការថែទាំតាមគ្រួសារ និងជាពិសេសឆ្ពោះទៅរកគោលដៅធ្វើសមាហរណកម្មកុមារ ចំនួន៣០% ពីមណ្ឌលឱ្យទៅជាការថែទាំតាមគ្រួសារវិញ។

### ការលើកកម្ពស់ និង ការស្វែងរកការគាំទ្រចំពោះការថែទាំតាមគ្រួសារ និងសហគមន៍ ៖

ទិន្នន័យនេះមានផ្តល់ជូនជាសាធារណៈ និងអាចយកមកប្រើប្រាស់ដោយបុគ្គលទាំងឡាយណាដែលមានចំណាប់អារម្មណ៍ ក្នុងការរួមចំណែកសម្រេចឱ្យបាននូវគោលដៅសមាហរណកម្មកុមារចេញពីមណ្ឌលព្រមជាមួយនឹង
ការលើកកម្ពស់ការ ថែទាំតាមគ្រួសារ និងសហគមន៍ក្នុងប្រទេសកម្ពុជា។

## ចន្លោះប្រហោងទិន្នន័យ និង ការស្រាវជ្រាវបន្ថែមទៀត

ដូចដែលបានបញ្ជាក់ពីខាងដើម ការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ បានបង្កើនមូលដ្ឋានចំណេះដឹងបច្ចុប្បន្នអំពីការថែទាំកុមារតាមមណ្ឌលក្នុងប្រទេសកម្ពុជា ក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ ប៉ុន្តែការកំណត់ទីតាំងនេះគ្រាន់តែបានផ្តោតលើចំនួនមណ្ឌលនិង ចំនួនកុមារដែលរស់នៅក្នុងមណ្ឌល និងលក្ខណៈមូលដ្ឋានរបស់មណ្ឌលទាំងនោះតែប៉ុណ្ណោះ។ ការសិក្សានេះមិនបានពិនិត្យទៅលើមូលហេតុនៃការយកកុមារមកដាក់នៅក្នុងមណ្ឌល ឬធ្វើការវិភាគបន្ថែមទៀតទៅលើគំហើញដទៃទៀតឡើយ។ ផ្អែកលើការពិភាក្សាអំពីគំហើញជាមួយអ្នកពាក់ព័ន្ធមួយក្រុមដែល
ត្រូវបានជ្រើសរើស គេបានកំណត់រកឃើញចន្លោះប្រហោងខាងក្រោម ដែលអាចកាត់បន្ថយតាមរយៈការសិក្សាស្រាវជ្រាវបន្ថែមទៀត៖



**ការស្វែងយល់បន្ថែមថាតើកុមារដែលរស់នៅក្នុងមណ្ឌល ភាគច្រើនមកពីខេត្តណាខ្លះ**



**ការវិភាគអំពី ហេតុអ្វីបានជាមានកុមារក្នុងវ័យសិក្សាក្នុងចំនួនច្រើនជាងគេកំពុងត្រូវបានដាក់ចូលទៅក្នុងមណ្ឌលដែលផ្ទុយពីកុមារតូច**



**ការវិភាគទៅលើផលធៀបយេនឌ័រដែលបានសង្កេតឃើញ (កុមារាច្រើនជាងកុមារីកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ និងអន្តេវាសិកដ្ឋាន)**



**ការបំបែកកុមារពិការទៅតាមប្រភេទពិការភាព**




**ការបំបែកឱ្យបានគ្រប់ជ្រុងជ្រោយអំពីលក្ខណៈកុមារដែលកំពុងរស់នៅក្នុងមណ្ឌល (ដូចជា ស្ថានភាពនៃភាពជាកុមារកំព្រា មូលហេតុនៃការមករស់នៅក្នុងមណ្ឌល និងកម្រិតភាពក្រីក្រ)**

# ១. សេចក្តីផ្តើម

ក្រសួង ស.អ.យ. បានកំណត់ទីតាំងកន្លែងថែទាំកុមារជាពីរដំណាក់កាល នៅចន្លោះ ខែវិច្ឆិកា ឆ្នាំ២០១៤ និង ខែធ្នូ ឆ្នាំ២០១៥ ដើម្បីដោះស្រាយបញ្ហាកង្វះព័ត៌មានគ្រប់ជ្រុងជ្រោយអំពីចំនួនកន្លែងដែលផ្តល់ការថែទាំកុមារក្នុងប្រទេសកម្ពុជា។ ព័ត៌មានតែមួយគត់ដែលមានមកទល់នឹងបច្ចុប្បន្ន ផ្អែកលើរបាយការណ៍អធិការកិច្ចដែលក្រសួងបានធ្វើ ព័ត៌មានទាំងនោះមានចំពោះមណ្ឌលដែលគេស្គាល់ជាផ្លូវការឬ មណ្ឌលដែលមានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងប៉ុណ្ណោះ។
គេបានសន្និដ្ឋានថា មានកន្លែងថែទាំកុមារជាច្រើនទៀត ហើយការកំណត់ទីតាំងកន្លែងថែទាំកុមារ គឺជាវិធីមួយប្រកបដោយប្រសិទ្ធភាពក្នុងការកំណត់អត្តសញ្ញាណកន្លែងទាំងនោះ។ ក្រសួង ស.អ.យ. បានធ្វើការកំណត់កន្លែងថែទាំកុមារលើកដំបូងមួយក្នុងរាជធានី-ខេត្តចំនួន ៥ នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៤ នឹងខែកុម្ភៈ ឆ្នាំ២០១៥ ហើយការកំណត់ទីតាំងកន្លែងថែទាំកុមារលើកទី២ទៅលើខេត្តដែលនៅសេសសល់ចំនួន២០ទៀតត្រូវបានធ្វើឡើងនៅចន្លោះខែតុលារហូតដល់ខែធ្នូ ឆ្នាំ២០១៥។

របាយការណ៍នេះត្រូវបានបែងចែកជា៧ផ្នែក ដែលរួមមានជាអាទិ៍៖ សង្ខេប សេចក្តីផ្តើម និងសេចក្តីអធិប្បាយអំពីការកំណត់ទីតាំង សារតានៃការសិក្សាស្រាវជ្រាវវិធីសាស្រ្ត គំហើញពីការសិក្សាស្រាវជ្រាវបែងចែកជាអនុផ្នែកចំនួន៥ទៀត ១. ចំនួន និងប្រភេទកន្លែងថែទាំកុមារ ២. មណ្ឌលថែទាំកុមារ ៣. កុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ ៤.ប្រភេទដទៃទៀតនៃកន្លែងថែទាំកុមារ និងកុមារដែលកំពុងរស់នៅកន្លែងទាំងនោះ ៥. យុវជនវ័យក្មេងដែលកំពុងរស់នៅកន្លែងថែទាំកុមារប្រភេទផ្សេងៗគ្នា សញ្ញាណនៅពេលអនាគតនៃការសិក្សាស្រាវជ្រាវនេះ និងសេចក្តីសន្និដ្ឋាន។

ក្រសួងសូមថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ អាជ្ញាធរ កម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និង កម្មវិធី 3PC[៨] ដែលបានផ្តល់កិច្ចគាំទ្របច្ចេកទេសសម្រាប់ការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ។ ក្រសួង ស.អ.យ. ក៏សូមថ្លែងអំណរគុណផងដែរចំពោះមូលនិធិកុមាររងការជម្លៀស និងកុមារកំព្រារបស់ USAID សម្រាប់ការបន្តផ្តល់វិភាគទានហិរញ្ញវត្ថុ និង ការប្តេជ្ញាចិត្តគាំទ្រដល់ការកែលម្អ ទៅលើការថែទាំកុមារក្នុងប្រទេសកម្ពុជា។

[៨] កម្មវិធីភាពជាដៃគូសម្រាប់កិច្ចការពារកុមារ (3PC) គឺជាកិច្ចសហការមួយរវាងក្រសួង ស.អ.យ. និង អង្គការយូនីសេហ្វ និង អង្គការ Friends-International ។ អង្គការសង្គមស៊ីវិលចំនួន៩ទៀត និង ក្រុមសហគមន៍មូលដ្ឋានចំនួន៥០ ក៏ជាចំណែកមួយនៃកម្មវិធី 3PC ក្រោមឆ័ត្ររបស់អង្គការ Friends-International ផងដែរ។

# ២. សារតា

បើទោះបីជាមានភស្តុតាងវិទ្យាសាស្រ្តបញ្ជាក់ថាការរស់នៅក្នុងមណ្ឌលអាចបង្កគ្រោះថ្នាក់ដល់ការអភិវឌ្ឍផ្នែកសង្គម ផ្លូវកាយ សតិបញ្ញា និង ផ្លូវចិត្តរបស់កុមារ និងមានផលប៉ះពាល់រយៈពេលវែងទៅលើជីវិតរបស់ពួកគេនៅពេលពេញវ័យ រាប់បញ្ចូលទាំងការប្រឈមទៅនឹងកំណើននៃការរំលោភបំពាន និងអំពើហិង្សា[៩] ក៏ដោយ ក៏មណ្ឌលថែទាំកុមារនៅកម្ពុជាបានបន្តរីករាលដាលយ៉ាងពេញទំហឹង។

យោងតាមទិន្នន័យរបស់ក្រសួង[១០] បានឱ្យដឹងថា មណ្ឌលថែទាំកុមារបានក្លាយទៅជារឿងធម្មតាកាន់តែខ្លាំងឡើងជាលំដាប់ ហើយកុមារជាច្រើនត្រូវបានបំបែកពីគ្រួសាររបស់ពួកគេ និងទុកដាក់នៅក្នុងមណ្ឌលដោយមិនចាំបាច់។ មានការកើនឡើង ៧៥%ចំពោះចំនួនមណ្ឌលថែទាំកុមារ នៅចន្លោះឆ្នាំ២០០៥ ទៅ ឆ្នាំ២០១០ ពី១៥៤ ទៅ ២៦៩មណ្ឌល ព្រមជាមួយនឹងកំណើនកុមារនៅក្នុងមណ្ឌលចំនួន ៩១% ពី ៦.២៥៤នាក់ ទៅ ១១.៩៤៥នាក់។ នៅចន្លោះឆ្នាំ២០១០ ទៅ ឆ្នាំ២០១៥ ចំនួនកុមារ និង មណ្ឌល បានធ្លាក់ចុះ បន្តិច ប៉ុន្តែវានៅតែបន្តមានកម្រិតខ្ពស់ដដែល ដោយមានកុមារចំនួន១១.១៧១នាក់(៤៧% ជាកុមារី)។ ក្នុង ឆ្នាំ២០១៥ មានមណ្ឌលថែទាំកុមារចំនួន ២៥៤កន្លែង ក្នុងនោះមណ្ឌលចំនួន២២ ជាមណ្ឌលរដ្ឋ (រូបភាពទី២)។ បើទោះជាដូច្នេះក្តី ទិន្នន័យនេះគ្រាន់តែឆ្លុះបញ្ចាំងអំពីមណ្ឌលដែលបានចុះបញ្ជីជាផ្លូវការជាមួយក្រសួង ស.អ.យ. ប៉ុណ្ណោះ មានន័យថាទំនងនឹងមានកុមារច្រើនជាងនេះទៀតនៅក្នុងមណ្ឌលបែបនេះ។ ដើម្បីយល់បានពេញលេញអំពីវិសាលភាពនៃបញ្ហានេះ គេចាំបាច់ត្រូវធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារដើម្បីរកឱ្យឃើញនូវរាល់មណ្ឌលថែទាំកុមារទាំងអស់នៅក្នុងប្រទេស។

[៩] សូមមើលកំណត់សម្គាល់ចុងទំព័រ ទី១។
[១០] ប្រព័ន្ធទិន្នន័យស្តីពីការថែទាំជំនួសរបស់ក្រសួង ស.អ.យ. (២០០៥-២០១០)។

**រូបភាពទី២៖** ចំនួនមណ្ឌលថែទាំកុមារ និងកុមារដែលនៅក្នុងមណ្ឌលទាំងនោះ (២០០៥-២០១៥)




| | ២០០៥ | ២០១០ | ២០១១ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| (កុមារី) | ២៥៦១ | ៥៣០២ | ៥០៣០ | ៦៨៤៤ | ៥២១៧ | ៥២១៦ |
| (កុមារា) | ៣៦៩៣ | ៦៦៤៣ | ៦០៨២ | ៥៥២៣ | ៦២៣៥ | ៥៩៥៥ |
| (មណ្ឌល) | ១៥៤ | ១៦៩ | ២១៦ | ២២៥ | ២២៨ | ២៥៤ |

ប្រភពឯកសារ៖ របាយការណ៍អធិការកិច្ច ក្រសួង ស.អ.យ. (២០១៦)

ស្របពេលដែលការកំណត់ទីតាំងកន្លែងថែទាំកុមារត្រូវបានចាប់ផ្តើម ការសិក្សាមួយទៀត ដែលមានគោលបំណងស្រដៀងគ្នា(ការប៉ាន់ប្រមាណថ្នាក់ជាតិអំពីចំនួនកុមារនៅក្នុងមណ្ឌលក្នុងប្រទេសកម្ពុជា) ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) និងសាកលវិទ្យាល័យកូឡុំប៊ីក៏ត្រូវបានផ្តួចផ្តើមឡើងផងដែរ។ របាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ ព្រមជាមួយនឹងរបាយការណ៍កំណត់ទីតាំងកន្លែងថែទាំកុមាររបស់ក្រសួង ស.អ.យ. ក្នុងរាជធានីខេត្តទាំង៥ ដែលធ្វើឡើងក្នុងខែមីនា ឆ្នាំ ២០១៦។ ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ បានធ្វើការប៉ាន់ប្រមាណថា មានកុមារចំនួន ៤៨.៧៧៥នាក់ កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារប្រមាណ ១.៦៥៨ កន្លែងនៅកម្ពុជា។

បើទោះបីជាការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស.អ.យ. បំពេញបាននូវចន្លោះប្រហោងព័ត៌មានមួយដ៏សំខាន់ក៏ដោយ ប៉ុន្តែគំហើញរបស់ពួកគេមានភាពខុសគ្នា។ ភាពខុសគ្នាចំពោះនិយមន័យនៃពាក្យថាមណ្ឌលថែទាំកុមារ និងភាពខុសគ្នានៃវិធីសាស្ត្ររបស់ពួកគេ បាននាំឱ្យទទួលបានលទ្ធផលខុសគ្នា។ ក្រសួងបានប្រើប្រាស់អភិក្រមកំណត់ទីតាំងមួយ ដើម្បីធ្វើការអង្កេតទៅលើមណ្ឌលទាំងអស់ (សូមមើលផ្នែកដែលនិយាយអំពីវិធីសាស្ត្រ) ដោយឡែក ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ គឺជាការប៉ាន់ប្រមាណផ្អែកលើទិន្នន័យដែលប្រមូលបាន ពីសំណាកទីតាំងដែលត្រូវបានជ្រើសរើសដោយចៃដន្យ (ទិន្នន័យត្រូវបានប្រមូលនៅថ្នាក់ឃុំសង្កាត់ ពីទីតាំងដែលបានជ្រើសរើសទាំង២៤ នៅក្នុងខេត្តដែលត្រូវបានជ្រើសរើសចំនួន១១)។ លើសពីនេះទៀត និយមន័យនៃពាក្យថាមណ្ឌលថែទាំកុមារដែលវិទ្យាស្ថានជាតិស្ថិតិបានប្រើប្រាស់ មានភាពទូលំទូលាយជាងនិយមន័យដែលក្រសួង ស.អ.យ. បានប្រើប្រាស់ ដែលមានភាពស្របគ្នាយ៉ាងខ្លាំងទៅនឹងនិយមន័យដែលប្រើប្រាស់នៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី មានគំហើញមួយចំនួនដែលមានលក្ខណៈដូចគ្នា៖ ការសិក្សាទាំងពីរនេះ បង្ហាញឱ្យឃើញថាមានកុមារាច្រើនជាងកុមារី រស់នៅក្នុងមណ្ឌល(ក្រសួង ស.អ.យ.៖ ៥៣% ជាកុមារា ហើយរបាយការណ៍ របស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញថាកុមារា មានចំនួន ៥៧%)។ ទិន្នន័យនេះក៏ទទួលបានការបញ្ជាក់ ពីរបាយការណ៍អធិការកិច្ចផងដែរ។ ដូចមានបង្ហាញនៅក្នុងរូបភាពទី២ ចំនួនកុមារានៅក្នុងមណ្ឌល បន្តមានអត្រាខ្ពស់ជាងចំនួនកុមារីក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ (លើកលែងតែឆ្នាំ២០១៣)។ ស្រដៀងគ្នានេះដែរការសិក្សាទាំងពីរនេះ បានរកឃើញ ថាកុមារភាគច្រើនលើសលប់ ស្ថិតក្នុងវ័យចូលរៀន។

ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ បានរកឃើញថាកុមារជាងពាក់កណ្តាលនៃចំនួនកុមារសរុបមានអាយុចន្លោះពី ១៣-១៧ឆ្នាំ។ ទន្ទឹមនឹងនេះ ការកំណត់ទីតាំងកន្លែងថែទាំកុមារ បានរកឃើញថាកុមារចំនួន ៦៧% ដែលរស់នៅក្នុងមណ្ឌលក្នុងខេត្តទាំង២០ មានអាយុចន្លោះពី ១១ ទៅ ១៧ឆ្នាំ (សូមមើលតារាងទី១)។

# ២. សារតា

**តារាងទី១៖** អាយុរបស់កុមារនៅតាមកន្លែងថែទាំកុមារ

| ការកំណត់ទីតាំងកន្លែងថែទាំកុមា* | | |
|---|---|---|
| ២% | ៣២% | ៦៧% |
| ០-៣ ឆ្នាំ | ៤-១០ ឆ្នាំ | ១១-១៧ ឆ្នាំ |

| ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ | | | |
|---|---|---|---|
| ៤% | ១៤% | ៣១% | ៥១% |
| <៥ ឆ្នាំ | ៥ ទៅ <៩ ឆ្នាំ | ៩ ទៅ <១៣ ឆ្នាំ | ១៣ ទៅ <១៨ ឆ្នាំ |

* មានទិន្នន័យសម្រាប់តែខេត្តចំនួន២០ប៉ុណ្ណោះ។ តួលេខនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតួលេខសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។

ការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ ក៏ផ្តល់នូវព័ត៌មានបន្ថែមមួយចំនួនផងដែរ។ ការសិក្សានេះ បានបញ្ជាក់ថា កុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា ពុំមែនសុទ្ធតែជាកុមារកំព្រាឡើយ ប៉ុន្តែយ៉ាងហោចណាស់ពួកគេមានឪពុក ឬម្តាយម្នាក់ដែលនៅរស់នៅឡើយ ដោយកុមារអាយុចន្លោះពី ១៣ឆ្នាំ ទៅ ១៧ឆ្នាំ ប្រមាណ ៧៩% ឬ កុមារ ៤នាក់ ក្នុងចំណោម ៥នាក់ ដែលរស់នៅក្នុងមណ្ឌល ត្រូវបានរាយការណ៍យ៉ាងហោចណាស់ពួកគេមានឪពុក ឬ ម្តាយម្នាក់ដែលនៅរស់។ ព័ត៌មាននេះមានសង្គតិភាពទៅនឹងរបាយការណ៍អធិការកិច្ចឆ្នាំ២០១៣ ដែលបានរាយការណ៍ឱ្យដឹងថា យ៉ាងហោចណាស់ កុមារចំនួន ៧៧% នៅក្នុងមណ្ឌល ថែទាំកុមារមានឪពុក ឬ ម្តាយម្នាក់ដែលនៅរស់។ ការសិក្សាស្រាវជ្រាវរបស់វិទ្យាស្ថានជាតិស្ថិតិ ក៏បានរាយការណ៍ផងដែរថា ក្នុងចំណោមកុមារ ដែលយ៉ាងហោចណាស់មានឪពុក ឬម្តាយម្នាក់ដែលនៅរស់ មានកុមារស្ទើរតែពាក់កណ្តាលបានរាយការណ៍ថា ឪពុកម្តាយរបស់ពួកគេរស់នៅក្នុងខេត្តតែមួយជាមួយនឹងមណ្ឌលដែរ។ ដើម្បីទទួលបានរូបភាពទាំងស្រុង នៃមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា គប្បីអាន់របាយការណ៍ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារ រួមគ្នាជាមួយនឹងការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ[១១]។

ពុំមានការសិក្សាស៊ីជម្រៅទូលំទូលាយអំពីមូលហេតុនៃការយកកុមារទៅដាក់ក្នុងមណ្ឌលឡើយ។ របាយការណ៍ដែលមាន បានឱ្យដឹងថា បើទោះបីជាភាពក្រីក្រ និងការអប់រំគឺជាកត្តាចម្បងក៏ដោយ ប៉ុន្តែ ពុំមែនគ្រប់គ្រួសារក្រីក្រទាំងអស់បញ្ជូនកូនរបស់ពួកគេទៅមណ្ឌលឡើយ និងមានកត្តាបន្ថែមទៀត ដែលជំរុញឱ្យគ្រួសារងាយរងគ្រោះយកកូនរបស់ពួកគេទៅដាក់នៅក្នុងមណ្ឌលថែទាំកុមារ។

ឧទាហរណ៍ របាយការណ៍ពីការសិក្សារបស់វិទ្យាស្ថានជាតិស្ថិតិ បានរាយការណ៍ឱ្យដឹងថា កុមារអាយុចន្លោះពី ១៣ឆ្នាំ ទៅ ១៧ឆ្នាំ ចំនួន៧៥% បានរៀបរាប់ថាការគេចពីភាពក្រីក្រ ឬឱកាសទទួលបានការអប់រំ គឺជាមូលហេតុចម្បងនៃការចូលមករស់នៅក្នុងមណ្ឌល។ ស្រដៀងគ្នានេះដែរ ការសិក្សាមួយរបស់អង្គការយូនីសេហ្វ ក្នុងឆ្នាំ ២០១១ បានរាយការណ៍ឱ្យដឹងថា គ្រប់គ្រួសារទាំងអស់ដែលមានកូនរស់នៅក្នុងមណ្ឌល បាននិយាយថាភាពក្រីក្របានរួមចំណែកធ្វើឱ្យពួកគេសម្រេចចិត្តយកកូនរបស់ពួកគេទៅដាក់នៅក្នុងមណ្ឌលថែទាំកុមារ[១២]។ បើទោះជាដូច្នេះក្តី របាយការណ៍ដដែលរបស់អង្គការយូនីសេហ្វ បានរកឃើញថាមិនមែនគ្រប់គ្រួសារក្រីក្រទាំងអស់បញ្ជូនកូនរបស់ពួកគេទៅមណ្ឌលថែទាំកុមារឡើយ និងមានកត្តាមួយចំនួនទៀត ដូចជា មរណភាពរបស់ឪពុក ឬម្តាយ ឪពុកម្តាយលែងលះគ្នា ឪពុកម្តាយបែកផ្លូវរៀបការជាមួយអ្នកផ្សេង ការប្រើប្រាស់បំពានគ្រឿងស្រវឹង កូនម្នាក់ស្លាប់ មានជម្ងឺ មានកូនច្រើនចំណាកស្រុក និងកង្វះសេវាសុខុមាលភាពសង្គមក្នុងមូលដ្ឋានបានរួមចំណែកធ្វើឱ្យមានការកើនឡើងនូវភាពងាយរងគ្រោះ និងការយកកុមារទៅដាក់ឱ្យរស់នៅក្នុងមណ្ឌល។ របាយការណ៍បានសរសេរបន្ថែមទៀតថា កត្តាសម្រេចដទៃទៀត រួមមានការស្គាល់នរណាម្នាក់នៅក្នុងមណ្ឌល ឬការលឺគេនិយាយអំពីមណ្ឌល ព្រមជាមួយនឹងថាតើគ្រួសារងាយរងគ្រោះមានលទ្ធភាពទទួលបានទម្រង់នៃកិច្ចគាំទ្រផ្សេងៗគ្នានៅក្នុងសហគមន៍ ដើម្បីអនុញ្ញាតឱ្យពួកគេរក្សាកូននៅឯផ្ទះ ដែរឬទេ។

កំណើនដ៏ឆាប់រហ័សចំពោះការទុកដាក់កុមារនៅក្នុងមណ្ឌល គឺផ្ទុយពីគោលនយោបាយរបស់រដ្ឋាភិបាលដែលចែងថា ការថែទាំតាមគ្រួសារ និងសហគមន៍ គឺជាជម្រើសប្រសើរបំផុតសម្រាប់ការថែទាំជំនួសចំពោះកុមារ ហើយការថែទាំតាមមណ្ឌលគប្បីជាជម្រើសចុងក្រោយ និងបណ្តោះអាសន្ន ហើយតួនាទីបឋមក្នុងការការពារ និងថែទាំកុមារ គឺជាតួនាទីរបស់គ្រួសារពួកគេ។ ចំណុចនេះមានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦ និង បទដ្ឋាន

[១១] វិទ្យាស្ថានជាតិស្ថិតិ និង សាកលវិទ្យាល័យកូឡុំបៀ "ការប៉ាន់ប្រមាណថ្នាក់ជាតិស្តីពីកុមារអនាថាក្នុងប្រទេសកម្ពុជា" ឆ្នាំ២០១៥។

[១២] អង្គការយូនីសេហ្វ "ដោយបំណងល្អបំផុត ៖ ការសិក្សាស្តីពីឥរិយាបថចំពោះការថែទាំតាមមណ្ឌលក្នុងប្រទេសកម្ពុជា" អង្គការយូនីសេហ្វ ភ្នំពេញ ២០១១។

អប្បបរមាស្តីពីការថែទាំជំនួសចំពោះ កុមារឆ្នាំ២០០៨
ដែលផ្តល់ក្របខ័ណ្ឌគតិយុត្ត និងសេចក្តីណែនាំមួយ
ស្តីពីការថែទាំជំនួសចំពោះកុមារក្នុងប្រទេសកម្ពុជា។

ថ្វីត្បិតតែរដ្ឋាភិបាលមានជំហររឹងមាំប្រឆាំងនឹងការថែទាំ
តាមមណ្ឌលក៏ដោយ ប៉ុន្តែ បើគ្មានការគ្រប់គ្រង
ឱ្យបានគ្រប់គ្រាន់ទេនោះ ចំនួនកន្លែងថែទាំកុមារនឹងបន្ត
កើនឡើងជារៀងរាល់ឆ្នាំ។

កំណើននៃមណ្ឌលថែទាំកុមារ ក៏បណ្តាលមកពីតែកម្រិត
នៃកិច្ចគាំទ្រពីម្ចាស់ជំនួយក្រៅប្រទេស ដែលមាន
ចេតនាប្រសើរបំផុតក្នុងការផ្តល់កិច្ចគាំទ្រ និងមូលនិធិ
ឧបត្ថម្ភដល់កុមារនៅក្នុងមណ្ឌល ("មណ្ឌលកុមារកំព្រា")
ដោយមិនបានដឹងអំពីជម្រើសថែទាំជំនួស
កុមារតាមគ្រួសារ និងសហគមន៍ផងដែរ។
បើទោះបីជាកន្លែងថែទាំកុមារ មួយចំនួនគ្រប់គ្រងដំណើ
រការដោយរដ្ឋក៏ដោយ ប៉ុន្តែកន្លែងថែទាំកុមារភាគច្រើន
គ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ឯកជន ឬ
អង្គការសាសនា ហើយកន្លែងថែទាំកុមារស្ទើរតែទាំង
អស់ទទួលបានការឧបត្ថម្ភពីបុគ្គលនៅក្រៅប្រទេស។
ជាលទ្ធផល មណ្ឌលជាច្រើនបានប្រែក្លាយជាមណ្ឌល
ទេសចរណ៍កុមារកំព្រា ដើម្បីទាក់ទាញម្ចាស់ជំនួយ
បន្ថែមទៀត ដែលជាហេតុនាំឱ្យមានប្រព័ន្ធមួយដែលជា
ហេតុនាំមកនូវប្រព័ន្ធមួយដែលធ្វើអោយកុមារមានការ
ប្រឈមនឹងគ្រោះថ្នាក់។

បទពិសោធន៍នៅក្នុងវិស័យថែទាំកុមារ ពុំមែនជាលក្ខខណ្ឌ
តម្រូវផ្លូវការ ហើយក៏មិនមែនជាលក្ខខណ្ឌតម្រូវក្រោម
បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារដែរ។

ចាប់តាំងពីឆ្នាំ២០០៦ ក្រសួង ស.អ.យ. បានពង្រឹង
ក្របខ័ណ្ឌស្តីពីការថែទាំជំនួសចំពោះកុមារដើម្បីលើកក
ម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ និង
គ្រប់គ្រងឱ្យបានកាន់តែប្រសើរទៅលើការថែទាំជំនួស
គ្រប់ទម្រង់ទាំងអស់។
បើទោះបីជាមានកិច្ចខិតខំយ៉ាងនេះក៏ដោយ
ក្រសួងគ្រាន់តែអាចធ្វើការផ្ទៀងផ្ទាត់ជាមួយភាព
អនុលោមទៅនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស
ចំពោះកុមារសម្រាប់តែ កន្លែងថែទាំកុមារមួយចំនួន
តូចប៉ុណ្ណោះ ជាពិសេសគឺមណ្ឌលថែទាំកុមារដែលមាន
អនុស្សរណៈនៃការយោគយល់ជាមួយក្រសួង។ បច្ចុប្បន្ន
មានកុមារ ជាច្រើនកំពុងរស់នៅក្រោមការផ្តល់សេវា
ដែលស្ថិតនៅក្រៅបទដ្ឋាននៃការថែទាំរបស់ក្រសួង
ស.អ.យ. ដែលមានន័យថា ពួកគេពុំមែនជាកម្មវត្ថុនៃកា
រត្រួតពិនិត្យរបស់រដ្ឋាភិបាល ដើម្បីធានាថាពួកគេទទួល
បានសេវាប្រកបដោយគុណភាពឡើយ។ ក្រសួង
ស.អ.យ. រួមជាមួយនឹងអង្គការយូនីសេហ្វ និងកម្មវិធី
3PC បានផ្តោតការយកចិត្តទុកដាក់ដើម្បីឆ្លើយតបទៅនឹង
កម្មវិធីរបស់ខ្លួននៅក្នុងរាជធានី-ខេត្តអាទិភាព ចំនួន៥
(ភ្នំពេញ សៀមរាប បាត់ដំបង កណ្តាល និងព្រះសីហនុ)
អាស្រ័យដោយរាជធានី-ខេត្តទាំងនេះ ត្រូវបានរក
ឃើញថាមានចំនួនកុមាររស់នៅក្នុងមណ្ឌលច្រើន។

ការអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំ
កុមារ បានតម្រូវឱ្យរាល់កន្លែងថែទាំកុមារទាំងអស់ដែល
មិនមែនជារបស់រដ្ឋ (មណ្ឌលដែលគ្រប់គ្រងដំណើរការ
ដោយអង្គការមិនមែនរដ្ឋាភិបាល មណ្ឌលសាសនា
កន្លែងថែទាំកុមារប្រភេទដទៃទៀត) ត្រូវចុះបញ្ជីដើម្បីធ្វើ
ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។ មិនមែនគ្រប់មណ្ឌល
ទាំងអស់សុទ្ធសឹងតែបានធ្វើបែបនេះជាមួយក្រសួង
ដូចគ្នាតែមួយឡើយ ដែលជាហេតុធ្វើឱ្យការគ្រប់គ្រងមិន
បានគ្រប់ជ្រុងជ្រោយ និងការអនុវត្តបទដ្ឋានអប្បបរមា
មានការលំបាក ដោយសារតែតួនាទីរវាងបណ្តាក្រសួង
នានាមិនច្បាស់លាស់។ បទប្បញ្ញត្តិ និងលក្ខខណ្ឌ
តម្រូវចំពោះការបើកមណ្ឌលថែទាំកុមារក៏មានភាពមិន
ច្បាស់លាស់ផងដែរ។ បើទោះជាដូច្នេះក្តី
នៅក្នុងវឌ្ឍនភាព
ចម្បងមួយនៃកំណែទម្រង់គោលនយោបាយដ៏សំខាន់
និងសេចក្តីថ្លែងការណ៍ប្តេជ្ញាចិត្តដែលអមមកជាមួយ
អនុក្រឹត្យស្តីពីការ គ្រប់គ្រងមណ្ឌលថែទាំកុមារ ត្រូវបាន
ប្រកាសផ្សព្វផ្សាយក្នុងឆ្នាំ២០១៥ ដោយផ្តល់យន្តការ
ច្បាស់លាស់មួយ ដើម្បីត្រួតពិនិត្យទៅលើមណ្ឌលថែទាំ
កុមារ និងការការពារកុមារពីការបំបែកពីគ្រួសារដោយ
មិនចាំបាច់។ អ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះទៀត
អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារបានកំណត់
ថាក្រសួង ស.អ.យ. គឺជាអាជ្ញាធរតែមួយគត់ ដែលមាន
តួនាទីគ្រប់គ្រងកន្លែងថែទាំកុមារទាំងអស់ (រាប់បញ្ចូល
កន្លែងថែទាំកុមារដែលមានកិច្ចព្រមព្រៀងជាមួយក្រសួង
ដទៃផងដែរ)។ សេចក្តីថ្លែងការណ៍ និងការប្តេជ្ញាចិត្ត
បានគូសបញ្ជាក់អំពីអាទិភាពសំខាន់ៗទាក់ទងនឹងការ
ថែទាំកុមារតាមមណ្ឌល ក្នុងនោះរួមមាន
ការធ្វើសមាហរណ-
កម្មកុមារ ចំនួន៣០% ពីមណ្ឌលឱ្យទៅរស់នៅជាមួយ
គ្រួសាររបស់ពួកគេវិញ ឬការថែទាំតាម គ្រួសារ ដើម្បី
សម្រេចមិនទទួលយកការដាក់ពាក្យសុំបើកមណ្ឌល
ថ្មី រហូតដល់ពេលដែលមណ្ឌលដែលមានស្រាប់ទាំងអស់
ត្រូវបានប៉ាន់ប្រមាណរួចរាល់ និងដំណើរការរៀបចំ
ផែនការដើម្បីកំណត់ថាតើត្រូវការឱ្យមានមណ្ឌលថែទាំ
កុមារចំនួនប៉ុន្មានទូទាំងប្រទេស សកម្មភាពនេះគួរត្រូវ
សម្រេចអោយបាននៅត្រឹមដំណាច់ឆ្នាំ២០១៦។ ក្រសួង
ស.អ.យ. នឹងបង្កើតឱ្យមានយន្តការត្រួតពិនិត្យមួយ
ដើម្បីគ្រប់គ្រងទៅលើសំណើទុកដាក់កុមារនៅក្នុងមណ្ឌល
ដោយមិនចាំបាច់ និងដូចមានចែងនៅក្នុងការប្តេជ្ញាចិត្ត
ថា ចាប់ពីដើមឆ្នាំ២០១៦តទៅ ពុំមានកុមារណាម្នាក់
ត្រូវបានបញ្ចូលឱ្យរស់នៅក្នុងមណ្ឌលអង្គការដោយគ្មាន

# ២. សារតា

ការអនុញ្ញាតជាផ្លូវការពីក្រសួង ស.អ.យ. ឡើយ។ កុមារនឹងមិនត្រូវបានយកទៅទុកដាក់នៅក្នុងមណ្ឌលឡើយ ប្រសិនបើមិនទាន់បានពិនិត្យអស់លទ្ធភាពទៅលើជម្រើសថែទាំជំនួសនានា ជាពិសេសចំពោះករណីកុមារអាយុក្រោម៣ឆ្នាំ។ ក្រសួង ស.អ.យ. នឹងបង្កើតឱ្យមានក្រុមឆ្លើយតបរហ័សមួយ ដើម្បីដោះស្រាយសេចក្ដីរាយការណ៍អំពីការរំលោភបំពាន និងភាពមិនប្រក្រតីនានានៅក្នុងមណ្ឌលថែទាំកុមារ។ ក្រុមការងារនេះនឹងធ្វើការឆ្លើយតបក្នុងរយៈពេល៤៨ម៉ោង ក្រោយពេលទទួលបានសេចក្ដីរាយការណ៍អំពីករណីរំលោភបំពាន ឬភាពមិនប្រក្រតី[១៣]។

ដើម្បីអនុវត្តអនុក្រឹត្យនេះប្រកបដោយប្រសិទ្ធភាពការប្រមូលទិន្នន័យអំពីកន្លែងថែទាំកុមារក្នុងប្រទេសកម្ពុជាឱ្យបានសុក្រឹត្យ ត្រូវបានគេយល់ឃើញថាជាជំហានមួយដ៏សំខាន់។ ដូច្នេះ ក្រសួងបានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ ដែលមិនមានលក្ខណៈជាការថែទាំតាមគ្រួសារ ដោយរាប់បញ្ចូលកន្លែងថែទាំកុមារដែលមិនបានចុះបញ្ជី និងមិនបានធ្វើអធិការកិច្ចផងដែរ។ ក្រសួង ស.អ.យ. នឹងប្រើប្រាស់ទិន្នន័យនេះដើម្បីគ្រប់គ្រងករណី និងធ្វើជាទិន្នន័យបឋមក្នុងការវាស់ស្ទង់ផលប៉ះពាល់នៃកម្មវិធីរបស់ខ្លួន។

បន្ថែមពីនេះទៀត ក្នុងខែកញ្ញា ឆ្នាំ២០១៥ FCF ដែលជាការផ្តួចផ្តើមមួយដែលទទួលបានការគាំទ្រពី USAID ត្រូវបានប្រកាសផ្សព្វផ្សាយឱ្យមានដំណើរការ។ កម្មវិធីនេះមានគោលបំណងបង្ការការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ និងបង្កលក្ខណៈឱ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់គ្រួសារ អាចត្រូវបានទុកដាក់នៅក្នុងការថែទាំដោយគ្រួសារសមស្រប។ គេរំពឹងថាការផ្តួចផ្តើមនេះក៏នឹងប្រើប្រាស់របាយការណ៍នេះផងដែរ ដើម្បីដោះស្រាយបញ្ហាវិស័យថែទាំតាមមណ្ឌលដែលកំពុងមានការកើនឡើង យ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា។

បន្ថែមពីនេះទៀត យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងសេចក្ដីថ្លែងការណ៍ប្ដេជ្ញាចិត្តរបស់ក្រសួង ស.អ.យ. សម្រាប់ការអនុវត្តរបស់ខ្លួន តម្រូវឱ្យគ្រប់មណ្ឌលថែទាំកុមារទាំងអស់ ផ្តល់ទម្រង់ជូនដំណឹងមួយដែលបានបំពេញគ្រប់ជ្រុងជ្រោយទៅឱ្យក្រសួង ស.អ.យ. ត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៦ ព្រមជាមួយនឹងព័ត៌មានមូលដ្ឋានអំពីសារតាផងដែរ។ ដោយមានកិច្ចគាំទ្រពីអង្គការយូនីសេហ្វ ក្រសួង ស.អ.យ. បាននិងកំពុងធ្វើការពិនិត្យផ្ទៀងផ្ទាត់បញ្ជីទម្រង់ដែលបានផ្តល់ជូន ធៀបនឹងរបាយការណ៍ ស្ដីពីការកំណត់ទីតាំងមណ្ឌលដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីចន្លោះប្រហោងនានានិងតាមដានកន្លែងថែទាំកុមារទាំងឡាយណាដែលមិនទាន់បានដាក់ជូននូវឯកសារការងារដែលចាំបាច់។ ទម្រង់ជូនដំណឹងផ្តល់នូវទិន្នន័យសំខាន់ៗអំពីចំនួន និងប្រភេទមណ្ឌល ព្រមទាំងកុមារដែលរស់នៅក្នុងនោះ ដោយរាប់បញ្ចូលទាំងស្ថានភាពជាកុមារពិការ និងកុមារកំព្រា ព្រមទាំងធ្វើការបែងចែកទៅតាមភេទ និងអាយុរបស់កុមារផងដែរ។ អាស្រ័យដោយវាគឺជាលក្ខខណ្ឌតម្រូវផ្លូវច្បាប់ សម្រាប់អ្នកផ្តល់សេវាថែទាំកុមារក្នុងការបំពេញដំណើរការជូនដំណឹង ដើម្បីឱ្យមានភាពសមស្របសម្រាប់ការចុះបញ្ជី និងការប៉ាន់ប្រមាណជាផ្លូវការ ដូច្នេះវាទំនងនឹងអាចបំពេញចន្លោះប្រហោងព័ត៌មានដែលខ្វះខាតបន្ថែមទៀត អំពីមណ្ឌលថែទាំកុមារនៅកម្ពុជា។

[១៣] មាត្រា ១៤ នៃការប្ដេជ្ញាចិត្តរបស់ក្រសួង ស.អ.យ. សម្រាប់ការអនុវត្តអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (២០១៥)។

# ៣. វិធីសាស្ត្រ

វិធីសាស្ត្រគឺជាធាតុផ្សំមួយដែលការកំណត់អត្តសញ្ញាណនៃកន្លែងថែទាំកុមារទាំងអស់ ដែលពុំមានលក្ខណៈជាការថែទាំតាមគ្រួសារក្នុងប្រទេសកម្ពុជា។ គ្រប់រាជធានី-ខេត្ត ទាំងអស់នៅកម្ពុជាត្រូវបានកំណត់ទីតាំងកន្លែងថែទាំកុមារ។ កន្លែងថែទាំកុមារដែលត្រូវបានពិចារណា រួមមានមណ្ឌលថែទាំកុមារ ផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្ន ផ្ទះស្នាក់នៅជាក្រុម ការថែទាំតាមវត្តអារាម និងអគារសាសនាដទៃទៀត ព្រមទាំងអន្តេវាសិកដ្ឋាន។ កន្លែងថែទាំកុមារដែលពុំមានបុគ្គលិកបម្រើការងារដែលទទួលបានបៀវត្សរ៍ មិនត្រូវបានរាប់បញ្ចូលឡើយ អាស្រ័យដោយកន្លែងទាំងនេះមិនស្ថិតនៅក្រោមនិយមន័យនៃកន្លែងថែទាំកុមារ។ សូមមើលនិយមន័យនៃកន្លែងថែទាំកុមារទាំងនេះ នៅទំព័រ ៦។

ព័ត៌មានត្រូវបានប្រមូលដោយផ្អែកលើចំណេះដឹងរបស់អ្នកផ្តល់ព័ត៌មានសំខាន់ និងការចុះពិនិត្យកន្លែងថែទាំកុមារដោយផ្ទាល់។ អ្នកផ្តល់ព័ត៌មានសំខាន់ៗ រួមមានមេឃុំ មេភូមិ និងសមាជិកគណៈកម្មាធិការ ទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ដែលបានកំណត់កន្លែងថែទាំកុមារដែលពុំមានលក្ខណៈជាការថែទាំតាមគ្រួសារ។ ពួកគេត្រូវបានជ្រើសរើសដោយផ្អែកលើចំណេះដឹងផ្ទាល់ខ្លួនអំពីភូមិឃុំ និងដោយសារតែពួកគេគឺជាផ្នែកមួយនៃរដ្ឋាភិបាលថ្នាក់ក្រោមបង្អស់ដែល

ស្ថិតនៅក្បែរសហគមន៍មូលដ្ឋានបំផុត។ អ្នកប្រមូលទិន្នន័យ បានចុះត្រួតពិនិត្យនៅតាមឃុំសង្កាត់នីមួយៗ និងបានពិគ្រោះយោបល់ជាមួយអ្នក ផ្ដល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់រកកន្លែងថែទាំកុមារដែលមានស្រាប់ មុនពេលចុះពិនិត្យមណ្ឌលដែលបានកំណត់រកឃើញដោយផ្ទាល់ ដើម្បីទទួលបានព័ត៌មានស៊ីជម្រៅ។ របាយការណ៍អធិការកិច្ចរបស់ក្រសួង ស.អ.យ.ក៏ត្រូវបានយកពិនិត្យឡើងវិញផងដែរ ដើម្បីធានាថារាល់មណ្ឌលដែលត្រូវបានធ្វើអធិការកិច្ចទាំងអស់ត្រូវបានរាប់បញ្ចូលក្នុងអំឡុងពេលនៃការកំណត់ទីតាំងមណ្ឌលកុមារ។

## វិធីសាស្ត្រប្រមូលទិន្នន័យ

អ្នកប្រមូលទិន្នន័យ បានធ្វើសម្ភាសន៍ប្រធាន ឬបុគ្គលសមស្របដែលទទួលបន្ទុកកន្លែងថែទាំកុមារ និងបំពេញនៅក្នុងទម្រង់ឯកសារដែលបានរៀបចំទុកជាមុនសាកល្បងរួច នឹងដែលមានការកែសម្រួលឡើងវិញក្រោយពេលសាកល្បង។

## ការប្រមូលទិន្នន័យដែលមានចំនួន ២លើក

ក្រសួងបានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារជាពីរដំណាក់កាល។ លើកទី១ បានធ្វើការកំណត់នៅរាជធានីខេត្ត អាទិភាពចំនួន៥ ដែលរួមមាន ភ្នំពេញ សៀមរាប បាត់ដំបង កណ្ដាល និងព្រះសីហនុ ដែលទិន្នន័យនេះត្រូវបានប្រមូលនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៤ និង ខែកុម្ភៈ ឆ្នាំ២០១៥ ហើយខេត្តដែលនៅសេសសល់ចំនួន ២០ ទៀត ត្រូវបានធ្វើជាលើកទី២ នៅចន្លោះខែតុលា រហូតដល់ខែធ្នូ ឆ្នាំ២០១៥។

## ការប្រមូលទិន្នន័យ ការបណ្ដុះបណ្ដាល និងការត្រួតពិនិត្យ

អ្នកប្រមូលទិន្នន័យ គឺជាមន្ត្រីនៃការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក។ ពួកគេទទួលខុសត្រូវប្រមូលព័ត៌មានពីស្រុករបស់ពួកគេផ្សេងៗគ្នា។ សរុបមកមានមន្ត្រីចំនួន១៩៥នាក់ ដែលត្រូវបានតែងតាំងឱ្យធ្វើជាអ្នកប្រមូលទិន្នន័យ ដោយយ៉ាងហោចណាស់មានបុគ្គលិក១រូប ពីស្រុកនីមួយៗ។ អ្នកប្រមូលទិន្នន័យគ្រប់រូប តម្រូវឱ្យផ្ដល់ទម្រង់បញ្ជាក់មួយដែលចុះហត្ថលេខាដោយមេឃុំ/ចៅសង្កាត់ ដោយមានប្រថាប់ត្រាឃុំផងដែរ ដើម្បីបញ្ជាក់ថាពួកគេបានពិគ្រោះយោបល់ជាមួយមេឃុំ/ចៅសង្កាត់ និងបានចុះត្រួតពិនិត្យកន្លែងថែទាំកុមារដែលបានរាយការណ៍ជាមុន។

បុគ្គលិករបស់ក្រសួង ស.អ.យ. អង្គការមិនមែនរដ្ឋាភិបាល ដែលជាដៃគូរបស់កម្មវិធី 3PC និងអង្គការយូនីសេហ្វ បានរួមគ្នាផ្ដល់វគ្គបណ្ដុះបណ្ដាលដែលមានរយៈពេល៣ថ្ងៃ សម្រាប់អ្នកប្រមូលទិន្នន័យ និងអ្នកត្រួតពិនិត្យ។ វគ្គបណ្ដុះបណ្ដាលបានផ្ដោតទៅលើប្រធានបទមួយចំនួនដូចជា ការពន្យល់អំពីប្រភេទកន្លែងថែទាំកុមារ និងជំនាញ ធ្វើសម្ភាសន៍ ការអនុវត្ត វិធានសង្កេត និងការបញ្ចូលទិន្នន័យ។ អ្នកប្រមូលទិន្នន័យស្ថិតក្រោមការត្រួតពិនិត្យរបស់ជនបង្គោលថ្នាក់ខេត្ត ដែលមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅថ្នាក់ក្រោមជាតិ និងក្រុមអធិការកិច្ចមកពីនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួង ស.អ.យ. ដែលបានបន្តផ្ដល់កិច្ចគាំទ្រក្នុងអំឡុងពេលប្រមូលទិន្នន័យ។ បុគ្គលិករបស់អង្គការដៃគូក្នុងរាជធានីខេត្តអាទិភាពទាំង៥ បានផ្ដល់កិច្ចគាំទ្របន្ថែម។

## ការបញ្ចូល និងការផ្ទៀងផ្ទាត់ទិន្នន័យ

ក្រោយពេលប្រមូលទិន្នន័យ ទម្រង់ដែលបានបំពេញរួចរាល់ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយ ជនបង្គោលថ្នាក់ខេត្ត ដែលជាអ្នកបញ្ជូនទម្រង់នេះទៅឱ្យអ្នកប្រមូលទិន្នន័យដើម្បីធ្វើការកែតម្រូវវិញ ក្នុងករណីដែលមានកំហុស និងចន្លោះប្រហោងនានា។ ក្រោយមក ទម្រង់ទាំងនេះត្រូវបានបញ្ជូនទៅមន្ត្រីក្រសួង ដែលជាអ្នកពិនិត្យទៅលើទម្រង់នីមួយៗ ដើម្បីពិនិត្យចន្លោះប្រហោង និងកំហុសនានា។ ប្រសិនបើរកឃើញមានចន្លោះប្រហោង ឬ កំហុសណាមួយ អ្នកប្រមូលទិន្នន័យនឹងត្រូវបានណែនាំឱ្យធ្វើការកែតម្រូវជាបន្ទាន់។ ក្រសួងក៏បានធ្វើការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍នេះ ធៀបទៅនឹងរបាយការណ៍ អធិការកិច្ចផងដែរ។ បន្ទាប់មកទម្រង់បំពេញដោយដៃដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចរាល់ត្រូវបានបញ្ជូនទៅអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ អាជ្ញាធរនេះត្រូវបានជ្រើសរើសដោយសារតែមានជំនាញឯកទេស ក្នុងការរចនាទម្រង់ស្រង់ព័ត៌មាន និងវិភាគទិន្នន័យ។

មុនពេលចាប់ផ្ដើមវិភាគទិន្នន័យ អង្គការយូនីសេហ្វ និងក្រសួង ស.អ.យ. បានពិនិត្យផ្ទៀងផ្ទាត់ទៅលើទិន្នន័យដែលបានបញ្ចូលចំនួន១០% ជ្រើសរើសចេញពីខេត្តទាំងអស់។ ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ចំនួន២លើក បានធ្វើឡើងមុនពេលធ្វើការវិភាគបន្ថែមទៀត។

បន្ទាប់មក ទិន្នន័យត្រូវបានចងក្រង និងវិភាគដោយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងនាយកដ្ឋានសុខុមាលភាពកុមារនៃក្រសួង ស.អ.យ. ដោយមានកិច្ចគាំទ្របច្ចេកទេសពីអង្គការយូនីសេហ្វ។

## ការកែសំរួលវិធីសាស្ត្រ ផ្អែកលើបទពិសោធន៍លើកទី១

ការកែលម្អដោយផ្អែកលើបទពិសោធន៍ពីការប្រមូលទិន្នន័យលើកទី១ ត្រូវបានយកមកប្រើប្រាស់ដើម្បីកែលម្អទៅលើការកំណត់ ទីតាំងកន្លែងថែ ទាំកុមារនៅក្នុងខេត្តដែលនៅសេសសល់ចំនួន២០ទៀត។ ការកែលម្អសំខាន់ៗរួមមានដូចខាងក្រោម៖

# ៣. វិធីសាស្ត្រ

- ការបំបែកទៅតាមអាយុរបស់កុមារ និង យុវជនវ័យក្មេងដែលកំពុងរស់នៅក្នុងមណ្ឌល និងទិន្នន័យបន្ថែមដទៃទៀត
- ការបណ្តុះបណ្តាលដែលមានរយៈពេលវែងជាងនេះសម្រាប់អ្នកប្រមូលទិន្នន័យ និងអ្នកត្រួតពិនិត្យ រាប់បញ្ចូលការបណ្តុះបណ្តាលជាក់ស្តែង និង វគ្គសិក្សាមួយអំពីបច្ចេកទេសសម្ភាសន៍ ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់មួយចំនួនដែលត្រូវបានជ្រើសរើស
- ការតម្រង់ទិសសម្រាប់ជនបង្គោលនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាអំពីការផ្ទៀងផ្ទាត់ទិន្នន័យ
- ការពិនិត្យផ្ទៀងផ្ទាត់មួយដំណាក់កាលទៀតនៅថ្នាក់ក្រសួង មុនពេលបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធទិន្នន័យ ក្នុងនោះរាប់បញ្ចូលទាំងការពិនិត្យផ្ទៀងផ្ទាត់របាយការណ៍កំណត់ទីតាំងមណ្ឌល និងរបាយការណ៍អធិការកិច្ចដើម្បីធានាថាពុំមានបាត់មណ្ឌលណាមួយដែលត្រូវបានបញ្ចូលក្នុងអំឡុងពេលនៃការធ្វើអធិការកិច្ចមុននោះទេ
- ការអនុវត្តវិធានការបន្ថែមទៀតចំពោះទិន្នន័យដោយក្រុមសិក្សាស្រាវជ្រាវរបស់ក្រសួងដែលបានធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលផ្តល់ជូនអំពីមណ្ឌលជាសំណាកនៃការសិក្សាស្រាវជ្រាវតាមរយៈការទូរស័ព្ទទៅកាន់មណ្ឌលដែលបានរាយការណ៍ឱ្យដឹង និងការធ្វើផ្ទៀងផ្ទាត់ទៅលើទិន្នន័យសំខាន់ៗ ដោយយកចិត្តទុកដាក់លើឃុំសង្កាត់ដែលមានចំនួនមណ្ឌលច្រើន និងឃុំសង្កាត់ដែលស្ថិតនៅតំបន់ដាច់ស្រយាល។

## ភាពមានកម្រិត

បើទោះបីជាមានដំណើរការត្រួតពិនិត្យគុណភាពផ្សេងៗគ្នាដែលក្រុមសិក្សាស្រាវជ្រាវបានជ្រើសរើសប្រើប្រាស់ក៏ដោយ ក៏នៅតែមានភាពមានកម្រិតជាក់លាក់មួយចំនួនផងដែរ។

ក្រុមសិក្សាស្រាវជ្រាវសម្រេចប្រើប្រាស់ទិន្នន័យស្វ័យរាយការណ៍អំពីចំនួនកុមារ ដែលរស់នៅក្នុងកន្លែងថែទាំកុមារ និងប្រភេទកន្លែងថែទាំកុមារ ដោយទទួលស្គាល់ថាទិន្នន័យនេះមិនទាន់បានពិនិត្យផ្ទៀងផ្ទាត់នៅឡើយ។ ទិន្នន័យស្វ័យរាយការណ៍ អាចមានភាពលម្អៀងផ្ទាល់ខ្លួន អាស្រ័យទៅតាមភាគីដែលផ្តល់សេចក្តីរាយការណ៍។ ក្រុមសិក្សាស្រាវជ្រាវ បានធ្វើការសម្រេចបែបនេះ ដោយសារតែធនធានមនុស្ស និងហិរញ្ញវត្ថុមានកម្រិតព្រមទាំងកង្វះពេលវេលា និងមានការព្រួយបារម្ភ ចំពោះសុវត្ថិភាពរបស់អ្នកប្រមូលទិន្នន័យ ប្រសិនបើពួកគេត្រូវធ្វើដំណើរនៅពេលយប់។ ចំណុចខ្លាំង និងចំណុចខ្សោយនៃអភិក្រមបែបនេះ នឹងត្រូវបានយកមកវិភាគសម្រាប់ជាព័ត៌មានយោងនៅពេលអនាគត។

- បើទោះបីជាក្រសួងមានការជឿជាក់ថា កន្លែងថែទាំកុមារដ៏ច្រើនលើសលប់នៅក្នុងរាជធានី-ខេត្តទាំង៥ ត្រូវបានកំណត់រកឃើញក៏ដោយ វាក៏អាចនៅមានការខ្វះខាតផងដែរ ពីព្រោះអ្នកផ្តល់ព័ត៌មានសំខាន់ៗទាំងនោះមិនអាចដឹងគ្រប់កន្លែងថែទាំទាំងអស់ ដែលពុំមានលក្ខណៈជាការថែទាំតាមគ្រួសារ នៅក្នុងតំបន់របស់ពួកគេ ជាពិសេសកន្លែងថែទាំទ្រង់ទ្រាយតូចដែលមិនផ្លូវការ ដែលទើបបានបង្កើតថ្មី។
- ទិន្នន័យថ្មីៗដូចជាការបំបែកទៅតាមអាយុ និងថាតើកន្លែងថែទាំកុមារមានលក្ខណៈជាកន្លែងសាសនា ឬមិនមែនជាកន្លែងសាសនា មិនត្រូវបានបញ្ចូលទៅក្នុងការកំណត់ទីតាំងកន្លែងថែទាំកុមារក្នុងរាជធានី-ខេត្តអាទិភាពទាំង៥ឡើយ។ ចំណុចនេះធ្វើឱ្យមានកម្រិតទៅលើការកំណត់ជាទូទៅចំពោះទិន្នន័យដែលទទួលបានពីខេត្តទាំង២០ ដែលគេបានប្រមូលបន្ថែម។
- កន្លែងថែទាំកុមារដែលពុំមានបុគ្គលិកបម្រើការងារដែលទទួលបានបៀវត្សរ៍ មិនត្រូវបានរាប់បញ្ចូលឡើយអាស្រ័យដោយកន្លែងទាំងនេះមិនស្ថិតនៅក្រោមនិយមន័យនៃកន្លែងថែទាំកុមារ។ ការកំណត់បែបនេះ បានផាត់ចោលនូវកុមារជាច្រើនដែលអាចកំពុងរស់នៅក្នុងកន្លែងថែទាំបែបមិនផ្លូវការបែបនេះ និងអាចប្រឈមទៅនឹងហានិភ័យទាក់ទងនឹងកិច្ចការពារកុមារ។

# ៩. គំហើញ និង ការពិភាក្សា

## ៩.១ គំហើញទូទៅអំពីចំនួន និង ប្រភេទកន្លែងថែទាំកុមារ

**តារាងទី២៖** ចំនួន និង ប្រភេទកន្លែងដែលកំពុងផ្តល់ការថែទាំកុមារ

| | | | | | | សរុប |
|---|---|---|---|---|---|---|
| ភាគរយ | ៦៤% | ៤% | ១១% | ១០% | ១១% | ១០០% |
| ចំនួនកន្លែងថែទាំកុមារ | ៤០៦ | ២៥ | ៧១ | ៦៥ | ៧២ | ៦៣៩ |
| ប្រភេទកន្លែងថែទាំកុមារ | មណ្ឌលថែទាំកុមារ | ផ្ទះស្នាក់នៅបណ្តោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន | ផ្ទះស្នាក់នៅជាក្រុម | វត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ | អន្តេវាសិកដ្ឋាន | |

*តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

តារាងទី២ បង្ហាញឱ្យឃើញអំពីចំនួន និង ប្រភេទកន្លែងផ្តល់ការថែទាំកុមារនៅគ្រប់រាជធានី-ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ តារាងនេះបង្ហាញថា មានកន្លែងថែទាំកុមារចំនួន ៦៣៩កន្លែង ដែលផ្តល់ការថែទាំកុមារក្នុងរាជធានី-ខេត្តទាំង២៥ (រូបភាពទី៣)។ ផ្អែកលើទិន្នន័យស្ទង់មតិរាយការណ៍ពីបុគ្គលិកមណ្ឌល (បុគ្គលិកបានផ្តល់និយមន័យផ្ទាល់មាត់អំពីប្រភេទកន្លែងថែទាំកុមារ) កន្លែងថែទាំកុមារទាំងនេះអាចបែងចែកជា ៥ប្រភេទ ៖ មណ្ឌលថែទាំកុមារ (៤០៦កន្លែង) ផ្ទះស្នាក់នៅបណ្តោះអាសន្ន/កន្លែងស្នាក់បន្ទាន់បណ្តោះអាសន្ន (២៥កន្លែង) ផ្ទះស្នាក់នៅជាក្រុម (៧១ កន្លែង) វត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ (៦៥កន្លែង) និងអន្តេវាសិកដ្ឋាន (៧២ កន្លែង)។

តារាងនេះបង្ហាញថា កន្លែងថែទាំកុមារភាគច្រើន (៦៤%) មានលក្ខខណ្ឌស្របទៅនឹងនិយមន័យបទដ្ឋាន របស់មណ្ឌលថែទាំកុមារ។ អន្តេវាសិកដ្ឋាន គឺជាកន្លែងថែទាំកុមារដែលធំជាងគេលំដាប់លេខរៀងទី២ និងបន្ទាប់មកគឺផ្ទះស្នាក់នៅជាក្រុម និង វត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់ កន្លែងស្នាក់នៅសម្រាប់កុមារ។ មណ្ឌលស្នាក់នៅបណ្តោះអាសន្ន ដែលមានចំនួនត្រឹមតែ ៤% មានអត្រាទាបជាងគេបំផុត ក្នុងចំណោមកន្លែងផ្តល់ការថែទាំទាំងអស់។

**រូបភាពទី៣៖** ចំនួន និង ប្រភេទកន្លែងថែទាំកុមារ



**តារាងទី៣៖** ចំនួនរាជធានី-ខេត្ត និង ប្រភេទកន្លែងថែទាំកុមារបែងចែកទៅតាមលំដាប់ចំនួននៃកន្លែងថែទាំកុមារ

| រាជធានី-ខេត្តសរុប | ២៥ | ២៥ | ២៥ | ២៥ | ២៥ |
|---|---|---|---|---|---|
| **ចំនួនរាជធានីខេត្ត និងប្រភេទកន្លែងថែទាំកុមារតាមលំដាប់** | | | | | |
| ច្រើនជាង10 | ៩ | ១ | ៣ | ១ | ៣ |
| ចន្លោះពី 6 ទៅ 10 | ៦ | ០ | ១ | ១ | ០ |
| ចន្លោះពី 1 ទៅ 5 | ៩ | ៥ | ១០ | ១៣ | ១២ |
| 0 | ១ | ១៩ | ១១ | ១០ | ១០ |
| **ប្រភេទកន្លែងថែទាំកុមារ** | មណ្ឌលថែទាំកុមារ | ផ្ទះស្នាក់នៅបណ្ដោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្ន | ផ្ទះស្នាក់នៅជាក្រុម | វត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ | អន្តេវាសិកដ្ឋាន |

តារាងទី៣ បង្ហាញអំពីចំនួនរាជធានី-ខេត្ត និងប្រភេទកន្លែងថែទាំកុមារតាមលំដាប់។ ទិន្នន័យនេះត្រូវបានបែងចែកជា៤ក្រុម៖ រាជធានី-ខេត្តដែលបានកត់ត្រាថាគ្មានកន្លែងថែទាំកុមារ មានកន្លែងថែទាំកុមារ ចន្លោះពី ១ ទៅ ៥ , ៦ ទៅ ១០ ឬ លើសពី១០។ តារាងនេះបានបង្ហាញឱ្យឃើញថាមណ្ឌលថែទាំកុមារមានចំនួនច្រើនជាងកន្លែងថែទាំកុមារប្រភេទដទៃទៀត ដោយមានតែខេត្តចំនួន១ប៉ុណ្ណោះដែលបានកត់ត្រាថាគ្មានមណ្ឌលថែទាំកុមារ ដោយឡែក រាជធានី-ខេត្តចំនួន ៧៦% បានកត់ត្រាថាគ្មានមណ្ឌលស្នាក់នៅបណ្តោះអាសន្ន ៤៤% បានកត់ត្រាថាគ្មានផ្ទះស្នាក់នៅជាក្រុម និង ៤០% បានកត់ត្រាថាគ្មានអន្តេវាសិកដ្ឋាន ឬ វត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ។

តារាងនេះបង្ហាញថា លើកលែងតែមណ្ឌលថែទាំកុមារ ក្រៅពីនោះ កន្លែងថែទាំកុមារប្រភេទដទៃទៀតមានចំនួនតិចតួចទូទាំងរាជធានីខេត្តនានាដោយខេត្តជាច្រើនបានកត់ត្រាថាមានចំនួនសូន្យ(តារាងទី៣)។សូម្បីតែមណ្ឌលថែទាំកុមារ ក៏មានលក្ខណៈប្រមូលផ្តុំនៅក្នុងរាជធានីខេត្តមួយចំនួនផងដែរ។ គំហើញសំខាន់ៗមួយចំនួនដទៃទៀត ដែលទទួលបានពីការប្រៀបធៀបរវាងកន្លែងថែទាំកុមារទាំងនេះ មានសង្ខេបជូនដូចខាងក្រោម។

រាជធានីភ្នំពេញ ដែលមានចំនួនកន្លែងថែទាំកុមារច្រើនជាងគេ មានលក្ខណៈគួរឱ្យកត់សម្គាល់ចំពោះការដែលវាមានវត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ ក្នុងចំនួនមួយទាបយ៉ាងខ្លាំង។ ខេត្តបន្ទាយមានជ័យ ដែលមានចំនួនមណ្ឌលថែទាំកុមារក្នុងកម្រិតមួយទាបជាងគួរឱ្យកត់សម្គាល់ មានវត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ ច្រើនជាងគេបំផុត សរុបចំនួន២១កន្លែង ស្មើនឹង ៣២% នៃវត្តអារាម និង អគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារសរុប។

ផ្ទះស្នាក់នៅជាក្រុមក្នុងចំនួនមួយដ៏ខ្ពស់គួរឱ្យកត់សម្គាល់ត្រូវបានរកឃើញនៅរាជធានីភ្នំពេញ ខេត្តសៀមរាប និង ខេត្តបាត់ដំបង ដោយឡែក អន្តេវាសិកដ្ឋានជាច្រើនត្រូវបានរកឃើញនៅខេត្តសៀមរាប និង ខេត្តបន្ទាយមានជ័យ។

អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេសគឺជាចំនួនផ្ទះស្នាក់នៅបណ្តោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន ដែលមានចំនួនទាបបំផុតក្នុងចំណោមកន្លែងថែទាំកុមារសរុប ដោយមានចំនួនត្រឹម៤%។ កន្លែងថែទាំកុមារប្រភេទនេះ ពុំមានវត្តមាននៅក្នុងរាជធានី-ខេត្ត ចំនួន១៩ ក្នុងចំណោមរាជធានី-ខេត្ត ទាំង២៥ ដោយឡែករាជធានី-ខេត្តដែលនៅសេសសល់បង្ហាញឱ្យឃើញអំពីវត្តមាននៃកន្លែងថែទាំកុមារប្រភេទនេះក្នុងចំនួនតិចតួចប៉ុណ្ណោះ (ចន្លោះពី១ទៅ៥) លើកលែងតែរាជធានីភ្នំពេញ ដែលមានកន្លែងស្នាក់នៅបណ្តោះអាសន្នចំនួន១៤។

**តារាងទី៤៖** ចំនួនកុមារ និង យុវជនវ័យក្មេងដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ

| ប្រភេទកន្លែងថែទាំកុមារ | ចំនួនកុមារ (អាយុ ០-១៧ឆ្នាំ) | | សរុប | ចំនួនយុវជនវ័យក្មេង (អាយុ ១៨-២៤ឆ្នាំ) | | សរុប | ចំនួនកុមារ និង យុវជនវ័យក្មេងសរុប |
|---|---|---|---|---|---|---|---|
| មណ្ឌលថែទាំកុមារ | ៧.៧៧៦ | ៨.៨០៣ | ១៦.៥៧៩ | ២.០៥៦ | ៤.៧១៣ | ៦.៧៦៩ | ២៣.៣៤៨ |
| ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន | ៣៤៨ | ២៨០ | ៦២៨ | ១៨៥ | ១៣៦ | ៣២១ | ៩៤៩ |
| ផ្ទះស្នាក់នៅជាក្រុម | ៨២០ | ៧៧២ | ១.៥៩២ | ៣២០ | ២២៤ | ៥៤៤ | ២.១៣៦ |
| វត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ | ៦៧៣ | ៦៧៦ | ១.៣៤៩ | ៤៣ | ១៧៩ | ២២២ | ១.៥៧១ |
| អន្តេវាសិកដ្ឋាន | ២.៩០៩ | ៣.១៣០ | ៦.០៣៩ | ៧១៩ | ៦១២ | ១.៣៣១ | ៧.៣៧០ |
| សរុប | ១២.៥២៦ | ១៣.៦៦១ | ២៦.១៨៧ | ៣.៣២៣ | ៥.៨៦៤ | ៩.១៨៧ | ៣៥.៣៧៤ |

តារាងទី៤ បង្ហាញថា មានកុមារចំនួន ១៦.៥៧៩នាក់ (៤៧%ជាកុមារី) អាយុក្រោម១៨ឆ្នាំ ត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន ៤០៦កន្លែង។ មានកុមារចំនួន ៩.៦០៨ នាក់បន្ថែមទៀត អាយុក្រោម១៨ឆ្នាំ (៤៩%ជាកុមារី) ត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមារចំនួន ២៣៣កន្លែង ដទៃទៀត។ ចំនួនកុមារសរុបបញ្ចូលគ្នា ដែលកំពុងរស់នៅក្នុងគ្រប់កន្លែងថែទាំកុមារទាំងអស់ មានចំនួន ២៦.១៨៧នាក់ (៤៨%ជាកុមារី)។ ផ្អែកលើចំនួនប្រជាជនឆ្នាំ២០១៥ មានន័យថាកុមារស្ទើរតែ ១នាក់ក្នុងចំណោមកុមារចំនួន ៣៥០នាក់ នៅកម្ពុជា កំពុងរស់នៅក្នុងមណ្ឌលតែទាំកុមារ[១៤]។

យុវជនវ័យក្មេងចំនួន ៩.១៨៧នាក់បន្ថែមទៀត (៣៦% ជាស្ត្រី) អាយុចន្លោះពី ១៨ឆ្នាំ ទៅ ២៥ឆ្នាំ ត្រូវបានរាយការណ៍ឱ្យដឹងថា កំពុងរស់នៅក្នុងកន្លែងថែទាំកុមារ ចំនួន ៦៣៩កន្លែង។ យុវជនវ័យក្មេងទាំងនេះភាគច្រើន កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ដែលស្មើនឹង ៧៤% នៃចំនួនយុវជនវ័យក្មេងសរុប។

ចំនួនកុមារ និង យុវជនវ័យក្មេងសរុបបញ្ចូលគ្នា ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមារទាំង ៦៣៩កន្លែង មានចំនួន ៣៥.៣៧៤នាក់ (៤៥%ជាស្ត្រី)។

តារាងបង្ហាញឱ្យដឹងថា កុមារភាគច្រើននៃកុមារសរុប ដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ (៦១%) រស់នៅក្នុងមណ្ឌលថែទាំកុមារ។

មានកុមារាច្រើនជាងកុមារីបន្តិច កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ (៥៣%) និង អន្តេវាសិកដ្ឋាន(៥២%)។ កុមារប្រមាណ ៥០% ដែលកំពុងរស់នៅតាមវត្តអារាម និង អគារសាសនាដទៃ ទៀត គឺជាកុមារី។ មានកុមារីច្រើនជាងកុមារាបន្តិចដែលកំពុងរស់នៅក្នុងមណ្ឌលស្នាក់នៅបណ្តោះអាសន្ន (៥៥%) និង អន្តេវាសិកដ្ឋាន(៥២%)។

១៤ យោងតាមការព្យាករណ៍ចំនួនប្រជាជនឆ្នាំ២០១៥ ចំនួនកុមារសរុបអាយុក្រោម ១៨ឆ្នាំ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៥.៨៥០.០០០នាក់ (UNDESA, 015)។

## ៤.២ គំហើញអំពីមណ្ឌលថែទាំកុមារ

**រូបភាពទី៤៖** ចំនួនមណ្ឌលថែទាំកុមារ បែងចែកតាមរាជធានី-ខេត្ត




រូបភាពទី៤ បង្ហាញអំពីចំនួនមណ្ឌលថែទាំកុមារក្នុងមួយខេត្ត។ មណ្ឌលមានចំនួនចន្លោះពីសូន្យក្នុងខេត្តត្បូងឃ្មុំ ទៅ ១១៧ ក្នុងរាជធានីភ្នំពេញ។ តារាងនេះបង្ហាញថា មណ្ឌលភាគច្រើនស្ថិតនៅរាជធានីភ្នំពេញ (៤៤%) បន្ទាប់មក គឺខេត្តសៀមរាប (៣០%)។ មណ្ឌលថែទាំកុមារប្រមូលផ្ដុំនៅក្នុងរាជធានី-ខេត្តចំនួន៩ ដែលស្មើនឹង ៨៣% នៃចំនួនសរុប ដោយមណ្ឌលដែលមានចំនួនច្រើនជាងគេ ត្រូវបានកត់ត្រាថាស្ថិតនៅរាជធានីភ្នំពេញ (១១៧) បន្ទាប់មកគឺ ខេត្តសៀមរាប (៨០) បាត់ដំបង (៣៥) កំពង់ធំ (២៣) កណ្ដាល (២០) កំពត (១៧) កំពង់ឆ្នាំង (១៦) ព្រះសីហនុ (១៥) និងកំពង់ស្ពឺ (១៥)។ គ្រាន់តែរាជធានីភ្នំពេញ និងខេត្តសៀមរាប តែឯង មានមណ្ឌលថែទាំកុមារចំនួន ៤៩% នៃមណ្ឌលថែទាំកុមារសរុបក្នុងប្រទេសកម្ពុជាទៅហើយ។ មណ្ឌលមានចំនួនចន្លោះពី ១ ទៅ ៩ ក្នុងខេត្តចំនួន១៥ទៀត ដែលនៅសេសសល់។ ពុំមានមណ្ឌលថែទាំកុមារ (ឬកន្លែងថែទាំកុមារដទៃទៀត) ត្រូវបានកត់ត្រាថាមាននៅក្នុងខេត្តត្បូងឃ្មុំឡើយ។

**តារាងទី៥៖** មណ្ឌលថែទាំកុមារ បែងចែកតាមស្ថានភាពអធិការកិច្ច

| | | | |
|---|---|---|---|
| ភាគរយ | ៦២% | ៣៨% | សរុប ១០០% |
| ចំនួន | ២៥០ | ១៥៦ | សរុប ៤០៦ |
| ប្រភេទមណ្ឌល |  មណ្ឌលថែទាំកុមារដែលក្រសួង ស.អ.យ. បានធ្វើអធិការកិច្ចក្នុងឆ្នាំ២០១៥ |  មណ្ឌលថែទាំកុមារដែលក្រសួង ស.អ.យ. មិនបានធ្វើអធិការកិច្ច និងត្រូវបានកំណត់រកឃើញក្នុងអំឡុងពេលនៃការកំណត់ទីតាំងមណ្ឌល (២០១៥) | |

តារាងទី៥ បង្ហាញថាមណ្ឌលថែទាំកុមារចំនួន ៣៨% ត្រូវបានកំណត់រកឃើញថ្មីៗ ក្នុងអំឡុងពេលនៃដំណើរការកំណត់ទីតាំងមណ្ឌល។ តារាងនេះបញ្ជាក់ថាមានភាពខុសគ្នារវាងចំនួនកន្លែងថែទាំកុមារជាក់ស្តែង (៤០៦) និងចំនួនកន្លែងថែទាំកុមារដែលត្រូវបានរាយការណ៍ឱ្យដឹង/ធ្វើអធិការកិច្ច(២៥០)នៅកម្ពុជា។ ចំណុចនេះបង្ហាញឱ្យឃើញអំពីចន្លោះប្រហោងគួរឱ្យកត់សម្គាល់មួយក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមារមួយភាគធំ អាស្រ័យដោយមណ្ឌលចំនួន ៣៨% មិនដែលត្រូវបានធ្វើអធិការកិច្ច ឬដាក់ឱ្យស្ថិតក្រោមការឃ្លាំមើល និងការគ្រប់គ្រងសមស្របរបស់រដ្ឋាភិបាលឡើយ។ កត្តានេះភាគច្រើនបណ្តាលមកពីការដែលមានតែមណ្ឌលដែលមានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងប៉ុណ្ណោះដែលត្រូវបានធ្វើអធិការកិច្ច។ ចំណុចនេះបង្ហាញឱ្យឃើញអំពីចន្លោះប្រហោងដ៏ធ្ងន់ធ្ងរ នៅក្នុងប្រព័ន្ធថែទាំកុមាររបស់ប្រទេសកម្ពុជា ដោយវាបាន បញ្ជាក់អំពីការព្រួយបារម្ភជាយូរយារណាស់មកហើយរបស់រដ្ឋាភិបាល និងបុគ្គលិកការពារកុមារ ចំពោះសុខុមាលភាពរបស់កុមារដែលកំពុងរស់នៅក្នុងមណ្ឌលដែលគ្មានការត្រួតពិនិត្យ និងកំណើន "មណ្ឌលកុមារកំព្រា" ដោយគ្មានការគ្រប់គ្រងនៅកម្ពុជា។ ស្របពេលជាមួយគ្នានេះដែរ វាក៏បានផ្តល់ឱ្យក្រសួងនូវព័ត៌មានគ្រប់ជ្រុងជ្រោយអំពីកុមារដែលរស់នៅក្នុងមណ្ឌល និងឱកាសក្នុងការជួបជាមួយពួកគេដើម្បីធ្វើការប៉ាន់ប្រមាណស្ថានភាពរបស់ពួកគេដែលនេះគឺជាជំហានដំបូងមួយដ៏សំខាន់សំដៅឆ្ពោះទៅរកដំណើរការសមាហរណកម្មតាមគ្រួសារ និងសហគមន៍មួយដ៏វែងឆ្ងាយ។

បន្ថែមពីនេះទៀត តារាងទី៦បង្ហាញអំពីស្ថានភាពនៃការធ្វើអធិការកិច្ច ដោយបែងចែកទៅតាមរាជធានី-ខេត្តនីមួយៗ។ គ្រប់មណ្ឌលថែទាំកុមារទាំងអស់ ត្រូវបានធ្វើអធិការកិច្ចនៅក្នុងរាជធានី-ខេត្តចំនួន១០។ ស្ថានភាពនៃការធ្វើអធិការកិច្ច មានភាពខុសគ្នានៅក្នុងបណ្តាខេត្តដទៃទៀត។ រាជធានីភ្នំពេញមានចំនួនមណ្ឌលច្រើនជាងគេបំផុតដែលមិនត្រូវបានធ្វើអធិការកិច្ច បន្ទាប់មកគឺខេត្តសៀមរាប កំពង់ធំ បាត់ដំបង កំពត និង កំពង់ឆ្នាំង។ ចំពោះភាគរយនៃមណ្ឌលដែលមិនត្រូវបានធ្វើអធិការកិច្ចនៅក្នុងរាជធានី-ខេត្តចំនួន៦ មានមណ្ឌលចំនួន ៥០% ឬច្រើនជាងនេះដែលមិនត្រូវបានធ្វើអធិការកិច្ច។ ក្នុងនោះ ខេត្តដែលមានអត្រាភាគរយខ្ពស់ជាងគេគឺខេត្តកំពត (៧១%) បន្ទាប់មកគឺខេត្តកំពង់ធំ (៧០%) និងខេត្តកំពង់ឆ្នាំង (៥៦%)។ រាល់មណ្ឌលទាំងនេះ មិនស្ថិតនៅក្នុងរាជធានី-ខេត្តអាទិភាពទាំង៥ឡើយ ប៉ុន្តែវាស្ថិតនៅក្នុងរាជធានី-ខេត្តទាំង៩ ដែលមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារខ្ពស់។

តារាងនេះបង្ហាញអំពីភាពខុសគ្នារវាងបណ្តារាជធានី-ខេត្តផ្សេងៗគ្នា ដែលស្តែងឱ្យឃើញថា ការត្រួតពិនិត្យ និងការគ្រប់គ្រងជារួម មានប្រសិទ្ធភាពជាងនៅក្នុងរាជធានី-ខេត្តចំនួន១០ ដោយរាល់មណ្ឌលទាំងអស់ដែលត្រូវបានកំណត់ទីតាំងសុទ្ធសឹងតែត្រូវបានធ្វើអធិការកិច្ច។ បើទោះជាដូច្នេះក្តី ការគ្រប់គ្រងមិនសូវមានប្រសិទ្ធភាពនៅក្នុងរាជធានី-ខេត្តចំនួន១៤ អាស្រ័យដោយមណ្ឌលជាច្រើនដែលត្រូវបានកំណត់រកឃើញ ក្នុងអំឡុងពេលនៃការកំណត់ទីតាំងមណ្ឌលមិនត្រូវបានធ្វើអធិការកិច្ច។ មណ្ឌលភាគច្រើនដែលមិនត្រូវបាន ធ្វើអធិការកិច្ច (៩២%) ស្ថិតនៅក្នុងចំណោមរាជធានី-ខេត្តចំនួន៨ នៃរាជធានី-ខេត្តទាំង៩ ដែលមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារច្រើន។

## តារាងទី៦៖ ការប្រៀបធៀបរវាងចំនួនមណ្ឌលថែទាំកុមារដែលគេស្គាល់មុន និង ក្រោយពេលកំណត់ទីតាំងមណ្ឌល

| រាជធានីខេត្ត | ចំនួនមណ្ឌលថែទាំកុមារសរុបដែលត្រូវបានកំណត់ទីតាំងក្នុងឆ្នាំ២០១៥ | មណ្ឌលថែទាំកុមារដែលក្រសួង ស.អ.យ. បានធ្វើអធិការកិច្ចក្នុងឆ្នាំ២០១៥ ផ្អែកលើរបាយការណ៍អធិការកិច្ច[១៥] | មណ្ឌលថែទាំកុមារដែលក្រសួង ស.អ.យ. មិនបានធ្វើអធិការកិច្ច និងត្រូវបានកំណត់រកឃើញក្នុងអំឡុងពេលធ្វើការកំណត់ទីតាំង (២០១៥) | ភាគរយនៃមណ្ឌលដែលមិនត្រូវបានធ្វើអធិការកិច្ច |
|---|---|---|---|---|
| ភ្នំពេញ | ១១៧ | ៥៩ | ៥៨ | ៥០ |
| សៀមរាប | ៨០ | ៥២ | ២៨ | ៣៥ |
| បាត់ដំបង | ៣៥ | ២៣ | ១២ | ៣៤ |
| កំពង់ធំ | ២៣ | ៧ | ១៦ | ៧០ |
| កណ្ដាល | ២០ | ១៥ | ៥ | ២៥ |
| កំពត | ១៧ | ៥ | ១២ | ៧១ |
| កំពង់ឆ្នាំង | ១៦ | ៧ | ៩ | ៥៦ |
| ព្រះសីហនុ | ១៥ | ១១ | ៤ | ២៧ |
| កំពង់ស្ពឺ | ១៥ | ១៥ | ០ | ០ |
| បន្ទាយមានជ័យ | ៩ | ៩ | ០ | ០ |
| កំពង់ចាម | ៨ | ៦ | ២ | ២៥ |
| ស្វាយរៀង | ៧ | ៤ | ៣ | ៤៣ |
| តាកែវ | ៧ | ៧ | ០ | ០ |
| ក្រចេះ | ៦ | ៣ | ៣ | ៥០ |
| ព្រៃវែង | ៦ | ៥ | ១ | ១៧ |
| ពោធិ៍សាត់ | ៥ | ៥ | ០ | ០ |
| ឧត្ដរមានជ័យ | ៤ | ២ | ២ | ៥០ |
| ប៉ៃលិន | ៤ | ៣ | ១ | ២៥ |
| ព្រះវិហារ | ៣ | ៣ | ០ | ០ |
| រតនគិរី | ៣ | ៣ | ០ | ០ |
| ស្ទឹងត្រែង | ៣ | ៣ | ០ | ០ |
| កែប | ១ | ១ | ០ | ០ |
| កោះកុង | ១ | ១ | ០ | ០ |
| មណ្ឌលគិរី | ១ | ១ | ០ | ០ |
| ត្បូងឃ្មុំ | ០ | ០ | ០ | ០ |
| សរុប | ៤០៦ | ២៥០ | ១៥៦ | ៣៨ |

● ខេត្តអាទិភាពបច្ចុប្បន្ន

● ខេត្តផ្សេងទៀតដែលមានមណ្ឌលថែទាំកុមារក្នុងចំនួនច្រើន

[១៥] យោងតាមរបាយការណ៍អធិការកិច្ច បានឱ្យដឹងថាមានមណ្ឌលចំនួន២៥៨កន្លែងត្រូវបានធ្វើអធិការកិច្ចក្នុងឆ្នាំ២០១៥។ យ៉ាងណាមិញ នៅពេលធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ មានមណ្ឌលចំនួន៨ក្នុងចំណោមមណ្ឌលទាំងនេះ ត្រូវបានរកឃើញថាស្ថិតនៅក្រោមប្រភេទកន្លែងថែទាំកុមារដទៃទៀត ដូច្នេះចំនួនមណ្ឌលសរុប សំដៅចំពោះមណ្ឌលដែលត្រូវបានធ្វើអធិការកិច្ច ដោយមិនរាប់បញ្ចូលកន្លែងថែទាំទាំង៨ ដែលស្ថិតក្រោមនិយមន័យរបស់កន្លែងថែទាំប្រភេទដទៃទៀត។ ដូច្នេះ ផ្នែកនេះប្រើប្រាស់តួលេខមណ្ឌលចំនួន ២៥០ សម្រាប់ការវិភាគប្រៀបធៀបមួយ រវាង មណ្ឌលដែលបានធ្វើអធិការកិច្ច និង មណ្ឌលដែលមិនបានធ្វើអធិការកិច្ច។ បើទោះជាដូច្នេះក្ដី សម្រាប់ការសំដៅយោងដទៃទៀតចំពោះរបាយការណ៍ អធិការកិច្ចឆ្នាំ២០១៥ ដូចជានៅក្នុងសារតានៃរបាយការណ៍នេះ តួលេខមណ្ឌលថែទាំកុមារចំនួន ២៥៨ ត្រូវបានយកមកប្រើប្រាស់។

**តារាងទី៧៖** មណ្ឌលថែទាំកុមារដែលផ្ដល់ការថែទាំរយៈពេលខ្លី និង រយៈពេលវែង

| ប្រភេទមណ្ឌលថែទាំកុមារដែលផ្ដល់ការថែទាំរយៈពេលខ្លី - រយៈពេលវែង | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង ៦ខែ | ២៦ | ៦% |
| លើសពី ៦ខែ | ២៩៣ | ៧២% |
| NO គ្មានការបញ្ជាក់ច្បាស់លាស់អំពីរយៈពេលជាមធ្យមនៃការថែទាំដែលផ្ដល់ជូន | ៨៧ | ២២% |
| សរុប | ៤០៦ | ១០០% |

*តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

ក្នុងចំណោមមណ្ឌលទាំង ៤០៦កន្លែង មានមណ្ឌលចំនួន ២៩៣កន្លែង (៧២%) ផ្ដល់ការថែទាំរយៈពេលវែង (លើសពី៦ខែ) និង មណ្ឌលចំនួន២៦ (៦%) ផ្ដល់ការថែទាំរយៈពេលខ្លី (តិចជាង៦ខែ)។ មានមណ្ឌលចំនួន ៨៧ (២២%) ដែលគ្មានទិន្នន័យអំពីរយៈពេលនៃការស្នាក់នៅ។ តារាងនេះបង្ហាញថា មណ្ឌលថែទាំកុមារភាគច្រើន ផ្ដល់ការថែទាំរយៈពេលវែង ដែលផ្ទុយពីគោលការណ៍ណែនាំស្ដីពីការថែទាំជំនួសចំពោះកុមារ[១៦] និង គោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ[១៧] ដែលចែងយ៉ាងច្បាស់ថា ការថែទាំតាមមណ្ឌលគប្បីជាជម្រើសចុងក្រោយ និង ជាដំណោះស្រាយបណ្ដោះអាសន្ន ហើយការថែទាំតាមគ្រួសារ និងសហគមន៍ គឺជាជម្រើសប្រសើរបំផុតសម្រាប់ការថែទាំជំនួស។

**តារាងទី៨៖** ស្ថានភាពនៃការចុះបញ្ជីមណ្ឌលថែទាំកុមារ

| ប្រភេទនៃការចុះបញ្ជី | យ៉ាងហោចណាស់បានចុះបញ្ជីជាមួយស្ថាប័នមួយរបស់រដ្ឋាភិបាល | មណ្ឌលកុមារកំព្រារដ្ឋដែលស្ថិតក្រោមក្រសួង ស.អ.យ. (មិនតម្រូវឱ្យចុះបញ្ជី) | មណ្ឌលដែលមិនបានចុះបញ្ជី | សរុប |
|---|---|---|---|---|
| ភាគរយ | ៨២% | ៥% | ១២% | ១០០% |
| ចំនួន | ៣៣៤ | ២២ | ៥០ | ៤០៦ |

*តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០% ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

តារាងទី៨ បង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន ៣៣៤កន្លែង ដែលយ៉ាងហោចណាស់បានចុះបញ្ជីជាមួយស្ថាប័នមួយរបស់រដ្ឋាភិបាល[១៨]។ មានមណ្ឌលរដ្ឋចំនួន ២២ផងដែរ ដែលគ្រប់គ្រងដំណើរការដោយក្រសួង ស.អ.យ. និងមិនតម្រូវឱ្យចុះបញ្ជី។ មានមណ្ឌលដែលមិនបានចុះបញ្ជីចំនួន ៥០កន្លែង ទូទាំងរាជធានី-ខេត្ត ចំនួន១០។ មណ្ឌលថែទាំកុមារបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ ឬ អាជ្ញាធរមូលដ្ឋាន។ មណ្ឌលថែទាំកុមាររដ្ឋ មិនតម្រូវឱ្យចុះបញ្ជីឡើយ។

[១៦] សេចក្ដីសម្រេចដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ ៤ ចំនុចទី១៤។

[១៧] គោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ ព្រះរាជាណាចក្រកម្ពុជា ខែមេសា ឆ្នាំ២០០៦ ជំពូក៤ ទំព័រ១២។

[១៨] សូមកត់សម្គាល់ថាការចុះបញ្ជីជាមួយក្រសួង ស.អ.យ. ពុំមែនជាលក្ខខណ្ឌតម្រូវមួយឡើយសម្រាប់មណ្ឌលថែទាំកុមារ។ ស្ថានភាពនេះបានផ្លាស់ប្ដូរនាពេលថ្មីៗនេះ នៅពេលដែលមានការអនុម័តក្នុងខែកញ្ញា ឆ្នាំ២០១៥ ទៅលើអនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។ អនុក្រឹត្យនេះតម្រូវឱ្យ គ្រប់មណ្ឌលទាំងអស់ត្រូវមានការអនុញ្ញាតពីក្រសួង ស.អ.យ.។

## រូបភាពទី៥៖ ចំនួនមណ្ឌលដែលមិនបានចុះបញ្ជី បែងចែកទៅតាមខេត្ត




រូបភាពទី៥ បង្ហាញថា មណ្ឌលដែលមិនបានចុះបញ្ជីទាំង ៥០នេះ ត្រូវបានរកឃើញនៅក្នុងរាជធានី-ខេត្តចំនួន១០។ តារាងនេះបង្ហាញឱ្យឃើញថា មណ្ឌលភាគច្រើន(៩២%)ស្ថិតនៅក្នុងរាជធានី-ខេត្តចំនួន ៧ក្នុងចំណោម៩ ដែលបានកត់ត្រាថាមានចំនួនមណ្ឌលខ្ពស់ (លើកលែងតែខេត្តកំពត និងខេត្តបាត់ដំបង) ដោយមានមណ្ឌលដែលមិនបានចុះបញ្ជីចំនួន ៣៧កន្លែង នៅក្នុងរាជធានី-ខេត្តអាទិភាពចំនួន៤ ក្នុងចំណោមរាជធានី-ខេត្តអាទិភាពទាំង៥ ស្មើនឹង៧៤% នៃចំនួនមណ្ឌលដែលមិនបានចុះបញ្ជីសរុប។ មណ្ឌលដែលមិនបានចុះបញ្ជីមានចំនួនច្រើនជាងគេបំផុត ត្រូវបានរកឃើញនៅរាជធានីភ្នំពេញ (៤០%) បន្ទាប់មកគឺខេត្តព្រះសីហនុ (២២%) និង ខេត្តកំពង់ធំ (១០%)។

## តារាងទី៩៖ មណ្ឌលថែទាំកុមារដែលមានអនុស្សរណៈនៃការយោគយល់ជាមួយទីភ្នាក់ងាររដ្ឋាភិបាលមួយ

| | | | | |
|---|---|---|---|---|
| ភាគរយ | ៧៣% | ២១% | ៥% | សរុប ១០០% |
| ចំនួន | ២៩៧% | ៨៧ | ២២ | សរុប ៤០៦ |
| ស្ថានភាពនៃអនុស្សរណៈនៃការយោគយល់ជាមួយរដ្ឋាភិបាល | មណ្ឌលដែលមានអនុស្សរណៈនៃការយោគយល់ចំនួន១ ឬ ច្រើនជាងនេះ | មណ្ឌលដែលគ្មានអនុស្សរណៈនៃការយោគយល់ | មណ្ឌលកុមារកំព្រារដ្ឋ (មិនតម្រូវឱ្យមានអនុស្សរណៈនៃការយោគយល់) | |

*តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

តារាងទី៩ បង្ហាញថាមណ្ឌលថែទាំកុមារចំនួន២៩៧កន្លែង (លើកលែងតែមណ្ឌលកុមារកំព្រារដ្ឋ ដែលមិនតម្រូវឱ្យមានអនុស្សរណៈនៃការយោគយល់)មានអនុស្សរណៈនៃការយោគយល់ចំនួន១ឬច្រើនជាងនេះជាមួយក្រសួងរដ្ឋាភិបាលមួយ ដោយឡែក មណ្ឌលចំនួន៨៧ ពុំមានអនុស្សរណៈនៃការយោគយល់ឡើយ។ តារាងនេះបង្ហាញថា មានមណ្ឌល១ ក្នុងចំណោមមណ្ឌលចំនួន ៥ ធ្វើប្រតិបត្តិការដោយគ្មានកិច្ចព្រមព្រៀងផ្លូវការណាមួយ ដែលចំណុចនេះបង្ហាញឱ្យឃើញអំពីចន្លោះប្រហោងមួយនៅក្នុងប្រព័ន្ធច្បាប់។ មណ្ឌលដែលគ្មានអនុស្សរណៈនៃការយោគយល់ (បែងចែកទៅតាមរាជធានី-ខេត្ត) មានផ្តល់ជូននៅក្នុងតារាងទី១២។

**រូបភាពទី៦៖** ចំនួនមណ្ឌលថែទាំកុមារដែលគ្មានអនុស្សរណៈនៃការយោគយល់ជាមួយស្ថាប័នរដ្ឋាភិបាល បែងចែកទៅតាមរាជធានី-ខេត្ត




រូបភាពទី៦ បង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន៨៧កន្លែងដែលគ្មានអនុស្សរណៈនៃការយោគយល់ ជាមួយរដ្ឋាភិបាល។ រូបភាពនេះបង្ហាញថា មណ្ឌលទាំងនេះភាគច្រើន (៩៧%) ស្ថិតនៅក្នុងរាជធានី-ខេត្ត អាទិភាពទាំង៥។ មណ្ឌលច្រើនបំផុតដែលគ្មានអនុស្សរណៈនៃការយោគយល់ជាមួយរដ្ឋាភិបាល ត្រូវបានរកឃើញថាស្ថិតនៅក្នុងរាជធានីភ្នំពេញ (៦០%) បន្ទាប់មកគឺខេត្តសៀមរាប (២១%) និងខេត្តព្រះសីហនុ (៩%) ដែលបង្ហាញឱ្យឃើញថា ការគ្រប់គ្រងមិនសូវមានប្រសិទ្ធភាពនៅក្នុងរាជធានី-ខេត្តទាំងនេះ។

**តារាងទី១០៖** ចំនួន និងប្រភេទនៃបុគ្គលិកដែលធ្វើការក្នុងមណ្ឌលថែទាំកុមារ

| | | | |
|---|---|---|---|
| បុគ្គលិក (ពេញសិទ្ធិ) | ២,៧១២ | ២,៣៦៧ | សរុប ៥,០៧៩ |
| បុគ្គលិកកិច្ចសន្យា | ៦៥៧ | ៥២៦ | សរុប ១,១៨៣ |
| សរុប | ៣,៣៦៩ | ២,៨៩៣ | ៦,២៦២ |

តារាងទី១០ បង្ហាញថាមានបុគ្គលិកសរុបចំនួន ៦.២៦២នាក់ (៥៩%ជាស្ត្រី) កំពុងបម្រើការងារជាបុគ្គលិកពេញសិទ្ធិ ឬ បុគ្គលិកកិច្ចសន្យា ក្នុងមណ្ឌលថែទាំកុមារទាំង ៤០៦កន្លែង។ ជាមធ្យមមានន័យថាមានបុគ្គលិកពេញសិទ្ធិ ឬ បុគ្គលិកកិច្ចសន្យាចំនួន១នាក់ដែលទទួលបានបៀវត្សរ៍មើលថែកុមារចំនួន៣នាក់ ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ។ បន្ថែមពីនេះទៀត មានបុគ្គលិកចំនួន ៩៦៣នាក់ (៥៥% ជាស្ត្រី) កំពុងធ្វើការងារក្នុងលក្ខណៈមិនផ្លូវការ។

*តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

**តារាងទី១១៖** ចំនួនអ្នកស្ម័គ្រចិត្តដែលកំពុងធ្វើការងារនៅតាមមណ្ឌលថែទាំកុមារ

| | | | |
|---|---|---|---|
| អ្នកស្ម័គ្រចិត្តបរទេស | ១១៩ | ៨០ | ៥៥% សរុប ១៩៩ |
| អ្នកស្ម័គ្រចិត្តកម្ពុជា | ៦៥ | ១០១ | ៤៥% សរុប ១៦៦ |
| សរុប | ១៨៤ | ១៨១ | ៣៦៥ ១០០% |

តារាងទី១១ បង្ហាញថាមានអ្នកស្ម័គ្រចិត្តសរុបចំនួន ៣៦៥នាក់ (៥០%ជាស្ត្រី) កំពុងបម្រើការងារនៅក្នុងមណ្ឌលថែទាំកុមារចំនួន ៤០៦កន្លែង ក្នុងប្រទេសកម្ពុជា។ មានអ្នកស្ម័គ្រចិត្តបរទេសច្រើនជាងអ្នកស្ម័គ្រចិត្តកម្ពុជា (អ្នកស្ម័គ្រចិត្តបរទេសចំនួន៥៥% ធៀបនឹង អ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៤៥%)។ ក្នុងចំណោមរាជធានី ខេត្តទាំង ២៤ ដែលយ៉ាងហោចណាស់មានមណ្ឌលថែទាំកុមារចំនួន១ មានមណ្ឌលនៅក្នុងខេត្តចំនួន៧ (កែប កោះកុង ឧត្តរមានជ័យ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ និង រតនៈគិរី) មិនបានរាយការណ៍ឱ្យដឹងថា មានអ្នកស្ម័គ្រចិត្តបម្រើការងារនៅក្នុងមណ្ឌលទាំងនោះឡើយ។ ដោយឡែក ខេត្តបាត់ដំបង កំពង់ធំ កណ្តាល រាជធានីភ្នំពេញ និង ខេត្តសៀមរាប មានអ្នកស្ម័គ្រចិត្តច្រើនជាងគេ។
រាជធានីភ្នំពេញមានចំនួនអ្នកស្ម័គ្រចិត្តច្រើនជាងគេបង្អស់ (១៥៥នាក់) កំពុងបម្រើការងារនៅតាមមណ្ឌលផ្សេងៗគ្នា ដែលស្មើនឹង ៤២%។

គប្បីកត់សម្គាល់ថា ចំនួនអ្នកស្ម័គ្រចិត្តនឹងមានភាពខុសគ្នាអាស្រ័យទៅលើថា តើគេប្រមូលទិន្នន័យនៅពេលណា។ តួលេខនេះតំណាងឱ្យចំនួនអ្នកស្ម័គ្រចិត្តសរុប ដែលកំពុងបម្រើការងារជូនមណ្ឌលថែទាំកុមារ នៅពេលដែលការកំណត់ទីតាំងមណ្ឌលត្រូវបានធ្វើឡើង។

**តារាងទី១២៖** ចំនួនមណ្ឌលថែទាំកុមារ បែងចែកតាមប្រភេទនៃការគ្រប់គ្រង

| | | | |
|---|---|---|---|
| ភាគរយ | ៧៨% | ២២% | សរុប ១០០% |
| ចំនួន | ៩៨ | ២៨ | សរុប ១២៦ |
| ប្រភេទនៃការគ្រប់គ្រង | គ្រប់គ្រងដំណើរការដោយជនជាតិខ្មែរ | គ្រប់គ្រងដំណើរការដោយជនបរទេស | |

*មានព័ត៌មានចំពោះតែមណ្ឌលថែទាំកុមារចំនួន ១២៦កន្លែង ក្នុងរាជធានី-ខេត្ត ចំនួន២០ប៉ុណ្ណោះ។*

ជនជាតិខ្មែរគឺជាអ្នកគ្រប់គ្រងដំណើរការមណ្ឌលថែទាំកុមារភាគច្រើន ដែលបានផ្តល់ព័ត៌មាននេះ និងតំណាងឱ្យមណ្ឌលចំនួន៧៨% នៃមណ្ឌលចំនួន ១២៦កន្លែង ក្នុងរាជធានី-ខេត្ត ចំនួន២០។ គប្បីកត់សម្គាល់ថា សំណួរនេះមិនបានសួរនៅក្នុងរាជធានី-ខេត្តអាទិភាពទាំង៥ឡើយ ដូច្នេះ ព័ត៌មាននេះមិនអាចយកមកកំណត់ជាទូទៅសម្រាប់ប្រទេសកម្ពុជាឡើយ។

## តារាងទី១៣៖ ចំនួនមណ្ឌលថែទាំកុមារ បែងចែកទៅតាមសាសនា

| | អង្គការសាសនា | មិនមែនអង្គការសាសនា | | |
|---|---|---|---|---|
| ភាគរយ | ៥៤% | ៤៦% | សរុប | ១០០% |
| ចំនួន | ៧៥ | ៦៤ | សរុប | ១៣៩ |

*មានព័ត៌មានចំពោះតែមណ្ឌលថែទាំកុមារចំនួន ១៣៩កន្លែង ក្នុងរាជធានី-ខេត្ត ចំនួន២០ប៉ុណ្ណោះ។*

មានអង្គការសាសនាច្រើនជាង ៥៤% អង្គការមិនមែនលក្ខណៈសាសនា នៅក្នុងរាជធានី-ខេត្តទាំង២០ ដែលបានធ្វើការប្រមូលទិន្នន័យ។ តារាងនេះបង្ហាញថា សាសនាដើរតួនាទីមួយដ៏សំខាន់ក្នុងការផ្ដល់ការថែទាំតាមមណ្ឌលសម្រាប់កុមារកម្ពុជា។ តារាងទី១៤ ផ្ដល់នូវសេចក្ដីលម្អិតអំពីប្រភេទមណ្ឌលសាសនា ដោយបែងចែកទៅតាមរាជធានី-ខេត្ត។

## តារាងទី១៤៖ ចំនួនមណ្ឌលថែទាំកុមារលក្ខណៈសាសនា និង មិនមែនលក្ខណៈសាសនា បែងចែកទៅតាមខេត្ត

| ខេត្ត | សាសនា គ្រិស្ត | សាសនា ព្រះពុទ្ធ | សាសនា អ៊ីស្លាម | មិនមែនអង្គការ សាសនា | សរុប |
|---|---|---|---|---|---|
| បន្ទាយមានជ័យ | ៤ | ០ | ០ | ៥ | ៩ |
| កែប | ០ | ០ | ០ | ១ | ១ |
| កំពង់ចាម | ៥ | ១ | ០ | ២ | ៨ |
| កំពង់ឆ្នាំង | ៩ | ០ | ១ | ៦ | ១៦ |
| កំពង់ស្ពឺ | ៦ | ១ | ០ | ៨ | ១៥ |
| កំពង់ធំ | ១៨ | ០ | ០ | ៥ | ២៣ |
| កំពត | ២ | ០ | ០ | ១៥ | ១៧ |
| កោះកុង | ០ | ០ | ០ | ១ | ១ |
| ក្រចេះ | ៤ | ០ | ១ | ១ | ៦ |
| មណ្ឌលគិរី | ០ | ០ | ០ | ១ | ១ |
| ឧត្ដរមានជ័យ | ៣ | ០ | ០ | ១ | ៤ |
| ប៉ៃលិន | ៣ | ០ | ០ | ១ | ៤ |
| ព្រះវិហារ | ១ | ២ | ០ | ០ | ៣ |
| ព្រៃវែង | ៣ | ០ | ០ | ៣ | ៦ |
| ពោធិ៍សាត់ | ១ | ១ | ០ | ៣ | ៥ |
| រតនគិរី | ១ | ០ | ០ | ២ | ៣ |
| ស្ទឹងត្រែង | ១ | ០ | ០ | ២ | ៣ |
| ស្វាយរៀង | ០ | ៣ | ០ | ៤ | ៧ |
| តាកែវ | ៣ | ០ | ១ | ៣ | ៧ |
| ត្បូងឃ្មុំ | ០ | ០ | ០ | ០ | ០ |
| សរុប | ៦៤ | ៨ | ៣ | ៦៤ | ១៣៩ |

*មានទិន្នន័យសម្រាប់តែខេត្តចំនួន២០ប៉ុណ្ណោះ។*

តារាងទី១៤ បង្ហាញថាអង្គការសាសនាភាគច្រើនគឺជាអង្គការសាសនាគ្រិស្ត (៨៥%) បន្ទាប់មកគឺសាសនាព្រះពុទ្ធ (១១%) និង សាសនាអ៊ីស្លាម (៤%)។ បើទោះជាដូច្នេះក្តី គួរកត់សម្គាល់ថា ប្រទេសកម្ពុជាគឺជាប្រទេសកាន់សាសនាព្រះពុទ្ធ ហើយការកំណត់ទីតាំងកន្លែងថែទាំកុមារបានបង្ហាញឱ្យដឹងថា មានវត្តអារាមជាច្រើនដែលផ្តល់ការថែទាំកុមារ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារបានរកឃើញវត្តអារាមសរុបចំនួន៦៥ នៅក្នុងរាជធានី-ខេត្តទាំង២៥ ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងផ្តល់ការថែទាំកុមារចំនួន ១.៣៤៩នាក់ (៥០%ជាកុមារី) ដែលភាគច្រើនគឺជាសាសនាព្រះពុទ្ធ (មិនដឹងតួលេខពិតប្រាកដ)។ តារាងនេះបន្តបង្ហាញឱ្យ ដឹងទៀតថា មណ្ឌលថែទាំកុមារភាគច្រើនដែលពុំមែនជាមណ្ឌលសាសនា ស្ថិតនៅខេត្តកំពត (២៣%)។ មណ្ឌលសាសនាភាគច្រើនស្ថិតនៅខេត្តកំពង់ធំ(២៤%)ដែលមណ្ឌលទាំងនេះសុទ្ធសឹងតែជាមណ្ឌល សាសនាគ្រិស្ត។

## ៤.៣ គំហើញអំពីកុមារដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ

ព័ត៌មានអំពីកុមារដែលរស់នៅក្នុងមណ្ឌល គឺជាព័ត៌មានស្វ័យរាយការណ៍ពីបុគ្គលិក ឬ បុគ្គលដទៃទៀតដែលទទួលខុសត្រូវក្នុងមណ្ឌល និង មិនមែនផ្អែកលើការរាប់ចំនួនកុមារដែលរស់នៅក្នុងមណ្ឌលដោយផ្ទាល់ឡើយ។

**តារាងទី១៥៖** ចំនួនកុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ ផ្អែកលើសេចក្តីរាយការណ៍ពីមណ្ឌល

| | | | | |
|---|---|---|---|---|
| ភាគរយ | ៤៧ | ៥៣ | សរុប | ១០០% |
| ចំនួន | ៧.៧៧៦ | ៨.៨០៣ | | ១៦.៥៧៩ |

តារាងទី១៥ បង្ហាញថាមានកុមារចំនួន ១៦.៥៧៩នាក់ អាយុក្រោម ១៨ឆ្នាំ ត្រូវបានរាយការណ៍ឱ្យដឹងថា កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន ៤០៦កន្លែង ទូទាំងប្រទេសកម្ពុជា។ ក្នុងនោះរួមមានកុមារាចំនួន ៨.៨០៣នាក់
(៥៣%) និង កុមារីចំនួន ៧.៧៧៦នាក់ (៤៧%)។ ចំនួននេះខ្ពស់ជាងការប៉ាន់ប្រមាណរបស់ រដ្ឋាភិបាលកន្លងមក ដោយផ្អែកលើរបាយការណ៍អធិការកិច្ចឆ្នាំ២០១៥ ថាមានកុមារចំនួន ១១.១៧១នាក់ (៤៧% ជាកុមារី) រស់នៅក្នុងមណ្ឌលថែទាំកុមារ។ ចំណុចនេះបង្ហាញថា មានកុមារចំនួនមួយភាគបីនៅក្នុងមណ្ឌលថែទាំ កំពុងរស់នៅក្រោមការថែទាំដែលគ្មានការគ្រប់គ្រងត្រឹមត្រូវ និង ពុំមានការត្រួតពិនិត្យពី រដ្ឋាភិបាលដែលជាហេតុធ្វើឱ្យពួកគេអាចប្រឈមទៅនឹងហានិភ័យនានា។

## តារាងទី១៦៖ ចំនួនកុមាររស់នៅតាមមណ្ឌល បែងចែកទៅតាមរាជធានី-ខេត្ត (តាមលំដាប់លំដោយពីច្រើនមកតិច)

| រាជធានីខេត្ត | | | |
|---|---|---|---|
| ភ្នំពេញ | ៣.១៦៤ | ៣.០៧៧ | ៦.២៤១ |
| សៀមរាប | ១.០១៩ | ១.១២៩ | ២.១៤៨ |
| បាត់ដំបង | ៦៩១ | ៧៧៧ | ១.៤៦៨ |
| កំពង់ធំ | ៣៣៤ | ៧៣៥ | ១.០៦៩ |
| កណ្តាល | ៣៩៩ | ៤៦៣ | ៨៦២ |
| កំពត | ៣៦៥ | ៤៦៥ | ៨៣០ |
| កំពង់ឆ្នាំង | ៣៨៥ | ៤២៦ | ៨១១ |
| ព្រះសីហនុ | ២៧៨ | ២៩៥ | ៥៧៣ |
| កំពង់ស្ពឺ | ១៨៤ | ១៨១ | ៣៦៥ |
| បន្ទាយមានជ័យ | ១៤៩ | ១៨១ | ៣៣០ |
| កំពង់ចាម | ១៣១ | ១៨២ | ៣១៣ |
| ស្វាយរៀង | ១១១ | ១១៤ | ២២៥ |
| តាកែវ | ៩៣ | ១០៣ | ១៩៦ |
| ក្រចេះ | ៥៦ | ១២០ | ១៧៦ |
| ព្រៃវែង | ៧៥ | ៨៧ | ១៦២ |
| ពោធិ៍សាត់ | ៧៣ | ៧៩ | ១៥២ |
| ឧត្តរមានជ័យ | ៦២ | ៨៥ | ១៤៧ |
| ប៉ៃលិន | ៥១ | ៨២ | ១៣៣ |
| ព្រះវិហារ | ៤៩ | ៧៤ | ១២៣ |
| រតនគិរី | ៣២ | ៦២ | ៩៤ |
| ស្ទឹងត្រែង | ៣៣ | ២១ | ៥៤ |
| កែប | ២៨ | ២៦ | ៥៤ |
| កោះកុង | ១៣ | ២៨ | ៤១ |
| មណ្ឌលគិរី | ១ | ១១ | ១២ |
| ត្បូងឃ្មុំ | 0 | 0 | 0 |
| សរុប | ៧.៧៧៦ | ៨.៨០៣ | ១៦.៥៧៩ |

- ខេត្តអាទិភាពបច្ចុប្បន្ន
- ខេត្តផ្សេងទៀតដែលមានមណ្ឌលថែទាំកុមារក្នុងចំនួនច្រើន

តារាងទី១៦ បង្ហាញអំពីចំនួនសរុបកុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំ។ តារាងនេះបង្ហាញថា កុមារទាំងនេះភាគច្រើន រស់នៅក្នុងរាជធានី-ខេត្តទាំង៩ ដែលត្រូវបានកត់ត្រាថាមានចំនួនមណ្ឌលច្រើនជាងគេបំផុត។ ក្នុងចំណោមកុមារសរុប មានកុមារចំនួន ៨៧% ឬ កុមារចំនួន ១៤.៣៦៧នាក់ ស្ថិតនៅក្នុងរាជធានីខេត្តទាំង៩នេះ។ បើទោះបីជាចំនួនមណ្ឌល និង ចំនួនកុមារ មិនត្រូវគ្នាទាំងស្រុងនៅក្នុងបណ្តារាជធានី-ខេត្តទាំងនេះក៏ដោយ ក៏រាជធានីភ្នំពេញ ខេត្តសៀមរាប និងបាត់ដំបង គឺជារាជធានី-ខេត្តដែលត្រូវបានរាយការណ៍ឱ្យដឹងថា មានចំនួនមណ្ឌល និង កុមារច្រើនជាងគេ។ ទិន្នន័យនេះក៏បង្ហាញឱ្យដឹងផងដែរថា រាជធានី-ខេត្តអាទិភាពទាំង៥ មានកុមារច្រើនជាងគេបង្អស់ រហូតដល់ ១១.៧៨៨នាក់ ឬ ស្មើនឹង៧១% នៃចំនួនកុមារសរុបបើទោះបីជារាជធានីខេត្តទាំងនេះ ពុំមានចំនួនមណ្ឌលច្រើនជាងគេបំផុតក៏ដោយ។ ស្រដៀងគ្នាទៅនឹងចំនួនមណ្ឌលដែរ គ្រាន់តែរាជធានីភ្នំពេញ និង ខេត្តសៀមរាបតែឯង មានកុមារចំនួន៥១% ឬ កុមារ ៨.៣៨៩នាក់ ក្នុងចំណោមកុមារសរុបទៅហើយ។

## តារាងទី១៧៖ ចំនួនកុមារដែលកំពុងរស់នៅក្នុងមណ្ឌល បែងចែកតាមរយៈពេល

| ប្រភេទមណ្ឌលថែទាំកុមារ | | | | % |
|---|---|---|---|---|
| លើសពី ៦ខែ — មណ្ឌលថែទាំកុមារដែលផ្តល់ការថែទាំរយៈពេលវែង (លើសពី៦ខែ) | ៤.៥២២ | ៥.៦០៤ | ១០.១២៦ | ៦១% |
| តិចជាង ៦ខែ — មណ្ឌលថែទាំកុមារដែលផ្តល់ការថែទាំរយៈពេលខ្លី (តិចជាង៦ខែ) | ៦៨៥ | ៧៦៧ | ១.៤៥២ | ៩% |
| NO — គ្មានការបញ្ជាក់ច្បាស់លាស់អំពីរយៈពេលជាមធ្យមនៃការថែទាំដែលផ្តល់ជូន | ២.៦១៥ | ២.៣៨៦ | ៥.០០១ | ៣០% |
| សរុប | ៧.៨២២ | ៨.៧៥៧ | ១៦.៥៧៩ | ១០០% |

តារាងទី១៧ បង្ហាញថា ក្នុងចំណោមកុមារចំនួន ១៦.៥៧៩នាក់ ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់ នៅក្នុងមណ្ឌលថែទាំកុមារក្នុងរាជធានី-ខេត្តទាំង៥។ កុមារភាគច្រើន (៦១%) កំពុងរស់នៅក្នុងមណ្ឌលដែលផ្តល់ការថែទាំរយៈពេលវែង ហើយមានតែ ៩% ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងមណ្ឌលដែលផ្តល់ការថែទាំរយៈពេលខ្លី។ រយៈពេលរស់នៅក្នុងមណ្ឌលសម្រាប់កុមារ ចំនួន៣០%ទៀត ពុំមានការបញ្ជាក់ច្បាស់លាស់ឡើយ។ អត្រាភាគរយនៃកុមារដែលកំពុងរស់នៅក្នុងមណ្ឌលក្រោមការថែទាំរយៈពេលវែង (៦១%) មានចំនួនតិចជាងអត្រាភាគរយនៃមណ្ឌលដែលផ្តល់ការថែទាំរយៈពេលវែង (៧២%)។ តាមរយៈការប្រៀបធៀបបានឱ្យដឹងថា កុមារដែលត្រូវបានរកឃើញថាកំពុងរស់នៅក្នុងមណ្ឌលដែលគ្មានបញ្ជាក់អំពីរយៈពេលនៃការថែទាំ មានចំនួនច្រើនជាងមណ្ឌលដែលគ្មានបញ្ជាក់អំពីរយៈពេល នៃការថែទាំ (មណ្ឌលដែលគ្មានការបញ្ជាក់អំពីរយៈពេលនៃការថែទាំចំនួន២២% ធៀបនឹងកុមារចំនួន៣០% ដែលកំពុងរស់នៅក្នុងមណ្ឌលដែលគ្មានការបញ្ជាក់អំពីរយៈពេលនៃការថែទាំ)។

រាជធានី-ខេត្តចំនួន៤ មានចំនួនកុមារច្រើនគួរឱ្យកត់សម្គាល់ (កុមារជាង១.០០០នាក់) កំពុងរស់នៅក្នុងមណ្ឌលដែលផ្តល់ការថែទាំរយៈពេលវែង។ រាជធានី-ខេត្តទាំងនេះរួមមាន ខេត្តសៀមរាប(១.៧៨១នាក់) រាជធានីភ្នំពេញ (១.៤៥១នាក់) ខេត្តបាត់ដំបង (១.២៦៩នាក់) និងខេត្តព្រះសីហនុ (១.០៦៩នាក់)។ គប្បីកត់សម្គាល់ថា បើទោះបីជាខេត្តព្រះសីហនុមានលំដាប់លេខរៀងទី៨ ក្នុងចំណោមបណ្តារាជធានី-ខេត្តដែល មានចំនួនមណ្ឌលច្រើនក៏ដោយ ប៉ុន្តែខេត្តនេះមានលំដាប់លេខរៀងខ្ពស់ជាង (លេខរៀងទី៤) ចំពោះចំនួនកុមារដែលរស់នៅក្រោមការថែទាំរយៈពេលវែង ដោយមានចំនួនរហូតដល់ ១.០៦៩នាក់។ បើទោះបីជារាជធានីភ្នំពេញមានចំនួនមណ្ឌលច្រើនជាងគេក៏ដោយ ប៉ុន្តែខេត្តសៀមរាបមានមណ្ឌលថែទាំកុមាររយៈពេលវែងច្រើនជាងគេ ព្រមទាំងមានចំនួនកុមាររស់នៅក្នុងមណ្ឌលទាំងនោះច្រើនជាងគេផងដែរ។

**តារាងទី១៨៖** ចំនួនកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារ បែងចែកទៅតាមអាយុ នៅក្នុងខេត្តទាំង២០

| អាយុ | | | | % |
|---|---|---|---|---|
| 0-3 ឆ្នាំ | ២៧ | ៥៣ | ៨០ | ២% |
| 4-10 ឆ្នាំ | ៦០៣ | ៩១២ | ១.៥១៥ | ៣២% |
| 11-17 ឆ្នាំ | ១.៥៣៩ | ១.៦៥៧ | ៣.១៩៦ | ៦៧% |
| សរុប | ២.១៦៩ | ២.៦២២ | ៤.៧៩១ | ១០០% |

*មានទិន្នន័យសម្រាប់តែខេត្តចំនួន២០ប៉ុណ្ណោះ។ តម្លៃនីមួយៗបូកបញ្ចូលគ្នាមិនទទួលបានតម្លៃសរុប១០០%ឡើយ ដោយសារតែការកំណត់ទាញយកលេខគត់។*

តារាងទី១៨ បង្ហាញថាកុមារភាគច្រើនដែលកំពុងរស់នៅក្នុងមណ្ឌល ស្ថិតក្នុងវ័យសិក្សានៅឯសាលារៀន ក្នុងនោះ ៦៧% មានអាយុចន្លោះពី១១ឆ្នាំ ទៅ ១៧ឆ្នាំ និង ៣២% មានអាយុចន្លោះពី ៤ឆ្នាំ ទៅ ១០ឆ្នាំ។ កុមារដែលមានអាយុចន្លោះពី ០ឆ្នាំ ទៅ ៣ឆ្នាំ មានចំនួនប្រមាណ ២%។

**តារាងទី១៩៖** ចំនួនកុមារដែលកំពុងរស់នៅក្នុងមណ្ឌល បែងចែកទៅតាមអាយុ និង ខេត្ត

| | ០-៣ ឆ្នាំ | | ៤-១០ ឆ្នាំ | | ១១-១៧ ឆ្នាំ | | សរុប | |
|---|---|---|---|---|---|---|---|---|
| ខេត្ត | សរុប | កុមារី | សរុប | កុមារី | សរុប | កុមារី | សរុប | កុមារី |
| បន្ទាយមានជ័យ | ៣ | ១ | ៩៥ | ៣៧ | ២៣២ | ១១១ | ៣៣០ | ១៤៩ |
| កែប | ០ | ០ | ១១ | ៣ | ៣០ | ១០ | ៤១ | ១៣ |
| កំពង់ចាម | ០ | ០ | ១២៤ | ៣៦ | ១៨៩ | ៩៥ | ៣១៣ | ១៣១ |
| កំពង់ឆ្នាំង | ៧ | ៣ | ៨១ | ៣៤ | ២៧៧ | ១៤៧ | ៣៦៥ | ១៨៤ |
| កំពង់ស្ពឺ | ១៦ | ៤ | ៣១៣ | ១១៩ | ៥០១ | ២៤២ | ៨៣០ | ៣៦៥ |
| កំពង់ធំ | ៦ | ២ | ១៤៧ | ៥៤ | ៤២០ | ២២២ | ៥៧៣ | ២៧៨ |
| កំពត | ១០ | ៥ | ២៩៥ | ១៥០ | ៥០៦ | ២៣០ | ៨១១ | ៣៨៥ |
| កោះកុង | ០ | ០ | ០ | ០ | ១២ | ១ | ១២ | ១ |
| ក្រចេះ | ៣ | ១ | ២៩ | ១៣ | ១៤៤ | ៤២ | ១៧៦ | ៥៦ |
| មណ្ឌលគិរី | ០ | ០ | ៥ | ២ | ៤៩ | ៣១ | ៥៤ | ៣៣ |
| ឧត្តរមានជ័យ | ៥ | ២ | ៤៦ | ១៩ | ៤៣ | ១១ | ៩៤ | ៣២ |
| ប៉ៃលិន | ១ | ១ | ៦១ | ១៤ | ៦១ | ៣៤ | ១២៣ | ៤៩ |
| ព្រះវិហារ | ០ | ០ | ៥៩ | ២៦ | ១០៣ | ៤៩ | ១៦២ | ៧៥ |
| ព្រៃវែង | ២ | ១ | ៥៦ | ២២ | ១៦៧ | ៨៨ | ២២៥ | ១១១ |
| ពោធិ៍សាត់ | ០ | ០ | ៣១ | ១១ | ១២១ | ៦២ | ១៥២ | ៧៣ |
| រតនគិរី | ៣ | ០ | ៦៧ | ២៧ | ៧៧ | ៣៥ | ១៤៧ | ៦២ |
| ស្ទឹងត្រែង | ៥ | ២ | ១៣ | ៤ | ៣៦ | ២២ | ៥៤ | ២៨ |
| ស្វាយរៀង | ០ | ០ | ៣៥ | ១០ | ៩៨ | ៤១ | ១៣៣ | ៥១ |
| តាកែវ | ១៩ | ៥ | ៤៧ | ២២ | ១៣០ | ៦៦ | ១៩៦ | ៩៣ |
| ត្បូងឃ្មុំ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ៨០ | ២៧ | ១.៥១៥ | ៦០៣ | ៣.១៩៦ | ១.៥៣៩ | ៤.៧៩១ | ២.១៦៩ |

*មានទិន្នន័យសម្រាប់តែខេត្តចំនួន២០ប៉ុណ្ណោះ។*

តារាងទី១៩ បង្ហាញថាក្នុងចំណោមខេត្តទាំង២០ មានខេត្តចំនួន៣ ដែលមានកុមារជាង ៥៦% ដែលមានអាយុចន្លោះពី ០ឆ្នាំ ទៅ ៣ឆ្នាំ។ ខេត្តទាំងនេះរួមមាន ខេត្តតាកែវ (១៩) កំពង់ស្ពឺ (១៦) និងកំពត (១០)។ កុមារគ្រប់រូបនៅក្នុងក្រុមអាយុនេះ ត្រូវបានរកឃើញថាកំពុងរស់នៅក្នុងកន្លែងថែទាំកុមាររយៈពេលវែង។ ចំណុចនេះគប្បីត្រូវបានមើលឃើញនៅក្នុងបរិបទដែលការស្រាវជ្រាវបង្ហាញថា ការរស់នៅក្នុងមណ្ឌល បង្កការខូចខាតកាន់តែធ្ងន់ធ្ងរចំពោះកុមារដែលមានអាយុក្រោម៣ឆ្នាំ។

**តារាងទី២០៖** ចំនួនកុមារត្រូវការកិច្ចគាំទ្រពិសេស[១៩] ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ

| ប្រភេទសេចក្តីត្រូវការពិសេស |  |  |  |
|---|---|---|---|
| កុមារពិការ | ៤០៣ | ៥២២ | ៩២៥ |
| កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ | ២៣៦ | ៣៤០ | ៥៧៦ |
| កុមារដែលបានទទួលសេវាបន្សាបគ្រឿងញៀន | ១៧៤ | ៩៦ | ២៧០ |
| កុមាររងគ្រោះនៃអំពើជួញដូរ | ២០១ | ៥១ | ២៥២ |

តារាងទី២០ បង្ហាញអំពីចំនួនកុមារត្រូវការកិច្ចគាំទ្រពិសេស ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងរស់នៅក្នុងមណ្ឌល[២០]។ ទិន្នន័យនេះបង្ហាញថា កុមារភាគច្រើនដែលត្រូវការកិច្ចគាំទ្រពិសេស គឺជាកុមារពិការ[២១] និងបន្ទាប់មកគឺកុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។ កុមារពិការមានចំនួន ៩២៥នាក់ (៤៤%ជាកុមារី) ដោយឡែកកុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍មានចំនួន ៥៧៦នាក់ (៤១%ជាកុមារី) និងកុមារដែលបានទទួលសេវាបន្សាបគ្រឿងញៀន មានចំនួន ២៧០នាក់ (៦៤%ជាកុមារី) និង កុមាររងគ្រោះនៃអំពើជួញដូរ មានចំនួន ២៥២នាក់ (៨០%ជាកុមារី)។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ មានកុមារីច្រើនជាងកុមារា ដែលត្រូវបានរកឃើញថាជាជនរងគ្រោះនៃអំពើជួញដូរ។ យោងតាមសេចក្តីរាយការណ៍ក៏បានឱ្យដឹងផងដែរថា មានកុមារីច្រើនជាងកុមារាទទួលបានសេវាបន្សាបគ្រឿងញៀន។ តារាងទី២១ ផ្តល់នូវទិន្នន័យអំពីចំនួនកុមារ ដែលត្រូវការកិច្ចគាំទ្រពិសេស ដោយបែងចែកទៅតាមខេត្តផ្សេងៗគ្នា។

[១៩] សម្រាប់គោលបំណងនៃរបាយការណ៍នេះ កុមារដែលត្រូវការកិច្ចគាំទ្រពិសេសរួមមានកុមារពិការ កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ កុមារដែលបានទទួលសេវាបន្សាបគ្រឿងញៀន និង កុមាររងគ្រោះនៃអំពើជួញដូរ។

[២០] មិនមែនកុមារគ្រប់រូបដែលត្រូវការកិច្ចគាំទ្រពិសេស និងកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ អាចទទួលបានកិច្ចគាំទ្រពិសេសឡើយ។ មណ្ឌលមួយចំនួនពិតជាមានការផ្តោតយកចិត្តទុកដាក់លើការថែទាំពិសេស ប៉ុន្តែការកំណត់ទីតាំងកន្លែងថែទាំកុមារមិនបានប្រមូលទិន្នន័យនេះឡើយ។

[២១] ពិការភាពមិនត្រូវបានធ្វើការបែងចែកទៅតាមប្រភេទឡើយ។

**តារាងទី២១៖** ចំនួនកុមារត្រូវការកិច្ចគាំទ្រពិសេសដែលកំពុងរស់នៅក្នុងមណ្ឌលបែងចែកទៅតាមភេទ និងរាជធានី-ខេត្ត

| រាជធានីខេត្ត | កុមារពិការ | | កុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ | | កុមារដែលបានទទួលសេវាបន្សាបគ្រឿងញៀន | | កុមាររងគ្រោះនៃអំពើជួញដូរ | |
|---|---|---|---|---|---|---|---|---|
| | សរុប | កុមារី | សរុប | កុមារី | សរុប | កុមារី | សរុប | កុមារី |
| បន្ទាយមានជ័យ | ០ | ០ | ០ | ០ | ០ | ០ | ៨ | ១ |
| បាត់ដំបង | ១៣ | ៥ | ១៣ | ៧ | ៥៤ | ៤៣ | ៣២ | ១៦ |
| កែប | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| កំពង់ចាម | ១៨២ | ៧៥ | ៧ | ៥ | ០ | ០ | ១៣ | ១៣ |
| កំពង់ឆ្នាំង | ៨១ | ៤៤ | ១១ | ៣ | ១១ | ២ | ០ | ០ |
| កំពង់ស្ពឺ | ៤ | ២ | ១៥៤ | ៦១ | ០ | ០ | ០ | ០ |
| កំពង់ធំ | ១២ | ៦ | ២ | ១ | ០ | ០ | ១ | ០ |
| កំពត | ៧៤ | ៣២ | ៤ | ១ | ០ | ០ | ០ | ០ |
| កណ្តាល | ៤៨ | ២៨ | ២៧ | ១២ | ១៣ | ៩ | ០ | ០ |
| ក្រចេះ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| មណ្ឌលគិរី | ២ | ១ | ០ | ០ | ០ | ០ | ១ | ១ |
| ប៉ៃលិន | ០ | ០ | ១ | ១ | ០ | ០ | ០ | ០ |
| ភ្នំពេញ | ៣៩៨ | ១៦៨ | ២៤១ | ៩៩ | ១៧៩ | ១១៧ | ១៥៦ | ១៤៣ |
| ព្រះសីហនុ | ៤ | ២ | ៤៩ | ២៦ | ០ | ០ | ៦ | ០ |
| ព្រៃវែង | ១ | ១ | ០ | ០ | ០ | ០ | ០ | ០ |
| សៀមរាប | ៣៤ | ៩ | ៣៤ | ៨ | ១២ | ៣ | ៣០ | ២៤ |
| ស្វាយរៀង | ១ | ១ | ២ | ១ | ០ | ០ | ៥ | ៣ |
| តាកែវ | ៦៩ | ២៩ | ៣១ | ១១ | ១ | ០ | ០ | ០ |
| សរុប | ៩២៥ | ៤០៣ | ៥៧៦ | ២៣៦ | ២៧០ | ១៧៤ | ២៥២ | ២០១ |

*សម្គាល់៖ កុមារម្នាក់អាចមានសេចក្តីត្រូវការពិសេសលើសពីមួយ។*

តារាងទី២១ បង្ហាញថា យ៉ាងហោចណាស់រាជធានី-ខេត្តចំនួន១៨ មានកុមារដែលមានសេចក្តីត្រូវការពិសេស យ៉ាងតិចមួយប្រភេទរស់នៅក្នុងមណ្ឌល។

មានកុមារពិការចំនួន ៩២៥នាក់ (កុមារីចំនួន ៤៤%) កំពុងរស់នៅក្នុងមណ្ឌល នៅក្នុងរាជធានី-ខេត្តចំនួន១៦ ក្នុងនោះ៧២% ស្ថិតនៅក្នុងរាជធានី-ខេត្តទាំង៩ ដែលរកឃើញថាមានការប្រមូលផ្តុំមណ្ឌលច្រើនជាងគេ។ បើទោះជាដូច្នេះក្តី ក្នុងចំណោមខេត្តដែលនៅសេសសល់ ដូចជាខេត្តតាកែវ និង ខេត្តកំពង់ចាម ដែលមានមណ្ឌលថែទាំកុមារក្នុងចំនួនទាប (ខេត្តតាកែវចំនួន ៧មណ្ឌល និង ខេត្តកំពង់ចាមចំនួន ៨មណ្ឌល) បែរជាមានចំនួនកុមារពិការច្រើនគួរឱ្យកត់សម្គាល់ ដោយខេត្តទាំងពីរនេះមានកុមារពិការចំនួន ២៧% នៃចំនួនកុមារពិការសរុបដែលរស់នៅក្នុងមណ្ឌល។ ចំនួនកុមារពិការក៏មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ទៅតាមរាជធានី-ខេត្តផ្សេងៗគ្នាផងដែរ ដោយកុមារពិការច្រើនបំផុតត្រូវបានកត់ត្រាថាស្ថិតនៅរាជធានីភ្នំពេញ (ដែលមានកុមារពិការចំនួន ៣៩៨នាក់ ឬ ៤៣% នៃចំនួនកុមារពិការសរុប) បន្ទាប់មក គឺខេត្តកំពង់ចាម (កុមារពិការចំនួន ១៨២នាក់ ឬ ២០% នៃចំនួនកុមារពិការសរុប) និងទាបបំផុត (កុមារពិការចន្លោះពី១នាក់ ទៅ ៤នាក់) ត្រូវបានកត់ត្រាថាស្ថិតនៅក្នុងខេត្តចំនួន៧។

មានកុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ចំនួន ៥៧៦នាក់ (កុមារីចំនួន៤១%) កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារក្នុងរាជធានី-ខេត្តចំនួន១៣ ដោយពួកគេចំនួន ៩៣% ស្ថិតនៅក្នុងរាជធានី-ខេត្តទាំង៩ ដែលត្រូវបានរកឃើញ

ថាមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារច្រើនបំផុត។ រាជធានីភ្នំពេញមានកុមារប្រភេទនេះច្រើនបំផុត ដែលស្មើនឹង៤២%នៃចំនួនកុមារសរុបដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។ ចំពោះខេត្តដែលនៅសេសសល់ដទៃទៀត ខេត្តតាកែវបានកត់ត្រាថាមានចំនួនកុមារផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ចំនួន៣១% ដែលខ្ពស់ជាងខេត្តដទៃទៀតគួរឱ្យកត់សម្គាល់។

មានកុមារចំនួន២៧០នាក់ (កុមារីចំនួន៦៤%) ដែលបានទទួលសេវា បន្សាបគ្រឿងញៀន ក្នុងរាជធានី-ខេត្តចំនួន៦។ រាជធានី-ខេត្តទាំង៦នេះ សុទ្ធសឹងតែស្ថិតនៅក្នុងបណ្តារាជធានី-ខេត្ត ដែលត្រូវបានរកឃើញថាមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារច្រើនជាងគេ លើកលែងតែខេត្តមួយប៉ុណ្ណោះ។ រាជធានីភ្នំពេញ មានចំនួនកុមារបែបនេះខ្ពស់ជាងគេបំផុតស្មើនឹង៦៦%នៃចំនួនកុមារសរុប ដែលបានទទួលសេវាបន្សាបគ្រឿងញៀន។

មានកុមាររងគ្រោះនៃអំពើជួញដូរ ចំនួន២៥២នាក់ (កុមារីចំនួន៨០%) ក្នុងរាជធានី-ខេត្តចំនួន៩។ រាជធានីភ្នំពេញមានចំនួនកុមារបែបនេះខ្ពស់ជាងគេ ស្មើនឹង៦២% នៃចំនួនកុមាររងគ្រោះនៃអំពើជួញដូរសរុប។

ទិន្នន័យបង្ហាញឱ្យឃើញអំពីរបាយមិនស្មើគ្នានៃកុមារមានសេចក្តីត្រូវការពិសេស ដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ដោយមានរាជធានី-ខេត្តមួយចំនួនតូចប៉ុណ្ណោះ ដែលបានកត់ត្រាថាកុមារបែបនេះមានចំនួនច្រើន។ រាជធានីភ្នំពេញ មានកុមារដែលមានសេចក្តីត្រូវការពិសេសផ្សេងៗគ្នាច្រើនជាងគេ កំពុងរស់នៅក្នុងមណ្ឌល។

## ៤.៤ គំហើញអំពីកន្លែងថែទាំកុមារប្រភេទដទៃទៀត និងកុមារដែលកំពុងរស់នៅកន្លែងទាំងនោះ

ដូចបានធ្វើការគូសបញ្ជាក់ពីខាងដើម ការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ ផ្តោតលើទិន្នន័យអំពីមណ្ឌលថែទាំកុមារ ("មណ្ឌលកុមារកំព្រា")។ ដូច្នេះព័ត៌មានមានកម្រិតចំពោះប្រភេទកន្លែងថែទាំកុមារដទៃទៀត។ កន្លែងថែទាំកុមារប្រភេទដទៃទៀតដែលត្រូវបានកត់ត្រា មានចំនួន ២៣៣កន្លែង (ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន, ផ្ទះស្នាក់នៅជាក្រុម, អន្តេវាសិកដ្ឋាន វត្តអារាម និងអគារសាសនាដទៃទៀត ដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ) ដែលមានចំនួនស្មើនឹង ៣៦%នៃកន្លែងថែទាំកុមារសរុប។ លក្ខណៈមូលដ្ឋាននៃកន្លែងទាំងនេះ មានរៀបរាប់ខាងក្រោម ៖

### ៤.៤.១ គំហើញអំពីផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន ព្រមទាំងកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ

**តារាងទី២២៖** ចំនួនផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន ព្រមទាំងកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ (តាមលំដាប់លំដោយពីច្រើនមកតិច)

| រាជធានី-ខេត្ត | ចំនួនផ្ទះស្នាក់នៅបណ្តោះអាសន្ន | | | |
|---|---|---|---|---|
| ភ្នំពេញ | ១៤ | ២២៤ | ១០៨ | ៣៣២ |
| បន្ទាយមានជ័យ | ៥ | ៦៦ | ៥២ | ១១៨ |
| ព្រះសីហនុ | ២ | ៤១ | ៨៩ | ១៣០ |
| កណ្តាល | ២ | ១០ | ១៩ | ២៩ |
| សៀមរាប | ១ | ៦ | ១០ | ១៦ |
| តាកែវ | ១ | ១ | ២ | ៣ |
| សរុប | ២៥ | ៣៤៨ | ២៨០ | ៦២៨ |

ផ្ទះស្នាក់នៅបណ្ដោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្ន គឺជាទម្រង់មួយនៃមណ្ឌលថែទាំកុមារដែលរយៈពេលស្នាក់នៅមានកំណត់។ កន្លែងបែបនេះគឺសម្រាប់កុមារដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំផែនការគ្រួសារអចិន្ត្រៃយ៍ ឬ កុមារដែលគ្រួសារកំពុងជួបប្រទះវិប័ត្តិធ្ងន់ធ្ងរ និង ទាមទារឱ្យមានការផ្ដល់លំនៅដ្ឋានបណ្ដោះអាសន្នសម្រាប់ពួកគេ ដើម្បីធ្វើឱ្យបរិយាកាសគ្រួសារមានលំនឹងឡើងវិញ។

រាជធានី-ខេត្តចំនួន៦ ក្នុងចំណោម២៥ មានផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្ដោះ-អាសន្ន។ តារាងទី២២ បង្ហាញថាមានកន្លែងបែបនេះចំនួន ២៥ នៅក្នុងប្រទេសកម្ពុជាដែលផ្ដល់ការថែទាំជំនួស សម្រាប់កុមារសរុបចំនួន ៦២៨នាក់ (កុមារីចំនួន៥៥%)។ មណ្ឌលបែបនេះភាគច្រើន (៥៦%) ស្ថិតនៅរាជធានីភ្នំពេញ និងបន្ទាប់មកគឺខេត្តបន្ទាយមានជ័យ (២០%) ខេត្តព្រះសីហនុ (៨%) និងខេត្តកណ្ដាល (៨%)។ ភ្នំពេញក៏មានចំនួនកុមារស្នាក់នៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្ន និង កន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្ន (៥៣%) បន្ទាប់មកគឺព្រះសីហនុ(២១%) និងបន្ទាយមានជ័យ១៩%។

## ៤.៤.២ គំហើញអំពីផ្ទះស្នាក់នៅជាក្រុម និងកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ

**តារាងទី២៣៖** ចំនួនផ្ទះស្នាក់នៅជាក្រុម និង ចំនួនកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ

| រាជធានីខេត្ត | ចំនួនផ្ទះស្នាក់នៅជាក្រុម (តាមលំដាប់លំដោយពីច្រើនមកតិច) | | | |
|---|---|---|---|---|
| បាត់ដំបង | ១៩ | ៥៤ | ៧២ | ១២៦ |
| ភ្នំពេញ | ១៧ | ២៤៣ | ១៧៩ | ៤២២ |
| សៀមរាប | ១៤ | ៧៩ | ៦១ | ១៤០ |
| កំពង់ចាម | ៦ | ៣០ | ១១ | ៤១ |
| កណ្ដាល | ៥ | ៨៥ | ៧១ | ១៥៦ |
| ព្រះសីហនុ | ២ | ២០១ | ២៤៧ | ៤៤៨ |
| កំពង់ឆ្នាំង | ១ | ១០ | ១០ | ២០ |
| កំពង់ធំ | ១ | ៧ | ៧ | ១៤ |
| កំពត | ១ | ៩ | ៦ | ១៥ |
| ក្រចេះ | ១ | ៤៨ | ៦២ | ១១០ |
| ប៉ៃលិន | ១ | ៨ | ១ | ៩ |
| ព្រៃវែង | ១ | ៥ | ៤ | ៩ |
| ពោធិ៍សាត់ | ១ | ២ | ៥ | ៧ |
| តាកែវ | ១ | ៣៩ | ៣៦ | ៧៥ |
| សរុប | ៧១ | ៨២០ | ៧៧២ | ១.៥៩២ |

ផ្ទះស្នាក់នៅជាក្រុម ត្រូវបានកំណត់និយមន័យថាជាការថែទាំដែលផ្ដល់ជូនកុមារក្នុងចំនួនកំណត់ណាមួយនៅក្នុងបរិយាកាសគ្រួសារមួយ ក្រោមការត្រួតពិនិត្យពីអ្នកថែទាំមួយក្រុមតូចដែលមិនមែនជាសាច់ញាតិរបស់កុមារ។

រាជធានី-ខេត្តចំនួន១៤ ក្នុងចំណោម២៥ បានធ្វើស្វ័យកំណត់អត្តសញ្ញាណផ្ទះស្នាក់នៅជាក្រុម។ តារាងទី២៣ បង្ហាញថាមានផ្ទះស្នាក់នៅជាក្រុម ចំនួន៧១កន្លែង ដែលត្រូវបានរាយការណ៍ឱ្យដឹងថាផ្ដល់ការថែទាំជំនួសចំពោះកុមារសរុបចំនួន ១.៥៩២នាក់ (កុមារីចំនួន ៥២%)។ ផ្ទះស្នាក់នៅជាក្រុមភាគច្រើន (៨៩%) ស្ថិតនៅក្នុងរាជធានី-ខេត្តចំនួន៦ ក្នុងនោះរាប់បញ្ចូលរាជធានី-ខេត្តអាទិភាពទាំង៥ (ភ្នំពេញ សៀមរាប បាត់ដំបង ព្រះសីហនុ និងកណ្ដាល) និងខេត្តកំពង់ចាម។ បើទោះបីជាផ្ទះស្នាក់នៅជាក្រុមច្រើនបំផុតស្ថិតនៅខេត្តបាត់ដំបង ដោយផ្ដល់ការថែទាំដល់កុមារសរុបចំនួន១២៦នាក់ក៏ដោយ ប៉ុន្តែកុមារភាគច្រើនដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម ស្ថិតនៅរាជធានី-ខេត្តចំនួន ២ គឺខេត្តព្រះសីហនុ ដែលមានកុមារចំនួន ៩៤៨នាក់ (កុមារីចំនួន៤៥%) និងបន្ទាប់មកគឺរាជធានីភ្នំពេញ ដែលមានកុមារចំនួន៩២២នាក់ (កុមារីចំនួ៥៨%)។

### ៤.៤.៣ ទិន្នន័យអំពីអន្តេវាសិកដ្ឋាន និងកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ

**តារាងទី២៤៖** ចំនួនអន្តេវាសិកដ្ឋាន និង ចំនួនកុមារដែលកំពុងរស់នៅកន្លែងទាំងនេះ

| រាជធានី-ខេត្ត | ចំនួនអន្តេវាសិកដ្ឋាន (តាមលំដាប់លំដោយពីច្រើនមកតិច) | | | |
|---|---|---|---|---|
| ភ្នំពេញ | ២២ | ១.១៧៩ | ១.០៣៦ | ២.២១៥ |
| សៀមរាប | ១៦ | ៥៣៩ | ៧៦៨ | ១.៣០៧ |
| បន្ទាយមានជ័យ | ១១ | ៣១២ | ២៦០ | ៥៧២ |
| បាត់ដំបង | ៣ | ៤ | ១០១ | ១០៥ |
| កណ្ដាល | ៤ | ៣៩ | ៩១ | ១៣០ |
| កំពត | ៣ | ១៣៣ | ២៩៥ | ៤២៨ |
| កំពង់ឆ្នាំង | ២ | ១៦៣ | ១០៤ | ២៦៧ |
| កំពង់ស្ពឺ | ២ | ១១ | ១៩ | ៣០ |
| កំពង់ធំ | ២ | ១១៣ | ១២៨ | ២៤១ |
| ព្រះវិហារ | ២ | ៣៥ | ១៣ | ៤៨ |
| មណ្ឌលគិរី | ១ | ៥៦ | ៣០ | ៨៦ |
| ព្រះសីហនុ | ១ | ១០៣ | ១២៨ | ២៣១ |
| ពោធិ៍សាត់ | ១ | ៦ | ៥ | ១១ |
| រតនគិរី | ១ | ២០៤ | ១៣៣ | ៣៣៧ |
| ស្ទឹងត្រែង | ១ | ១២ | ១៩ | ៣១ |
| សរុប | ៧២ | ២.៩០៩ | ៣.១៣០ | ៦.០៣៩ |

បើនិយាយពីលក្ខណៈបច្ចេកទេស អន្តេវាសិកដ្ឋានត្រូវបានកំណត់និយមន័យថាជា ការរៀបចំលំនៅដ្ឋានសម្រាប់កុមារស្នាក់នៅរយៈពេលសិក្សា១វគ្គ ឬ ច្រើនវគ្គដើម្បីទទួលការអប់រំនៅឆ្ងាយពីផ្ទះ។ អន្តេវាសិកដ្ឋានត្រូវបានបញ្ចូលនៅក្នុងការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ អាស្រ័យដោយមានការព្រួយបារម្ភថា សាលារៀនមួយចំនួនអាចជាមណ្ឌលថែទាំកុមារ។

រាជធានី-ខេត្តចំនួន១៥ ក្នុងចំណោម២៥ បានធ្វើស្វ័យកំណត់អត្តសញ្ញាណអន្តេវាសិកដ្ឋានដែលផ្ដល់ការថែទាំកុមារ។ តារាងទី២៤ បង្ហាញថាមានសាលារៀនបែបនេះចំនួន៧២កន្លែង ដែលផ្ដល់ការថែទាំកុមារចំនួន៦.០៣៩នាក់ (កុមារីចំនួន៤៨%)។ អន្តេវាសិកដ្ឋានភាគច្រើន (៨២%) ស្ថិតនៅក្នុងរាជធានី-ខេត្តចំនួន៦ ក្នុងនោះមានរាជធានី-ខេត្តអាទិភាពចំនួន៤ (លើកលែងតែខេត្ត ព្រះសីហនុ) ខេត្តកំពត និងខេត្តបន្ទាយមានជ័យ។ គ្រាន់តែរាជធានីភ្នំពេញនិងខេត្តសៀមរាបតែឯងមានអន្តេវាសិកដ្ឋានជាងពាក់កណ្ដាលទៅហើយ(៥៣%) ដែលមានកុមារ ៣.៥២២នាក់ (កុមារីចំនួន៤៩%) កំពុងរស់នៅ។ កុមារដែលនៅរាជធានីភ្នំពេញ និងខេត្តសៀមរាបទាំងនេះ មានចំនួនស្មើនឹង ៥៨% នៃចំនួនកុមារសរុបដែលកំពុងរស់នៅក្នុងអន្តេវាសិកដ្ឋាន។

## ៩.៩.៩ គំហើញអំពីការថែទាំតាមវត្តអារាម និងអគារសាសនាដទៃទៀតដែលផ្ដល់ការថែទាំកុមារ

**តារាងទី២៥៖** ចំនួនវត្តអារាម និងអគារសាសនាដទៃទៀតដែលផ្ដល់ការថែទាំកុមារ និងចំនួនកុមារដែលកំពុងរស់នៅទីនោះ

| រាជធានី-ខេត្ត | ចំនួនវត្តអារាម និងអគារសាសនាដទៃទៀតដែលផ្ដល់ការថែទាំកុមារ (តាមលំដាប់លំដោយពីច្រើនមកតិច) | | | |
|---|---|---|---|---|
| បន្ទាយមានជ័យ | ២១ | ១៧៨ | ១៧៣ | ៣៥១ |
| ពោធិ៍សាត់ | ៦ | ៣៩ | ៤៧ | ៨៦ |
| កំពង់ស្ពឺ | ៥ | ២៦ | ៣៦ | ៦២ |
| ព្រះវិហារ | ៥ | ៥៤ | ៧២ | ១២៦ |
| កំពង់ធំ | ៤ | ២៩ | ៤៤ | ៧៣ |
| មណ្ឌលគិរី | ៤ | ៣២ | ៤៣ | ៧៥ |
| ព្រះសីហនុ | ៤ | ១៦៥ | ១៣២ | ២៩៧ |
| កំពង់ឆ្នាំង | ៣ | ២ | ១០ | ១២ |
| កំពត | ៣ | ១៧ | ២៨ | ៤៥ |
| បាត់ដំបង | ២ | ៧៤ | ៣ | ៧៧ |
| កណ្ដាល | ២ | ២ | ១១ | ១៣ |
| សៀមរាប | ២ | ១៤ | ១៨ | ៣២ |
| តាកែវ | ២ | ១១ | ២១ | ៣២ |
| ភ្នំពេញ | ១ | ៤ | ៩ | ១៣ |
| ព្រៃវែង | ១ | ២៦ | ២៩ | ៥៥ |
| សរុប | ៦៥ | ៦៧៣ | ៦៧៦ | ១.៣៤៩ |

វត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់ការថែទាំកុមារ ត្រូវបានកំណត់និយមន័យថាជាការថែទាំដែលផ្តល់ជូនកុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងស្ថាប័នសាសនា ដែលផ្តល់ជូននូវអ្វីដែលជាសេចក្តីត្រូវការមូលដ្ឋានរបស់កុមារនៅក្នុងវត្ត និងកន្លែងសាសនាដទៃទៀត។ គប្បីកត់សម្គាល់ថា មានវត្តអារាម និងអគារសាសនាជាច្រើននៅតាមបណ្តារាជធានី-ខេត្តនានា ប៉ុន្តែ ពុំមែនវត្តអារាម និងអគារសាសនាទាំងអស់សុទ្ធសឹងតែផ្តល់ការថែទាំជំនួសចំពោះកុមារឡើយ។ ក្រុមការងារធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ គ្រាន់តែបានរាប់ចំនួនវត្តអារាម និងអគារសាសនាដែលផ្តល់ការថែទាំកុមារប៉ុណ្ណោះ។

ក្នុងចំណោមរាជធានី-ខេត្តទាំង២៥ មានរាជធានី-ខេត្តចំនួន១៥ ដែលមានវត្តអារាម និងអគារសាសនាដទៃទៀតដែលផ្តល់ការថែទាំកុមារ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារ បានរកឃើញកន្លែងបែបនេះចំនួន៦៥ទីតាំង ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងផ្តល់ការថែទាំកុមារចំនួន ១.៣៤៩នាក់ (កុមារីចំនួន ៥០%)។ អគារទាំងនេះភាគច្រើន (៨៥%) ស្ថិតនៅរាជធានី-ខេត្តចំនួន៧ ក្នុងនោះមានតែខេត្តចំនួនមួយប៉ុណ្ណោះដែលជាខេត្តអាទិភាព (ខេត្តព្រះសីហនុ)។ គ្រាន់តែខេត្តបន្ទាយមានជ័យតែឯង មានវត្តអារាម និងអគារសាសនាដទៃទៀត ចំនួន៣២%។

## ៤.៥ យុវជនវ័យក្មេងដែលកំពុងរស់នៅក្នុងកន្លែងថែទាំប្រភេទផ្សេងៗគ្នា

**តារាងទី២៦៖** យុវជនវ័យក្មេងដែលកំពុងរស់នៅក្នុងកន្លែងថែទាំប្រភេទផ្សេងៗគ្នា បែងចែកទៅតាមភេទ

| ប្រភេទកន្លែងថែទាំកុមារ | | | |
|---|---|---|---|
| មណ្ឌលថែទាំកុមារ | ២.០៥៦ | ៤.៧១៣ | ៦.៧៦៩ |
| ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន | ១៨៥ | ១៣៦ | ៣២១ |
| ផ្ទះស្នាក់នៅជាក្រុម | ៣២០ | ២២៤ | ៥៤៤ |
| វត្តអារាម និង អគារសាសនាដទៃទៀត | ៤៣ | ១៧៩ | ២២២ |
| អន្តេវាសិកដ្ឋាន | ៧១៩ | ៦១២ | ១.៣៣១ |
| សរុប | ៣.៣២៣ | ៥.៨៦៤ | ៩.១៨៧ |

ដូចបានពន្យល់នៅក្នុងផ្នែកខាងដើម មានកន្លែងថែទាំកុមារ ចំនួន៦៣៩កន្លែង ដែលផ្តល់ការថែទាំកុមារក្នុងរាជធានី-ខេត្តទាំង២៥។ ការកំណត់ទីតាំងកន្លែងថែទាំកុមារបានរកឃើញថា មានយុវជនវ័យក្មេងចំនួន ៩.១៨៧នាក់ ដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ២៤ឆ្នាំ (ស្ត្រីចំនួន៣៦%) កំពុងរស់នៅក្នុងកន្លែងថែទាំទាំងនេះ។ វត្តអារាម និង អគារសាសនាដទៃទៀត មានអត្រាភាគរយស្ត្រីរស់នៅទីនោះក្នុងកម្រិតទាបគួរឱ្យកត់សម្គាល់ (១៩%)។ យុវជនវ័យក្មេងភាគច្រើន ចំនួន ៦.៧៦៩នាក់ (៧៤%នៃយុវជនវ័យក្មេង) រាប់បញ្ចូលស្ត្រីចំនួន ២.០៥៦នាក់ កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ។

# ៥. សេចក្តីសន្និដ្ឋានចំពោះគោលនយោបាយ

ខាងក្រោមនេះ គឺជាសេចក្តីសន្និដ្ឋានសំខាន់ៗ ចំពោះការបង្កើតគោលនយោបាយ និងការរៀបចំកម្មវិធី ដែលទទួលបានពីទិន្នន័យកំណត់ទីតាំងកន្លែងថែទាំកុមារ៖

## ១ ការឆ្លើយតបទៅនឹងកំណើនចំនួនកន្លែងថែទាំកុមារ រាប់បញ្ចូលទាំងមណ្ឌលថែទាំកុមារ៖

មានកន្លែងថែទាំកុមារ ៦៣៩កន្លែង រាប់បញ្ចូលទាំងមណ្ឌលថែទាំកុមារ ឬ មណ្ឌលកុមារកំព្រាចំនួន ៤០៦កន្លែង ឬ ៦៤% នៃកន្លែងថែទាំកុមារសរុបនៅក្នុងប្រទេសកម្ពុជា ច្រើនជាងចំនួនដែលក្រសួង ស.អ.យ. បានដឹងកន្លងមក។ មុនពេលមានទិន្នន័យនេះ ក្រសួងបានដឹងត្រឹមតែចំនួន ២៥៤កន្លែង។ បន្ថែមពីនេះ មានកន្លែងថែទាំកុមារសរុប ចំនួន២៣៣កន្លែង ផ្សេងទៀត ដែលស្មើនឹង ៣៦% ដែលមិនស្ថិតនៅក្នុងនិយមន័យមណ្ឌលថែទាំកុមាររបស់រដ្ឋាភិបាលទេ។ ក្នុងចំណោមមណ្ឌលថែទាំកុមារទាំងនោះមានមណ្ឌលចំនួន៣៨% ដែលទើបត្រូវបានរកឃើញថ្មីក្នុងអំឡុងពេលនៃការកំណត់ទីតាំងថែទាំកុមារនេះ ដែលមានន័យថា មណ្ឌលទាំងនោះមិនធ្លាប់បានក្រសួង ស.អ.យ. ចុះធ្វើអធិការកិច្ចឡើយ និងគ្មានការឃ្លាំមើលពីរដ្ឋាភិបាល ដែលបានបង្ហាញឱ្យឃើញអំពីក្តីបារម្ភគួរឱ្យកត់សម្គាល់ចំពោះសុខុមាលភាពរបស់កុមារដែលកំពុងរស់នៅក្នុងមណ្ឌលទាំងនោះ។

---

*គំហើញបង្ហាញឱ្យដឹងថា ក្រសួងត្រូវពង្រីកវិសាលភាពការងាររបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងកំណើនមណ្ឌលថែទាំកុមារ។ ការដែលមានវត្តមានកន្លែងថែទាំកុមារច្រើនប្រភេទ "ដទៃទៀត" ដែលពុំមានលក្ខខណ្ឌស្របទៅនឹងនិយមន័យមណ្ឌលថែទាំកុមារ បង្ហាញឱ្យឃើញអំពីសេចក្តីត្រូវការជាបន្ទាន់ឱ្យមានការផ្តោតយកចិត្តទុកដាក់ផ្នែកគោលនយោបាយ ផែនការ និងកម្មវិធីកាន់តែមានប្រសិទ្ធិភាព។ ជាពិសេស មណ្ឌល និងកន្លែងថែទាំកុមារដែលទើបត្រូវបានកំណត់រកឃើញថ្មី ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធអធិការកិច្ចរបស់ក្រសួង ស.អ.យ. ជាចាំបាច់ដើម្បីឱ្យកន្លែងទាំងនោះទទួលបានការត្រួតពិនិត្យជាទៀងទាត់។ ក្រសួងក៏ត្រូវបង្កើត ប្រព័ន្ធផ្តល់របាយការណ៍ដែលមានទំនាក់ទំនងជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ឬ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដើម្បីកំណត់រកកន្លែងថែទាំកុមារថ្មីៗ ដែលអាចទើបនឹងបើក ដើម្បីឱ្យបញ្ជីអធិការកិច្ចអាចត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់។*

## ២ របាយមិនស្មើគ្នានៃកន្លែងថែទាំកុមារទូទាំងប្រទេសកម្ពុជា និងតម្រូវឲ្យមានការប្រើប្រាស់យុទ្ធសាស្ត្រទ្វេវិធាន៖

បើទោះបីជាមានការកើនឡើងជារួមនៃចំនួនមណ្ឌលថែទាំកុមារនៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែរបាយនៃកន្លែងទាំងនេះពុំមានភាពស្មើគ្នាឡើយ។ បើធៀបនឹងលទ្ធផលរបាយការណ៍អធិការកិច្ចឆ្នាំ២០១៥ បានឱ្យដឹងថា ពុំមានការកត់ត្រាអំពីមណ្ឌលដែលមិនត្រូវបានកំណត់រកឃើញ ឬ មណ្ឌលដែលមិនត្រូវបានធ្វើអធិការកិច្ចកន្លងមក នៅក្នុងខេត្តចំនួន១០ ឡើយ។ ទិន្នន័យនេះក៏បង្ហាញឱ្យដឹងផងដែរថា ខេត្តជាច្រើន មានចំនួនមណ្ឌលទាបគួរឱ្យកត់សម្គាល់ លើកលែងតែក្នុងករណីនៃមណ្ឌលថែទាំកុមារដទៃទៀតមានចំនួនតិចតួចនៅតាមបណ្តាខេត្តនានា ដោយខេត្តជាច្រើនបានកត់ត្រាថាគ្មានកន្លែងថែទាំកុមារដទៃទៀត ក្រៅពីមណ្ឌលថែទាំកុមារ។ សូម្បីតែរបាយមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា ក៏មានភាពមិនស្មើគ្នាក្នុងកម្រិតមួយដ៏ខ្ពស់ផងដែរ។ មណ្ឌលភាគច្រើន (៨៣%) ប្រមូលផ្តុំក្នុងរាជធានី-ខេត្តចំនួន៩ (ភ្នំពេញ សៀមរាប បាត់ដំបង ព្រះសីហនុ កណ្តាល កំពង់ធំ កំពត កំពង់ឆ្នាំង និងកំពង់ស្ពឺ)។ មណ្ឌលថែទាំកុមារដែលមានចំនួន

២

ចន្លោះពី ១ ទៅ ៩ មណ្ឌល ស្ថិតនៅក្នុងខេត្តដែលនៅសេសសល់ចំនួន១៥ដទៃទៀត។ ពុំមានកំណត់ត្រាថាមានមណ្ឌលថែទាំកុមារ (ឬកន្លែងថែទាំកុមារប្រភេទដទៃទៀត) នៅក្នុងខេត្តត្បូងឃ្មុំឡើយ។

*គំហើញបង្ហាញឱ្យដឹងអំពីសេចក្តីត្រូវការ ក្នុងការជ្រើសរើសប្រើប្រាស់យុទ្ធសាស្ត្រទ្វេវិធានមួយ ដើម្បីកាត់បន្ថយ (នៅក្នុងបណ្តារាជធានី-ខេត្តដែលមានចំនួនមណ្ឌលថែទាំកុមារច្រើន) និង ទប់កុំឱ្យមានការកើនឡើង (ចំពោះកន្លែងដែលកំណត់រកឃើញថាមានចំនួនមណ្ឌលតិច ឬគ្មានមណ្ឌលថ្មី)។ ទង្វើបែបនេះនឹងធានាបានថាគ្រប់រាជធានី-ខេត្តទាំងអស់ស្ថិតនៅក្រោមការឃ្លាំមើលរបស់ក្រសួង និង មានយន្តការត្រួតពិនិត្យ ត្រូវតែបង្កើតឲ្យមានដើម្បីឱ្យមណ្ឌលថ្មីៗ ដែលបើកនៅពេលអនាគត ត្រូវតែជូនដំណឹងដល់ក្រសួងភ្លាមៗ។ ទិន្នន័យអំពីការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ ក៏នឹងផ្តល់មគ្គុទ្ទេសក៍ណែនាំដល់ការកំណត់ចំនួនមណ្ឌលថែទាំកុមារដែលចង់បានបំផុត មុននឹងនិងសម្រេចទទួលយកពាក្យសុំបើកមណ្ឌលថ្មី នៅក្នុងរាជធានី-ខេត្តផ្សេងៗ។*

៣

## ពិនិត្យឡើងវិញទៅលើរាជធានី-ខេត្តអាទិភាពទាំង៥៖

ក្នុងចំណោមរាជធានី-ខេត្តទាំង៩ ដែលបានរក ឃើញមណ្ឌលថែទាំកុមារចំនួន៨៣% មានតែរាជធានី-ខេត្តចំនួន៥ប៉ុណ្ណោះ ដែលជាអាទិភាព (ភ្នំពេញ សៀមរាប បាត់ដំបង ព្រះសីហនុ កណ្តាល)។ ទន្ទឹមនឹងនេះដែរ កុមារភាគច្រើនដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ (៨៧%នៃចំនួនកុមារសរុប) ស្ថិតនៅក្នុងរាជធានី-ខេត្តដដែលទាំង៩នោះ។ ក្នុងនោះ រាជធានី-ខេត្តអាទិភាពទាំង៥ មានកុមារ ៧១% នៃចំនួនកុមារសរុប។ បើទោះជាដូច្នេះក្តី ខេត្តដទៃទៀតទាមទារឱ្យមានកិច្ចខិតខំជាក់លាក់ ឧទាហរណ៍ដូចជា ខេត្តដែលកុមារភាគច្រើនមានអាយុក្រោម៣ឆ្នាំ ឬ មានកុមារច្រើនដែលមានសេចក្តីត្រូវការពិសេស។

*គំហើញបានឱ្យដឹងថា ការផ្តោតយកចិត្តទុកដាក់របស់កម្មវិធីទៅលើតំបន់ភូមិសាស្ត្រ ក្នុងរាជធានី-ខេត្ត អាទិភាពទាំង៥ នាពេលបច្ចុប្បន្ន គឺជាការត្រឹមត្រូវ និងនៅតែមានភាពពាក់ព័ន្ធ អាស្រ័យដោយរាជធានី-ខេត្តទាំងនេះ មានចំនួនមណ្ឌល និងកុមារច្រើន។ បើទោះជាដូច្នេះក្តី ខេត្តចំនួន៤ទៀត ដែលមានការប្រមូលផ្តុំមណ្ឌលថែទាំកុមារក្នុងកម្រិតមួយដ៏ខ្ពស់ ក៏គប្បីផ្តោតអាទិភាពផងដែរ។ ការយកចិត្តទុកដាក់ក៏គប្បីផ្តោតលើបណ្តាខេត្តដែលអាចជាករណីពិសេស ដូចជាខេត្តដែលមានចំនួនកុមារតូចច្រើន កុមារដែលមានសេចក្តីត្រូវការពិសេស ឬ ខេត្តដែលមានវត្តអារាមច្រើនដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ។ រាជធានី-ខេត្តអាទិភាពគប្បីត្រូវបានពិនិត្យ និងចាត់អាទិភាពឡើងវិញឱ្យបានទៀងទាត់។*

## ៤ កំណត់អាទិភាពទៅលើការថែទាំរយៈពេលខ្លី និងបណ្ដោះអាសន្ន៖

មណ្ឌលថែទាំកុមារភាគច្រើន (៧២%) ផ្ដល់ការថែទាំរយៈពេលវែង (ត្រូវបានកំណត់និយមន័យថាជាការថែទាំលើសពី៦ខែ) បើទោះបីជាមានការយល់ដឹងច្បាស់អំពីបញ្ហាទាក់ទងនឹងការរក្សាកុមារនៅក្នុងមណ្ឌលរយៈពេលវែងក៏ដោយ។ គោលការណ៍ណែនាំរបស់រដ្ឋាភិបាល និងគោលការណ៍ណែនាំអន្តរជាតិ ថ្លែងថាការថែទាំតាមមណ្ឌលគប្បីជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្ដោះអាសន្ន ហើយការថែទាំតាមគ្រួសារ និង សហគមន៍ គឺជាជម្រើសប្រសើរបំផុត សម្រាប់ការថែទាំជំនួស។ កុមារ និងយុវជនវ័យក្មេងគ្រប់រូប មានសិទ្ធិរស់នៅក្នុងបរិយាកាសមួយដែលផ្ដល់កិច្ចគាំទ្រ ការការពារ និងការថែទាំ ដែលជំរុញឱ្យពួកគេសម្រេចបាននូវសក្ដានុពលពេញលេញរបស់ខ្លួន។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេស គឺជាចំនួនផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្ដោះអាសន្ន ដែលមានចំនួនតិចជាងគេបំផុតក្នុងចំណោមកន្លែងថែទាំកុមារ (២៤%) និងត្រូវបានរកឃើញនៅក្នុងរាជធានី-ខេត្តចំនួន៦ប៉ុណ្ណោះ។

---

*មណ្ឌលថែទាំកុមាររយៈពេលវែងមានចំនួនច្រើន នេះបញ្ជាក់ឲ្យឃើញថាមណ្ឌលទាំងនេះមិនមែនកំពុងត្រូវបានប្រើប្រាស់ជាជម្រើសបណ្ដោះអាសន្ន ឬ ជម្រើសចុងក្រោយឡើយ។ មណ្ឌលថែទាំកុមាររយៈពេលវែង មានចំនួនច្រើនលើសពីសេចក្ដីត្រូវការ ប៉ុន្តែពុំមានកន្លែងដែលមានឯកទេសខាងផ្ដល់ការថែទាំរយៈពេលខ្លីគ្រប់គ្រាន់ឡើយ។ ក្រសួង ស.អ.យ. និងលើកកម្ពស់ការថែទាំរយៈពេលខ្លី ក្នុងករណីដែលអាចធ្វើទៅបាន។ ការផ្លាស់ប្ដូរកន្លែងផ្ដល់ការថែទាំរយៈពេលវែងទៅជាកន្លែងផ្ដល់ថែទាំរយៈពេលខ្លី គប្បីយកមកពិចារណាជាជម្រើសមួយ។*

## ៥ ការឃ្លាំមើល និង ការត្រួតពិនិត្យរបស់រដ្ឋាភិបាល៖

មណ្ឌលថែទាំកុមារចំនួន ២១% ពុំមានអនុស្សរណៈនៃការយោគយល់ជាមួយរដ្ឋាភិបាល និង ១២% ពុំមានចុះបញ្ជីជាមួយទីភ្នាក់ងាររដ្ឋាភិបាលណាមួយឡើយ។ មណ្ឌលថែទាំកុមារភាគច្រើន (៩២%) ស្ថិតនៅក្នុងរាជធានី-ខេត្តចំនួន៧ នៃរាជធានី-ខេត្តទាំង៩ ដែលមាន ចំនួនមណ្ឌលច្រើន (លើកលែងតែខេត្តកំពត និងបាត់ដំបង) ដោយមានមណ្ឌលចំនួន៣៧ មិនបានចុះបញ្ជី (៧៤%នៃមណ្ឌលសរុបដែលមិនបានចុះបញ្ជី) នៅក្នុងរាជធានី-ខេត្តអាទិភាពចំនួន៤ ក្នុងចំណោមរាជធានី-ខេត្តអាទិភាពទាំង៥។ ស្រដៀងគ្នានេះដែរ មណ្ឌលថែទាំកុមារភាគច្រើន (៩៧%) ស្ថិតនៅក្នុងរាជធានី-ខេត្តអាទិភាពទាំង៥។

---

*ការកំណត់ទីតាំងកន្លែងថែទាំកុមារ បញ្ជាក់ទៅលើការសន្និដ្ឋានថាមានមណ្ឌលថែទាំកុមារច្រើនជាងនេះ នៅក្នុងប្រទេសកម្ពុជា ដោយមណ្ឌលមួយចំនួនស្ថិតក្រោមការឃ្លាំមើលរបស់ក្រសួងដទៃទៀត ពិភាក្សាសម្របសម្រួល និងមានការកំណត់ឱ្យស្ថិតនៅក្រោមក្របខ័ណ្ឌគ្រប់គ្រងរួមតែមួយ។ ការកំណត់ទីតាំងកន្លែងថែទាំកុមារ ក៏បង្ហាញឱ្យដឹងផងដែរថា ការត្រួតពិនិត្យមិនសូវមានប្រសិទ្ធភាពនៅក្នុងរាជធានី-ខេត្តទាំង៩ ដែលមានការប្រមូលផ្ដុំមណ្ឌលថែទាំកុមារច្រើន ហើយក៏បង្ហាញឱ្យឃើញអំពីសេចក្ដីត្រូវការឱ្យមានធនធានបន្ថែមទៀត ដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងរាជធានី-ខេត្តទាំងនេះ។ អនុក្រឹត្យស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ គឺជាជំហានមួយដ៏ត្រឹមត្រូវនៅក្នុងទិសដៅនេះ។ ការទាមទារឱ្យមានការបន្តសម្របសម្រួល និងសហប្រតិបត្តិការរវាងបណ្ដាក្រសួងនានា ដើម្បីឱ្យមានការឆ្លើយតបប្រកបដោយភាពសុខដុមចំពោះកុមារដែលស្ថិតនៅក្នុងកន្លែងថែទាំប្រភេទផ្សេងៗគ្នា។*

## ៦ ផ្តល់អាទិភាពលើការធ្វើសមាហរណកម្មកុមារអាយុចន្លោះពី០ ទៅ ៣ឆ្នាំ៖

នៅក្នុងខេត្តទាំង២០ ដែលមានទិន្នន័យនេះ កុមារអាយុចន្លោះពី ០ ទៅ ៣ឆ្នាំ មានចំនួនភាគរយទាបគួរឱ្យកត់សម្គាល់ (២%) នៃចំនួនកុមារសរុបក្នុងមណ្ឌល។ បើទោះជាដូច្នេះក្តី ចំណុចនេះគប្បីត្រូវបានមើលឃើញនៅក្នុងបរិបទដែលការស្រាវជ្រាវបង្ហាញថា ការរស់នៅក្នុងមណ្ឌលបង្កការខូចខាតកាន់តែធ្ងន់ធ្ងរ ចំពោះកុមារដែលមានអាយុក្រោម៣ឆ្នាំ។ អ្វីដែលជាការព្រួយបារម្ភបន្ថែមទៀត គឺកុមារដែលមានអាយុចន្លោះពី ០ ទៅ ៣ឆ្នាំទាំងអស់ ត្រូវបានរកឃើញថាកំពុងរស់នៅក្នុងកន្លែងផ្តល់ការថែទាំរយៈពេលវែង។ ក្នុងចំណោមខេត្តទាំង ២០ មានខេត្តចំនួន៣ (តាកែវ កំពង់ស្ពឺ និងកំពត) ដែលមានកុមារអាយុចន្លោះពី ០ ទៅ ៣ឆ្នាំ ជាងពាក់កណ្តាល (៥៦%) នៃចំនួនកុមារសរុបក្នុងក្រុមអាយុនេះ។ ទិន្នន័យនេះត្រូវបានប្រមូលពីខេត្តចំនួន២០ប៉ុណ្ណោះ ដោយមិនរាប់បញ្ចូលរាជធានី-ខេត្តអាទិភាពទាំង៥។ ការសិក្សាដទៃទៀត ជាពិសេសគឺការសិក្សាដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក៏បានរកឃើញផងដែរថា កុមារដ៏ច្រើនលើសលប់ស្ថិតនៅក្នុងវ័យសិក្សានៅឯសាលារៀន។

*ទិន្នន័យនេះបានឱ្យដឹងថា ដោយសារតែមិនសូវមានកុមារអាយុចន្លោះពី ០ ទៅ ៣ឆ្នាំ នៅក្នុងមណ្ឌល និង ដោយសារតែកុមារទាំងនោះប្រមូលផ្តុំតែនៅក្នុងបណ្តារាជធានី-ខេត្តមួយចំនួន ដូច្នេះគេអាចកំណត់អាទិភាពនៃការធ្វើសមាហរណកម្មកុមារបានឡើយ។*

## ៧ ការឃ្លាំមើលជាក់លាក់ចំពោះមណ្ឌលដែលកំពុងផ្តល់សេវាសម្រាប់កុមារដែលមានសេចក្តីត្រូវការពិសេស៖

មានមណ្ឌលថែទាំជាច្រើនដែលកុមារមានតម្រូវការពិសេសកំពុងរស់នៅ ដោយយ៉ាងហោចណាស់មានរាជធានី-ខេត្តចំនួន១៨ រាយការណ៍ឱ្យដឹងអំពីកុមារដែលមានសេចក្តីត្រូវការពិសេសយ៉ាងតិចមួយប្រភេទ កំពុងរស់នៅក្នុងមណ្ឌល។ បើទោះជាដូច្នេះក្តី មានរាជធានី-ខេត្តមួយចំនួនតូចប៉ុណ្ណោះ ដែលកត់ត្រាថាកុមារបែបនេះមានចំនួនច្រើន។

*ទិន្នន័យបានឱ្យដឹងថាកុមារដែលមានសេចក្តីត្រូវការពិសេស កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារទូទាំងប្រទេសកម្ពុជា ហើយរបាយកុមារទាំងនេះពុំមានភាពស្មើគ្នាឡើយ។ ទាមទារឱ្យមានកិច្ចគាំទ្រជាក់លាក់ និងការឃ្លាំមើលមណ្ឌលដែលផ្តល់សេវាសម្រាប់កុមារដែលមានសេចក្តីត្រូវការពិសេស អាស្រ័យដោយកុមារទាំងនោះងាយរងគ្រោះជាងគេ។ អាស្រ័យដោយមណ្ឌលបែបនេះមានការប្រមូលផ្តុំ តែនៅតាមរាជធានី-ខេត្តមួយចំនួន ដូច្នេះការឃ្លាំមើលបន្ថែមនេះអាចធ្វើទៅបាន។*

# ៦. សេចក្តីសន្និដ្ឋាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ ដើម្បីដោះស្រាយបញ្ហាកង្វះព័ត៌មានអំពីចំនួនកន្លែងផ្តល់ការថែទាំកុមារ។ បើទោះបីជាធនធាន និងវិធីសាស្រ្តមានកម្រិត ប៉ុន្តែការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ បានបង្កលក្ខណៈឱ្យក្រសួងកំណត់បានថា មានភាពខុសគ្នារវាងចំនួនកន្លែងថែទាំកុមារជាក់ស្តែង និងចំនួនដែលបានរាយការណ៍នៅក្នុងប្រទេសកម្ពុជា។ នេះជាកត្តាបង្ហាញឲ្យឃើញពីភាពខ្វះខាតនៃប្រព័ន្ធថែទាំសុខុមាលភាពកុមារ ហើយក៏បញ្ជាក់ផងដែរអំពីការព្រួយបារម្ភរបស់រដ្ឋាភិបាល និងភ្នាក់ងារការពារកុមារចំពោះសុខុមាលភាពរបស់កុមារ ដែលបាននិងកំពុងរស់នៅក្នុងមណ្ឌលដែលគ្មានការត្រួតពិនិត្យ ជាពិសេសខ្វះយន្តការទប់ស្កាត់នៃការកើនឡើង “មណ្ឌលកុមារកំព្រា”។ សំខាន់ជាងនោះទៅទៀតគំហើញនេះបានផ្តល់ឱ្យក្រសួងនូវព័ត៌មានគ្រប់ជ្រុងជ្រោយអំពីស្ថានភាពកុមារដែលបាន និងកំពុងរស់នៅក្នុងមណ្ឌល ហើយក៏ជាជំហានដំបូងមួយឆ្ពោះទៅរកការធ្វើសមាហរណកម្មកុមារ ទៅគ្រួសារ និងសហគមន៍វិញ ។

ក្រសួង សូមបញ្ជាក់ជាថ្មីឡើងវិញអំពីការប្តេជ្ញាចិត្តក្នុងការបន្តលើកកម្ពស់ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ និង ទប់ស្កាត់ការយកកុមារទៅដាក់ក្នុងមណ្ឌលក្នុងករណីមិនចាំបាច់ ហើយការអនុម័តនាពេលថ្មីៗនេះ ទៅលើអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារនៅក្នុងប្រទេសកម្ពុជាគឺជាសមិទ្ធផលមួយដ៏សំខាន់ដែលនឹងជួយជំរុញការអនុវត្តក្របខ័ណ្ឌគតយុត្តិដែលមានស្រាប់ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ និងធានាដល់ការអនុវត្តក្របខ័ណ្ឌច្បាប់នានា ស្តីពីការថែទាំជំនួសដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ក្រសួងនិងធ្វើសមាហរណកម្មកុមារ ចំនួន៣០% ពីមណ្ឌលថែទាំកុមារ ឱ្យបានត្រឹមឆ្នាំ២០១៨ និងទប់ស្កាត់ចំពោះការយកកុមារអាយុក្រោម៣ឆ្នាំ ទៅដាក់នៅក្នុងមណ្ឌល។ ការកំណត់ទីតាំងកន្លែងថែទាំកុមារនេះមានសារៈសំខាន់ខ្លាំងសម្រាប់ក្រសួងក្នុងការអនុវត្តគោលនយោបាយ និងបទដ្ឋានគតិយុត្តឲ្យកាន់តែមានប្រសិទ្ធិភាពដើម្បីទប់ស្កាត់ការកើនឡើងនៃចំនួនកន្លែងថែទាំកុមារ។

គំហើញពីការកំណត់ទីតាំងកន្លែងថែទាំកុមារនេះ នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីពិនិត្យកែសម្រួលឡើងវិញនូវគោលនយោបាយ និងការរៀបចំកម្មវិធីនានាដោយរដ្ឋាភិបាលទាក់ទងនឹងការធ្វើសមាហរណកម្មកុមារពីមណ្ឌល ដើម្បីសំដៅឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅធ្វើសមាហរណកម្មកុមារចំនួន ៣០%ពីមណ្ឌលថែទាំកុមារ។ ទិន្នន័យនេះនឹងត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីវាស់ស្ទង់អំពីប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារនៅកម្ពុជាផងដែរ។

# ចំនួន និងប្រភេទកន្លែងថែទាំកុមារ ដែលកំពុងផ្តល់ការថែទាំកុមារ

**៤០៦**
មណ្ឌលថែទាំកុមារ

**២៥**
ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្ន

**៧១**
ផ្ទះស្នាក់នៅជាក្រុម

**៦៥**
វត្តអារាម និង អគារសាសនាដទៃទៀត ដែលផ្តល់កន្លែងស្នាក់នៅសម្រាប់កុមារ

**៧២**
សាលារៀនដែលផ្តល់កន្លែងស្នាក់នៅ

unicef for every child

Together, building stronger child protection systems

USAID FROM THE AMERICAN PEOPLE